ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងមហាផ្ទៃ

# របាយការណ៍ស្តីពី លទ្ធផលការងារឆ្នាំ២០២០
# និងលើកទិសដៅការងារឆ្នាំ២០២១

# រៀបរៀងដោយ

# នាយកដ្ឋានសរុប និងស្ថិតិ នៃអគ្គលេខាធិការដ្ឋាន

# ក្រសួងមហាផ្ទៃ


ទីស្តីការក្រសួងមហាផ្ទៃ : លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារ : (៨៥៥) ២៣ ៧២៦ ០៥២ - ២៣ ៧២៦ ០៥៣

អ៊ីម៉ែល : moi@interior.gov.kh

វេបសាយ : www.interior.gov.kh

# មាតិកា

I. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២០ ........ ២
១-ការងារពង្រឹងស្ថាប័ន ........ ២
២-ការងារតាមវិស័យ ........ ៣
២.១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ........ ៣
២.២-ការងារគ្រប់គ្រងរដ្ឋបាលដែនដី ........ ៤
ក-ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ៤
ខ-ការសម្របសម្រួល និងសហការអនុវត្តគម្រោងដោយផ្នែកនានា ........ ៨
គ-ការងារជំនាញផ្សេងទៀត ........ ៩
២.៣-ការងារគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច ........ ១០
២.៤-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ........ ១១
ក-សភាពការណ៍អន្តរជាតិដែលពាក់ព័ន្ធដល់សន្តិសុខជាតិ ........ ១១
ខ-ការចាត់តាំង អនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ........ ១១
គ-អំពីការងាររក្សាសន្តិសុខជាតិ ........ ១២
ឃ-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស ........ ១៣
ង-សភាពការណ៍ និងកិច្ចប្រតិបត្តិការរក្សាសណ្តាប់ធ្នាប់សាធារណៈ ........ ១៤
ច-សភាពការណ៍ និងកិច្ចប្រតិបត្តិការរក្សា ការពារសន្តិសុខព្រំដែន ........ ១៤
២.៥-ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ........ ១៥
២.៦-ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ........ ១៦
២.៧-ការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ........ ១៨
២.៨-ការងារអត្តសញ្ញាណកម្ម ........ ១៩
ក-ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ........ ១៩
ខ-ការងារអត្រានុកូលដ្ឋាន ........ ១៩
គ-ការគ្រប់គ្រងការស្នាក់នៅ ........ ២០
ឃ-ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែន ........ ២០
ង-ការងារសញ្ជាតិ ........ ២១
ច-ការងារពង្រឹងយន្តការផ្តល់សេវាអត្តសញ្ញាណកម្ម ........ ២១
ឆ-វឌ្ឍនភាពនៃការផ្តល់ឯកសាររដ្ឋបាលកម្ពុជាឱ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន្ត ........ ២១
២.៩-ការងារអន្តោប្រវេសន៍ ........ ២២
ក-ការងារគ្រប់គ្រងដំណើរចេញ ចូលប្រទេស ........ ២២
ខ-ការងារគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ........ ២២
គ-ការងារគ្រប់គ្រងជនបរទេសជាអ្នកវិនិយោគ និងហត្ថពលកម្មបរទេស ........ ២៣
ឃ-ការងារស៊ើបអង្កេត និងអនុវត្តនីតិវិធី ........ ២៣
២.១០-ការងារគ្រប់គ្រងពន្ធនាគារ ........ ២៣

២.១១-ការងារបណ្ឌិត្យសភានគរបាលកម្ពុជា ........ ២៤
២.១២-ការងារភស្តុភារ និងហិរញ្ញវត្ថុ ........ ២៥
២.១៣-ការងារអធិការកិច្ច ........ ២៧
២.១៤-ការងារសវនកម្មផ្ទៃក្នុង ........ ២៧
២.១៥-ការងារទំនាក់ទំនងអន្តរជាតិ ........ ២៨
២.១៦-ការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ........ ២៩
II. សេចក្តីសន្និដ្ឋាន ........ ៣០
III. ទិសដៅការងារឆ្នាំ២០២១ ........ ៣៣
១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ........ ៣៣
២-ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ........ ៣៤
៣-អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ៣៤
ក-ការអភិវឌ្ឍគោលនយោបាយ ប្រព័ន្ធ និងរចនាសម្ព័ន្ធអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៣៤
ខ-ការផ្ទេរធនធានពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ........ ៣៥
គ-ការផ្តល់សេវារដ្ឋបាល ........ ៣៥
ឃ-ការសម្របសម្រួល និងសហការអនុវត្តគម្រោងដោយឡែកនានា ........ ៣៦
ង-ការងារជំនាញដទៃទៀត ........ ៣៦
៤-ការងារគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច ........ ៣៦
៥-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ........ ៣៧
៦-ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ........ ៣៨
៧-ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ........ ៣៨
៨-ការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ........ ៣៩
៩-ការងារអត្តសញ្ញាណកម្ម ........ ៣៩
១០-ការងារអន្តោប្រវេសន៍ ........ ៤០
១១-ការងារពន្ធនាគារ ........ ៤១
១២-ការងារបណ្ឌិត្យសភានគរបាលកម្ពុជា ........ ៤១
១៣-ការងារភស្តុភារ និងហិរញ្ញវត្ថុ ........ ៤២
១៤-ការងារអធិការកិច្ច ........ ៤២
១៥-ការងារសវនកម្មផ្ទៃក្នុង ........ ៤៣
១៦-ការងារទំនាក់ទំនងអន្តរជាតិ ........ ៤៣
១៧-ការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ........ ៤៣
១៨-កិច្ចសហការសម្របសម្រួលអន្តរស្ថាប័ន ........ ៤៣
ឧបសម្ព័ន្ធ ........ ៤៥



**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០២៤.របក.

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០២១

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១
## របស់ក្រសួងមហាផ្ទៃ

ក្នុងឆ្នាំ២០២០ កន្លងទៅនេះ សភាពការណ៍សន្តិសុខអន្តរជាតិមានការវិវត្តប្រែប្រួលឆាប់រហ័ស ប្រកបដោយហានិភ័យខ្ពស់ ពិបាកប៉ាន់ស្មាន បណ្តាលមកពីការប្រកួតប្រជែងកាន់តែស្រួចស្រាល់រវាងមហាអំណាចធំៗ ដែលមានផលប៉ះពាល់មកលើសន្តិសុខក្នុងសកលលោក និងតំបន់ ។ ទន្ទឹមគ្នានេះ ការផ្ទុះឡើងនៃជំងឺរាតត្បាតសកលកូវីដ-១៩ ក៏បានបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរមិនធ្លាប់កើតមានមកលើប្រទេសនានាជាច្រើន ក្នុងនោះ រួមទាំងកម្ពុជាផងដែរ ។ ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងចាត់គ្រប់វិធានការ ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងដោះស្រាយផលលំបាកនានាបណ្តាលមកពីជំងឺនេះ និងគ្រោះជំនន់ទឹកភ្លៀងដែលបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរនៅក្នុងផ្ទៃក្នុងប្រទេស ក្រុមឧទ្ទាមក្រៅច្បាប់នៅតែបន្តធ្វើសកម្មភាពទាំងក្នុង និងក្រៅប្រទេស ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរបៀបបដិវត្តន៍ពណ៌ ។ ប៉ុន្តែទោះបីយ៉ាងនេះក្តី ព្រះរាជាណាចក្រកម្ពុជានៅតែរក្សាបានរឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គមទាំងមូល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការនានាយ៉ាងមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងជំងឺរាតត្បាតសកល ការទប់ស្កាត់ឧបាយកលបដិវត្តន៍ពណ៌របស់ក្រុមឧទ្ទាមក្រៅច្បាប់ និងការឆ្លើយតបបានទាន់ពេលវេលាចំពោះផលប៉ះពាល់បណ្តាលមកពីគ្រោះជំនន់ទឹកភ្លៀង រក្សាបានប្រក្រតីភាពនៃគ្រប់សកម្មភាពក្នុងសង្គម និងជីវភាព សុខុមាលភាពប្រជាពលរដ្ឋ ជាពិសេសបង្ការ ទប់ស្កាត់បានប្រកបដោយប្រសិទ្ធភាពពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដែលត្រូវបានអង្គការសុខភាពពិភពលោកវាយតម្លៃខ្ពស់ជាប្រទេសមានសមត្ថភាពក្នុងការចាត់ចែង គ្រប់គ្រងស្ថានភាព និងផលប៉ះពាល់នៃជំងឺនេះ បានយ៉ាងល្អប្រសើរ ។

សមិទ្ធផលដែលសម្រេចបានទាំងនេះ គឺពិតជាមានការប្តេជ្ញាចិត្តគាំទ្រ និងការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ននានា អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ក្នុងនោះ ក្រសួងមហាផ្ទៃបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តបទបញ្ជា និងវិធានការនានារបស់រាជរដ្ឋាភិបាល ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ការជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង និងការងារនានាជាច្រើនក្នុងក្របខ័ណ្ឌតួនាទី ភារកិច្ច របស់ក្រសួងមហាផ្ទៃ ។ ក្រៅពីនេះ ក្រសួងមហាផ្ទៃក៏បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជំរុញអនុវត្តបញ្ចប់នូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ឆ្នាំ (២០១០-២០២០) និងរៀបចំបញ្ចប់នូវកំណែទម្រង់ទស្សនទាន

សម្រាប់ការតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ដើម្បីបន្តកែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។

ជាក់ស្តែង លទ្ធផលការងារដែលក្រសួងមហាផ្ទៃសម្រេចបាន និងកំពុងជំរុញអនុវត្តបន្ត រួមមានជាអាទិ៍ ៖

# I-លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២០

## ១-ការងារពង្រឹងស្ថាប័ន

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចការនានាដែលស្ថិតក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានខិតខំជំរុញនូវកិច្ចការសំខាន់ៗ ដូចខាងក្រោម ៖

-រៀបចំកែសម្រួលអនុក្រឹត្យលេខ ១០៩អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ដោយធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់ប្រហាក់ប្រហែលមួយចំនួនចំណុះក្រសួងមហាផ្ទៃ ក្នុងនោះ រួមទាំងសាលាជាតិរដ្ឋបាលមូលដ្ឋានផងដែរ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងារនៅតាមអង្គភាពនីមួយៗ និងឆ្លើយតបទៅនឹងការវិវត្តនៃកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ។

-ធ្វើការវិភាគមុខងារ កំណត់ចំនួនមុខតំណែង និងតម្រូវការក្របខ័ណ្ឌសម្រាប់រយៈពេលចំពោះមុខ និងរយៈពេលពីមធ្យមទៅរយៈពេលវែង នៅតាមអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ។

-បន្ថែមផ្នែកចំណុះការិយាល័យរដ្ឋបាលសរុប និងការិយាល័យក្របខ័ណ្ឌ នៃនាយកដ្ឋានបុគ្គលិក របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងចំណុះការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បន្ថែមផ្នែកអន្តោប្រវេសន៍ចំណុះអធិការដ្ឋាននគរបាលស្រុកចំនួន ១២ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម មណ្ឌលគិរី និងខេត្តរតនគិរី បង្កើតប៉ុស្តិ៍ចំនួន ០២ ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៧០៥ និងលេខ ៦១៩ របស់ស្នងការដ្ឋាននគរបាលខេត្តរតនគិរី និងបង្កើតការិយាល័យគ្រប់គ្រងសន្តិសុខឯកជនចំណុះផែនសន្តិសុខរបស់ស្នងការដ្ឋាននគរបាលខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ ។

-បង្កើតក្រុមការងារតាមដានអំពីការដោះស្រាយមតិ យោបល់ ឬសំណូមពរ (Comment) របស់មហាជនក្នុងគេហទំព័រហ្វេសប៊ុក (Facebook Page) របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។ ដែលគិតពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារប្រមូលបាននូវមតិ យោបល់ និងសំណូមពរ ពីមហាជនសរុប ៧៦៩ករណី ក្នុងនោះករណីដែលត្រូវដោះស្រាយក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃមាន ៥១៧ករណី (ដោះស្រាយបញ្ចប់បាន ២៣៧ករណី និងកំពុងបន្តដោះស្រាយ ២៨០ករណី) ៣៤ករណី ប្រគល់ជូនអង្គភាពពាក់ព័ន្ធនានាដោះស្រាយ រីឯ ២១៨ករណីទៀត ជាការជូនព័ត៌មានប៉ុណ្ណោះ ។

-ផ្តល់កិច្ចអន្តរាគមន៍គាំទ្រទាំងផ្នែកគោលនយោបាយ ច្បាប់ ធនធានហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសដល់អង្គភាពប្រតិបត្តិការជំនាញ និងអង្គភាពផ្តល់សេវាបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួងមហាផ្ទៃ សំដៅឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃការងារជំនាញ និងតម្រូវការនៃការកសាងសមត្ថភាពនៃមន្ត្រីក្នុងជួរកងកម្លាំងនគរបាលជាតិ និងមន្ត្រីរដ្ឋបាលស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងស្ថានការណ៍ថ្មីៗ។

-ទាំងមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ត្រូវបានយកចិត្តទុកដាក់ពង្រឹងសមត្ថភាពតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលដោយផ្ទាល់ផង និងចាត់បញ្ជូនទៅចូលរួមវគ្គសិក្សារយៈពេលវែង-ខ្លី ទាំងក្នុង និងក្រៅប្រទេសផង ដើម្បីពង្រឹងសមត្ថភាពក្នុងការចាត់ចែង រៀបចំក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់

និងអនុវត្តជាក់ស្តែងលើមុខជំនាញនីមួយៗទាំងផ្នែកសន្តិសុខ និងការងារគ្រប់គ្រងរដ្ឋបាល ។ ជាក់ស្តែង ក្នុងឆ្នាំ ២០២០ មានមន្ត្រីរាជការស៊ីវិលចំនួន ៧.៣២៩រូប មន្ត្រីពន្ធនាគារចំនួន ២៧០រូប និងមន្ត្រីនគរបាលជាតិចំនួន ២.២១០រូប ទទួលបានការបណ្តុះបណ្តាលមុខជំនាញរយៈពេលវែង និងរយៈពេលខ្លីទាំងនៅក្នុង និងក្រៅប្រទេស។ <u>**កត់សម្គាល់**</u> **៖** ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ មានវគ្គសិក្សា និងកម្មវិធីបណ្តុះបណ្តាលជាច្រើន ត្រូវបានផ្អាកដំណើរការ ឆ្លើយតបនឹងស្ថានការណ៍នេះ ក្រសួងក៏បានជំរុញលើកទឹកចិត្តឱ្យអគ្គនាយកដ្ឋាន និងអង្គភាពនីមួយៗ រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងរបស់ខ្លួននៅហ្នឹងកន្លែង ដោយអនុវត្តវិធានការការពារការឆ្លងជំងឺនេះផងដែរ ។

ក្នុងរយៈពេល ០១ឆ្នាំនេះ ស្ថានភាពមន្ត្រីរាជការចំណុះក្រសួងមហាផ្ទៃ មានការប្រែប្រួលដូចតទៅ ៖

**-មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ** ៖ បញ្ចូលក្របខ័ណ្ឌថ្មីចំនួន ១០១រូប កាត់ចេញពីក្របខ័ណ្ឌ ៩៦រូប ដំឡើងឋានន្តរស័ក្តិ-ថ្នាក់សរុប ៣.៨៧២រូប តែងតាំងមុខតំណែងគ្រប់លំដាប់ថ្នាក់សរុប ៨៤៩រូប និងផ្តល់គ្រឿងឥស្សរិយយសចំនួន ២.៧៤២រូប ។ បច្ចុប្បន្ន ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ សរុបមានចំនួន ៧.០៤៥រូប ស្រី ១.២៥២រូប រួមមាន មន្ត្រីរាជការស៊ីវិល (ថ្នាក់ជាតិ ៩៧៣រូប ស្រី ២៤៧រូប និងថ្នាក់ក្រោមជាតិ ២.៩៥៩រូប ស្រី ៥៤១រូប) និងមន្ត្រីពន្ធនាគារ (ថ្នាក់ជាតិ ១.១៧៩រូប ស្រី ១៨៧រូប និងថ្នាក់ក្រោមជាតិ ១.៩៣៤រូប ស្រី ២៧៧រូប) ។

ដោយឡែក បច្ចុប្បន្នភាពគណៈអភិបាល និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានដូចខាងក្រោម៖

+គណៈអភិបាល ៖ មានចំនួនសរុប ១.១១៣រូប ស្រី ២២៦រូប (ថ្នាក់រាជធានី ខេត្ត ១៧៥រូប ស្រី ២៨រូប និងថ្នាក់ក្រុង ស្រុក ខណ្ឌ ៩៣៨រូប ស្រី ១៩៨រូប) ។

+ក្រុមប្រឹក្សា ៖ មានចំនួនសរុប ១៥.៦៨៦រូប ស្រី ៣.១២២រូប (ថ្នាក់រាជធានី ខេត្ត ៥៥៩រូប ស្រី ៩៦រូប ក្រុង ស្រុក ខណ្ឌ ៣.៥៥៥រូប ស្រី ៦២៥រូប និងឃុំ សង្កាត់ ១១.៥៧២រូប ស្រី ២.៤០១រូប) ។ ក្នុងឆ្នាំ២០២០ បានធ្វើការផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សរុបចំនួន ២៤៩រូប ស្រី ២៧រូប (ថ្នាក់រាជធានី ខេត្ត ០៩រូប ស្រី ០១រូប ក្រុង ស្រុក ខណ្ឌ ៦៣រូប ស្រី ១០រូប និងឃុំ សង្កាត់ ១៧៧រូប ស្រី ១៦រូប) ។

**-មន្ត្រីនគរបាលជាតិ** ៖ បញ្ចូលក្របខ័ណ្ឌថ្មីចំនួន ៤.៤៥៣រូប ដាក់ឱ្យចូលនិវត្តន៍ ១.៧៣៧រូប បណ្តេញចេញពីក្របខ័ណ្ឌ ១២៣រូប តែងតាំងមុខតំណែង និងសម្រួលភារកិច្ច ៨.១៦៥រូប ដំឡើងឋានន្តរស័ក្តិ ១៨.៧៦១រូប និងដកហូតមុខតំណែង-បន្ថយឋានន្តរស័ក្តិចំនួន ១៣រូប ។ បច្ចុប្បន្ន ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិសរុបចំនួន ៦០.២៧៨រូប ស្រី ៥.៣១០រូប (ថ្នាក់ជាតិ ២១.២០១រូប ស្រី ១.៩១១រូប និងថ្នាក់ក្រោមជាតិ ៣៩.០៧៧រូប ស្រី ៣.៣៩៩រូប) ។

## ២-ការងារតាមវិស័យ

### ២.១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ពិសេសលើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជាឆ្លើយតបទៅនឹងស្ថានភាពវិវត្តន៍រីកចម្រើនក្នុងសង្គម នៅក្នុងឆ្នាំ២០២០ នេះ ក្រសួងមហាផ្ទៃបានរៀបចំ និងដាក់ឱ្យអនុវត្តនូវច្បាប់ចំនួន ០៣ អនុក្រឹត្យចំនួន ១៦ រួមទាំងប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ និងបទបញ្ជាមួយចំនួនទៀត ។ ជាមួយនេះ ក្រសួងក៏បានចូលរួមសហការជាមួយក្រសួង ស្ថាប័ននានា ក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាច្រើនទៀតផងដែរ ។ (សូមមើលឧបសម្ព័ន្ធទី១)

### ២.២-ការខារគ្រប់គ្រងរដ្ឋបាលដែនដី

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត ២៤ ក្រុង ២៧ ស្រុក ១៦២ ខណ្ឌ ១៤ ឃុំ ១.៤០៥ សង្កាត់ ២៤១ និងភូមិចំនួន ១៤.៤០៥ ។ <u>**កត់សម្គាល់៖**</u> នៅក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតភូមិថ្មីចំនួន ១១ (ខេត្តតាកែវចំនួន ០២ភូមិ ខេត្តបាត់ដំបងចំនួន ០៩ភូមិ) និងកែសម្រួលព្រំប្រទល់រវាងរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តកណ្ដាល ។ (សូមមើលឧបសម្ព័ន្ធទី២-ទី៤)

#### ក-ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ឆ្នាំ២០២០ ជាឆ្នាំទី៣ នៃការអនុវត្តផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៣ ឬហៅកាត់ថា **ផអ៣ ទី៣** (២០១៨-២០២០) ដែលជាឆ្នាំចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ឆ្នាំ (២០១០-២០២០) ។ ក្នុងការអនុវត្ត **ផអ៣ ទី៣** និងផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ **គ.ជ.អ.ប** ក្រសួងមហាផ្ទៃបានផ្ដោតទៅលើកិច្ចការគន្លឹះៗ ដូចជា ៖ **១**-ការពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងរៀបចំកម្មវិធីនានាសម្រាប់ការងារកំណែទម្រង់ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ **២**-ការរៀបចំ ការពង្រឹងរចនាសម្ព័ន្ធ និងអភិបាលកិច្ចមូលដ្ឋាន **៣**-ការគាំទ្រ និងការសម្របសម្រួលការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ **៤**-ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ និង **៥**-ការគាំទ្រ តាមដាន ត្រួតពិនិត្យការអនុវត្តថវិកា និងមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២០ កន្លងទៅនេះ មានជាអាទិ៍ ៖

**- ការពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងរៀបចំកម្មវិធីនានាសម្រាប់ការងារកំណែទម្រង់**

ដើម្បីជានាដល់ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំសម្របសម្រួលរបស់គ.ជ.អ.ប ក្រសួងមហាផ្ទៃដែលជាស្ថាប័នដ៏សំខាន់មួយក្នុងការអនុវត្តកម្មវិធីជាតិ បានចូលរួមក្នុងការរៀបចំ និងអនុវត្តកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការកែសម្រួលមុខងារ និងរចនាសម្ព័ន្ធអនុគណៈកម្មាធិការចំនួន ០៤ និងការបង្កើតអនុគណៈកម្មាធិការថ្មីចំនួន ០១ របស់ គ.ជ.អ.ប ។
- ការរៀបចំឯកសារទស្សនទាន សម្រាប់ការតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីខែធ្នូ ឆ្នាំ២០២០ ។
- ការរៀបចំ និងដាក់បញ្ចូលផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២១ របស់ គ.ជ.អ.ប ។

**- ការរៀបចំ ការពង្រឹងរចនាសម្ព័ន្ធ និងអភិបាលកិច្ចមូលដ្ឋាន**

ក្នុងឆ្នាំ២០២០ នេះ រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង ២០៣ ត្រូវបានរៀបចំកែសម្រួលឡើងវិញ តាមរយៈការធ្វើសមាហរណកម្មការិយាល័យ និងអង្គភាពជំនាញនានារបស់ក្រសួង ស្ថាប័នចំនួន ២០ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមស្មារតីអនុក្រឹត្យលេខ ១៨២ លេខ ១៨៣ និងលេខ ១៨៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងការធ្វើសមាហរណកម្មមន្ទីរសុខាភិបាលទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត តាមស្មារតីអនុក្រឹត្យលេខ

១៩៣ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ។ ដើម្បីជួយគាំទ្រដល់ការងារនេះ ក្រសួងមហាផ្ទៃបានរៀបចំកិច្ចការចាំបាច់នានាដូចខាងក្រោម ៖

- ការរៀបចំ និងដាក់ចេញសេចក្តីណែនាំស្តីពី ការធានានិរន្តរភាពការងាររដ្ឋបាល និងការផ្តល់សេវាក្នុងដំណាក់កាលនៃដំណើរការរៀបចំរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។
- សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសមាហរណកម្មបុគ្គលិកនៃក្រសួង ស្ថាប័នចំនួន ១៩.៦២៣រូប ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបុគ្គលិកក្នុងវិស័យសុខាភិបាលចំនួន ២០.១២៤រូប ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ។
- ការចុះសិក្សា ស្រាវជ្រាវអំពីការអនុវត្តតួនាទី ភារកិច្ច និងមុខងាររបស់ក្រុង ស្រុក ខណ្ឌ មួយចំនួន ដើម្បីដកពិសោធន៍ការងារ និងពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធថ្មីនេះ សំដៅរិះរកមធ្យោបាយសមស្របសម្រាប់ជួយគាំទ្រ និងលើកកម្ពស់ប្រសិទ្ធភាពការងារបន្ថែមទៀត ។
- ការរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងលេខ ១៥២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត តាមរយៈការផ្ទេររចនាសម្ព័ន្ធនៃមន្ទីរសុខាភិបាលរាជធានី ខេត្ត ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងនោះ រួមមាន ៖ មន្ទីរសុខាភិបាលចំនួន ២៥ មន្ទីរពេទ្យបង្អែករាជធានី ខេត្តចំនួន ២៥ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ១០៣ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌចំនួន ៩២ មណ្ឌលសុខភាពចំនួន ១.២២១ និងប៉ុស្តិ៍សុខភាពចំនួន ១២៧ ។

ក្នុងការពង្រឹងការងារគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានរៀបចំ និងអនុវត្តនូវកិច្ចការសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ការងារគណនេយ្យភាពសង្គម ត្រូវបានបន្តអនុវត្ត និងពង្រីកគ្របដណ្តប់លើរដ្ឋបាលឃុំ សង្កាត់ចំនួន ១.៣៩៩ សាលាបឋមសិក្សា ៦.១៩០ និងមណ្ឌលសុខភាពចំនួន ១.០៩៥ ក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន ១៧០ នៃរាជធានី ខេត្តចំនួន ២៥ ។
- ការអនុវត្តសាកល្បងការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន ០៥ នៃរាជធានី ខេត្តចំនួន ០៣ ។
- ការបង្កើត និងដាក់ឱ្យដំណើរការការិយាល័យប្រជាពលរដ្ឋចំនួន ៣២គោលដៅថ្មី បន្ថែមទៀត ព្រមទាំងពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋទាំងអស់ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល ការរៀបចំ និងកែសម្រួលលិខិតបទដ្ឋានចាំបាច់នានា សម្រាប់ផ្តល់ការណែនាំបន្ថែមដល់ការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋ ។
- ក្នុងឆ្នាំ២០២០ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ទទួលបានការបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋចំនួន ១០.២៤១ករណី ក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ចចំនួន ២២២ករណី (ដោះស្រាយចប់រួចរាល់ ២១៤ករណី និង ០៨ករណីទៀត កំពុងបន្តដោះស្រាយ) បណ្តឹងក្រៅសមត្ថកិច្ច ២៧៣ករណី សំណូមពរ ៧៤៣ករណី ការសរសើរ ២៩[illegible]ករណី និងការសាកសួរព័ត៌មានផ្សេងៗចំនួន ៨.៧១២ករណី ។ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទាំង ២៥ ទទួល

បានពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗចំនួន ១.០១៧ករណី ក្នុងនោះ បណ្ដឹងក្នុងសមត្ថកិច្ចចំនួន ៤៥៣ករណី (ដោះស្រាយចប់រួចរាល់ ៣៤៧ករណី និង ១០៦ករណីទៀត កំពុងបន្តដោះស្រាយ) បណ្ដឹងក្រៅសមត្ថកិច្ច ២៦១ករណី សំណូមពរ ១៤២ករណី ការសរសើរ ០៨ករណី និងការសាកសួរព័ត៌មានផ្សេងៗចំនួន ១៥៣ករណី ។

**- ការគាំទ្រ និងការសម្របសម្រួលការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារដែលបានផ្ទេរពីក្រសួង ស្ថាប័ននានា ក្រោមការដឹកនាំ សម្របសម្រួលរបស់ គ.ជ.អ.ប ក្រសួងមហាផ្ទៃបានចូលរួមសហការក្នុងការរៀបចំ និងអនុវត្តកិច្ចការសំខាន់ៗ ដូចខាងក្រោម ៖

- ការរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ដើម្បីផ្ទេរថវិកាចំនួនប្រមាណ ១៦៦លានដុល្លារ ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់លើការអនុវត្តមុខងារផ្ដល់សេវាសុខាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់ឆ្នាំ២០២១ ។
- ការរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្ទេរថវិកាចំនួនប្រមាណ ៣៣លានដុល្លារ ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារការគ្រប់គ្រងកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំងនោះ ។
- ការផ្ទេរបន្ថែមនូវថវិការដ្ឋប្រមាណជាង ៣២០.០០០ដុល្លារ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់កិច្ចប្រតិបត្តិការរដ្ឋបាលសម្រាប់រយៈពេល ០៦ខែ ចុងឆ្នាំ២០២០ ព្រមទាំងបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំផ្ទេរថវិកាប្រមាណជិត ៣០លានដុល្លារ សម្រាប់ឆ្នាំ២០២១ នេះ ដើម្បីគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ លើកិច្ចប្រតិបត្តិការរដ្ឋបាល និងការអនុវត្តមុខងារក្នុងវិស័យទាំង ២០ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។
- ការគាំទ្រដល់រដ្ឋបាលរាជធានីភ្នំពេញក្នុងការរៀបចំ និងដាក់ចេញនូវដីកា ដើម្បីធ្វើប្រតិភូកម្មមុខងារនានាទៅឱ្យរដ្ឋបាលខណ្ឌ ស្របតាមស្មារតីអនុក្រឹត្យលេខ ១៨៣ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ ។
- ការរៀបចំ និងកែសម្រួលសេចក្ដីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះមានក្រសួងចំនួន ០៤ បានរៀបចំរួចរាល់ (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ) និងក្រសួងចំនួន ១៥ទៀត បាន និងកំពុងរៀបចំ ។

**- ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានរៀបចំកិច្ចការមួយចំនួនសម្រាប់គាំទ្រដល់ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ៖

- ការរៀបចំ និងដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពី ការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សេចក្ដីណែនាំស្ដីពី ការពង្រឹងការគ្រប់គ្រង និង

ចាត់ចែងមន្ត្រី-បុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសេចក្តីណែនាំស្តីពី នីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ ។

- ការរៀបចំវគ្គបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ អំពីភាពជាអ្នកដឹកនាំសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ០៩វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣៧៧រូប ស្រី ១០រូប វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់គ្រូបង្គោលថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន ១២វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣០៥រូប ស្រី ៦៣រូប និងវគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីពី មុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជូនដល់មន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៩៧វគ្គ មានសិក្ខាកាមចូលរួមចំនួន ៥.៧៦២រូប ស្រី ១.៤៣៦រូប។

**- ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រសួងមហាផ្ទៃបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យ កែសម្រួលប្រព័ន្ធចែករំលែកធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង ស្រុកឡើងវិញ។ ដោយផ្អែកលើមូលដ្ឋានដែលបានឯកភាពគ្នា ការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវបានកើនឡើង ៤% និងរដ្ឋបាលឃុំ សង្កាត់ កើនឡើង ៤,៥% ចាប់ពីឆ្នាំ២០២០ តទៅ និងបន្តកើនឡើងក្នុងអត្រា ០,៥% ក្នុងមួយឆ្នាំៗជាបន្តបន្ទាប់ទៀត ។

វឌ្ឍនភាពនៃការរៀបចំ និងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ៖

-ក្រសួងមហាផ្ទៃបានផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍសម្រាប់ជាគុណប្រយោជន៍រាជធានី ខេត្ត ចំនួន ២៦៨គម្រោង ទឹកប្រាក់ ៣៩៧.៨០៦.៩៨១.២៦០រៀល សមមូល ៩៩.៤៥១.៧៤៥ដុល្លារ ។ គម្រោងទាំងនេះ ភាគច្រើនផ្តោតសំខាន់ទៅលើការសាងសង់អគាររដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជា ៖ ស្ពាន ផ្លូវថ្នល់ សួនច្បារសាធារណៈ បណ្តាញអគ្គិសនីបំភ្លឺសាធារណៈ និងសំណង់សិល្បការនានា ...។

-គម្រោងមូលនិធិក្រុង ស្រុក ដែលបានគ្រោងឡើងក្នុងឆ្នាំ២០២០ មានចំនួន ៥១១គម្រោង ក្នុងនោះ គម្រោងបានដាក់ឱ្យដេញថ្លៃរួចចំនួន ៤៦២គម្រោង(បានចុះកិច្ចសន្យាសាងសង់ ៤៥៤គម្រោង) បញ្ចប់ការសិក្សា ២៥គម្រោង កំពុងសិក្សា ០៩គម្រោង និងមិនទាន់សិក្សាចំនួន ១៥គម្រោង ។ ដោយឡែក គម្រោងមូលនិធិក្រុង ស្រុក ដែលបានគ្រោងឡើងក្នុងឆ្នាំ២០១៩ ចំនួន ៥៣៥គម្រោង មកទល់ពេលនេះ គម្រោងបានដាក់ឱ្យដេញថ្លៃរួចចំនួន ៥០០គម្រោង (បានចុះកិច្ចសន្យាសាងសង់ ៤៩៩គម្រោង) បញ្ចប់ការសិក្សា ០៦គម្រោង កំពុងសិក្សា ០៤គម្រោង និងមិនទាន់សិក្សាចំនួន ២៥គម្រោង ។ ក្រៅពីការអនុវត្តគម្រោងមូលនិធិខាងលើនេះ រដ្ឋបាលក្រុង ស្រុក ក៏បានអនុវត្តគម្រោងនានាជាច្រើនទៀត ក្រោមការទទួលហិរញ្ញប្បទានផ្សេងទៀតពីថវិការដ្ឋផងដែរ ។

-មូលនិធិឃុំ សង្កាត់ដែលបានផ្ទេរពីថ្នាក់ជាតិមានចំនួន ៦០៧.៣៨៦លានរៀល។ មូលនិធិនេះ ត្រូវបានបែងចែកជា ០២សមាសភាព គឺសមាសភាពរដ្ឋបាលចំនួន ៣៤៧.១៤០លានរៀល និងសមាសភាពអភិវឌ្ឍមូលដ្ឋានចំនួន ២៦០.២៤៦លានរៀល។ ក្នុងសមាសភាពអភិវឌ្ឍមូលដ្ឋាន ឃុំ សង្កាត់បានរៀបចំសំណើគម្រោងឆ្នាំ២០២០ ចំនួន ២.០៤២គម្រោង ក្នុងនោះគម្រោងបានដាក់ឱ្យដេញថ្លៃរួចចំនួន ១.៨៧១គម្រោង (បានចុះកិច្ចសន្យាសាងសង់ ១.៧៨៨គម្រោង) បញ្ចប់ការសិក្សា ១៣០គម្រោង កំពុងសិក្សា ០៥គម្រោង និងមិនទាន់សិក្សាចំនួន ០៦គម្រោង ។ ដោយឡែក សម្រាប់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ បានគ្រោងឡើងចំនួន

១.៨០៧គម្រោង ក្នុងនោះ បានចុះកិច្ចសន្យាសាងសង់រួច ១.៧៩៥គម្រោង (បញ្ចប់ជាស្ថាពរ ១.៧៧១គម្រោង កំពុងអនុវត្ត ២៣គម្រោង មិនទាន់អនុវត្ត ០១គម្រោង) រីឯ ១២គម្រោងទៀត ត្រូវបានផ្អាកជាបណ្តោះអាសន្ន ។

**- ការរៀបចំ និងគាំទ្រយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានរៀបចំពិធីសម្ពោធ និងប្រកាសដាក់ឱ្យដំណើរការនូវអង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្ត ព្រមទាំងបានរៀបចំកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងសៀវភៅណែនាំសម្រាប់ជួយគាំទ្រដល់ការដាក់ឱ្យប្រើប្រាស់កម្មវិធីនេះ។ ទន្ទឹមនេះ អនុលោមតាមស្មារតីអនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃបានរៀបចំបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយនៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង ២០៣ ។ ដើម្បីឆ្លើយតបនឹងតម្រូវការនៃការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ក្រសួងមហាផ្ទៃបានផ្តល់ការគាំទ្របច្ចេកទេស និងផ្តល់វគ្គបណ្តុះបណ្តាលចាំបាច់មួយចំនួនដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃការិយាល័យច្រកចេញចូលតែមួយ ក្នុងនោះរួមមាន ៖ ការបណ្តុះបណ្តាលស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ការិយាល័យច្រកចេញចូលតែមួយ បច្ចេកទេសនៃការផ្តល់សេវាតាមវិស័យជំនាញនីមួយៗ និងការបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ (MIS) ។ ក្រសួងក៏បានដាក់ចេញសេចក្តីណែនាំស្តីពី ការពង្រឹងការគ្រប់គ្រងការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយពីការធ្វើសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ផងដែរ ។

ជារួមក្នុងរយៈពេល ០១ឆ្នាំនេះ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង ២៥ បានផ្តល់សេវារដ្ឋបាលចំនួន ៥០៨.០៧៥សេវា លើ ១៤វិស័យ ជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងទទួលបានចំណូលចំនួន ៧៦.២៣២.៧៣៤.៩៥២រៀល សមមូល ១៩.០៥៨.១៨៤ដុល្លារ ។ ដោយឡែក ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌចំនួន ១១៤គោលដៅ បានផ្តល់សេវារដ្ឋបាលចំនួន ១.៧៥៧.១៤២ សេវា លើ ១៤វិស័យ និងទទួលបានចំណូលចំនួន ១៦.៣០៨.៩៣៥.២២៦រៀល សមមូល ៤.០៧៧.២៣៤ដុល្លារ ។

**ខ-ការសម្របសម្រួល និងសហការអនុវត្តគម្រោងដោយឡែកនានា**

នៅក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃ រួមជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប បានបន្តសហការជាមួយដៃគូអភិវឌ្ឍមួយចំនួន សម្រាប់គាំទ្រគម្រោងអភិវឌ្ឍនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរួមមាន ៖

**-គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ** (LEAP)៖ ក្នុងឆ្នាំ២០២០ មានថវិកាសរុបចំនួន ៧.១២១.០៦៤ ដុល្លារ ក្នុងនោះ ចំណាយថវិកាអស់ ៤.៤៤៨.៦៣១ដុល្លារ ស្មើ ៦២% ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន ៖ បានបង្កើត និងពង្រឹងសមត្ថភាពក្រុមជួយខ្លួនឯងចំនួន ៧៨៤ក្រុម (ក្នុងនោះបានទទួលទុនវិនិយោគលក្ខណៈគ្រួសារ ៦១៤.៤០០ដុល្លារ និងទុនសន្សំ ៣២០.៩០៤ដុល្លារ) បានបង្កើតក្រុមផលិតចំនួន ១២១ក្រុម បានបណ្តុះបណ្តាលជំនាញដល់កូននៃគ្រួសារក្រីក្រចំនួន ៥៧៦នាក់ និងបានកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចចំនួន ៦៨គម្រោង មានដូចជា ផ្លូវចាក់បេតុង ផ្លូវលំ ស្ពានបេតុងខ្នាតតូច ធារាសាស្ត្រខ្នាតតូច ...។

**-គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចជំហានទី២** (TSSD-AF)៖ គម្រោងនេះ មានរយៈពេល ០៥ឆ្នាំ(២០១៨-២០២៣) និងអនុវត្តនៅខេត្តគោលដៅចំនួន ០៧ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង គ្របដណ្តប់លើក្រុង ស្រុកចំនួន ៣៧ និងឃុំ សង្កាត់ចំនួន ២[illegible]០។ ក្នុងឆ្នាំ២០២០ គ្រោងថវិកាសរុបចំនួន ៨៣.២៦១លានរៀល (ចំណាយថវិកាអស់ ១០.៩៣៥លានរៀល) ។

**-គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់ទី២** (LASED II) ៖ គម្រោងនេះ មានរយៈពេល ០៥ឆ្នាំ(២០១៦-២០២១) និងអនុវត្តនៅខេត្តគោលដៅចំនួន ០៥ គឺខេត្តក្រចេះ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ និងខេត្តត្បូងឃ្មុំ ។ ក្នុងឆ្នាំ២០២០ គ្រោងថវិកាចំនួន ១.២៤១លានរៀល (ចំណាយថវិកាអស់ ៧៥៤លានរៀល) លទ្ធផលសំខាន់ៗ ដែលសម្រេចបាន រួមមាន សាងសង់ផ្លូវសហគមន៍បានចំនួន ០៣គម្រោង ប៉ុស្តិ៍សុខភាពចំនួន ០១គម្រោង ផ្លូវក្រាលក្រួសក្រហមចំនួន ០៤គម្រោង និងសាងសង់លូ-ប្រឡាយបានចំនួន ០៥គម្រោង ។

**-គម្រោងលើកកម្ពស់សេវាសង្គម ឬកម្មវិធីសិទ្ធិកុមាររបស់អង្គការ** UNICEF៖ ក្នុងឆ្នាំ២០២០ គ្រោងថវិកាចំនួន ៤៧៦.៧៥៩ដុល្លារ(ចំណាយថវិកាអស់ ៤៣៤.៨២១ដុល្លារ) លទ្ធផលសំខាន់ៗដែលសម្រេចបាន រួមមាន បានកែសម្រួលប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ក.ន.ក កែសម្រួល និងបំពេញបន្ថែមនីតិវិធីនៃការរៀបចំផែនការវិនិយោគបីឆ្នាំរំកិល រៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពី កម្មវិធីពានរង្វាន់សេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញបង្វឹកដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តគោលដៅ វគ្គបណ្តុះបណ្តាលស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងវគ្គបណ្តុះបណ្តាលស្តីពី ការគូសផែនទីសេវាសង្គម ជំរុញការដាក់បញ្ចូលសកម្មភាពសេវាសង្គមទៅក្នុងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំដាក់ឱ្យប្រើប្រាស់សាកល្បងនូវទម្រង់ថវិកាសង្ខេបរបស់ឃុំ សង្កាត់ និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកាឃុំ សង្កាត់ ។

**-គម្រោងកសាងសមត្ថភាព កសាងសន្តិភាព និងការសន្ទនាប្រកបដោយបរិយាប័ន្នរបស់** UNDP ៖ គម្រោងនេះ មានរយៈពេល ០៣ឆ្នាំ(២០២០-២០២៣) ដោយមានការគាំទ្រថវិកាពីរដ្ឋាភិបាលជប៉ុន ហើយបច្ចុប្បន្ន បាន និងកំពុងជួយអភិវឌ្ឍសមត្ថភាពបន្ថែមដល់មន្ត្រីសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអង្គការសង្គមស៊ីវិលនានា ដើម្បីលើកកម្ពស់ភាពជាដៃគូរវាងមន្ត្រីរាជការ និងអង្គការសង្គមស៊ីវិល ។ ទន្ទឹមនេះ គម្រោងក៏ផ្តល់ការគាំទ្រ និងពង្រឹងគុណភាពនៃការរៀបចំវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលរាជធានី ខេត្ត និងអង្គការសង្គមស៊ីវិល ឱ្យកាន់តែប្រសើរឡើង ផងដែរ ។

**-គម្រោងលើកកម្ពស់សេវាគណនេយ្យភាពសង្គមផ្នែកតម្រូវការ** (CSOs) ៖ ក្នុងឆ្នាំ២០២០ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយអង្គការនានា គម្រោងមានថវិកាសរុប ២២.៤០៨លានរៀល ។ គម្រោងនេះ អនុវត្តនៅរាជធានី ខេត្តគោលដៅចំនួន ២៣ គ្របដណ្តប់លើរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ១៣៧ ឃុំ សង្កាត់ចំនួន ១.០៣៤ សាលាបឋមសិក្សាចំនួន ៣.០៩២ និងមណ្ឌលសុខភាពចំនួន ៨០៦។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ គម្រោងបានចំណាយថវិកាចំនួន ៤.៤០៩លានរៀល ។

**-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់** (DCOCP)៖ មានថវិកាសរុប ១០លានដុល្លារ ក្រោមក្របខ័ណ្ឌមូលនិធិទ្រទ្រង់ថវិកាឆ្នាំ២០១៦-២០១៩ ពីធនាគារអភិវឌ្ឍន៍អាស៊ី ADB សម្រាប់គាំទ្រការកសាងអគាររដ្ឋបាល និងអគារសាលប្រជុំសាលាស្រុកចំនួន ០៧ និងអគាររដ្ឋបាលឃុំ សង្កាត់ចំនួន ១៥០។ មកទល់ពេលនេះ គម្រោងបានដំណើរការសាងសង់នៅស្រុកចំនួន ០៧ និងឃុំ សង្កាត់ចំនួន ១៣៥ ស្មើនឹង ៩០% ។

### គ-ការងារជំនាញផ្សេងទៀត

#### - ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារសរុបចំនួន ៨២ ក្នុងនោះច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ ។

ដើម្បីពង្រឹងយន្តការសហប្រតិបត្តិការក្នុងការគ្រប់គ្រងច្រកទ្វារព្រំដែន ក្រសួងមហាផ្ទៃ បាន និងកំពុងសហការជាមួយភាគីវៀតណាម ពិនិត្យ សិក្សារៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី ការគ្រប់គ្រងច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម ព្រមទាំងកំពុងសហការជាមួយភាគីថៃ សិក្សារៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី ការសាងសង់ស្ពានឆ្លងកាត់អូរធម្មជាតិនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំផងដែរ ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃបានដឹកនាំគណៈកម្មការអន្តរក្រសួង ធ្វើការសាងសង់ច្រាំងទន្លេបាសាក់ និងព្រែកជ្រៃធំ ដើម្បីការពារការបាក់ច្រាំង និងបង្គោលព្រំដែនលេខ ២៤៥/៤ និង ២៤៦/២ ព្រមទាំងសមិទ្ធផលនានាដែលមានក្នុងបរិវេណនោះផងដែរ ។

គិតពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋបានចំនួន ០៣ប័ណ្ណ និងព្រំដែនកម្ពុជា-ថៃបានចំនួន ៣៥.៤៦៧ប័ណ្ណ ព្រមទាំងបានបន្តសុពលភាពប័ណ្ណព្រំដែនចំនួន ១៧១ប័ណ្ណ ។

**- ការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ក្រុង នៃបណ្តាប្រទេសនានា**

ក្នុងរយៈពេល ០១ឆ្នាំ កន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) និងចុះកិច្ចព្រមព្រៀងស្តីពីការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ក្រុង នៃបណ្តាប្រទេសមួយចំនួន ដូចជា រដ្ឋបាលរាជធានីភ្នំពេញ ជាមួយខេត្តហ៊្វូជៀន នៃប្រទេសចិន និងក្រុងណូវ៉ូស៊ីប៊ីស នៃប្រទេសរុស្ស៊ី ខេត្តបាត់ដំបង ជាមួយមូលនិធិទីក្រុងឆ្លាតអាស៊ាន-អូស្ត្រាលី ក្រោមគម្រោង ADB (សម្រាប់អនុវត្តនៅក្រុងបាត់ដំបង) និងរដ្ឋបាលក្រុងសៀមរាប ជាមួយក្រុងតាចុង និងក្រុងស៊ីអាន ខេត្តសានស៊ី នៃប្រទេសចិន ។

**- ការផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្រសួងមហាផ្ទៃ បានគោរពស្នើសុំរាជរដ្ឋាភិបាលផ្តល់គោរមងារជាឧកញ៉ាចំនួន ២៥រូប និងផ្តល់គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិសរុបចំនួន ៩២១គ្រឿង ដើម្បីសម្តែងនូវការដឹងគុណ និងលើកទឹកចិត្តដល់សប្បុរសជនទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយថវិកាផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផលនានានៅមូលដ្ឋាន សរុបជាទឹកប្រាក់ចំនួន ៣៥.៧៨៣.៩៥៩ដុល្លារ និង ១.៧៤៩.១៤៧.០០០រៀល ។

**២.៣-ការងារគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច**

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ នេះ គណបក្សនយោបាយមានចំនួនសរុប ៤៧គណបក្ស ក្នុងនោះគណបក្សនយោបាយមិនទាន់ចុះបញ្ជីចំនួន ០១គណបក្ស។ ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យបង្កើតគណបក្សនយោបាយចំនួន ០១គណបក្ស ចុះក្នុងបញ្ជីគណបក្សចំនួន ០៣គណបក្ស និងសម្រេចលុបឈ្មោះចេញពីបញ្ជីគណបក្សចំនួន ០១គណបក្ស ។

ដោយឡែក សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួន ៥.៩២០(សមាគម ២.៣៨៥ អង្គការមិនមែនរដ្ឋាភិបាល ៣.៣៨៣ និងសហគមន៍ជនជាតិដើមភាគតិច ១៥២) ។ <u>កត់សម្គាល់៖</u> នៅក្នុងរយៈពេល ០១ឆ្នាំនេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច ចំនួន ២៣៨ (សមាគម ១៤៨ អង្គការមិនមែនរដ្ឋាភិបាល ៨១ និងសហគមន៍ ០៩) និងសម្រេចលុបឈ្មោះចេញពីបញ្ជីចំនួន ២៧ (សមាគម ១២ និងអង្គការមិនមែនរដ្ឋាភិបាល ១៥)។ ទន្ទឹមនេះ ក្រសួងបានរៀបចំវេទិកាស្តីពី ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលចំនួន ០១លើក ក្នុងគោលបំណងពិនិត្យឡើងវិញនូវស្ថានភាពនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ព្រមទាំងកំណត់នូវបញ្ហាប្រឈមនានាដែលបានជួបប្រទះនាពេលកន្លងមក ក្នុងនោះក៏បានឯកភាពបំពេញបន្ថែមនូវសមាសភាពក្រុមការងាររបស់រាជរដ្ឋាភិបាលចំនួន ០៦ក្រសួង-ស្ថាប័ន

ដើម្បីជួយសម្របសម្រួលដោះស្រាយសំណើ សំណូមពររបស់អង្គការសង្គមស៊ីវិល សំដៅលើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយអង្គការសង្គមស៊ីវិល។ ជាមួយគ្នានេះ ក្រសួងក៏បានរៀបចំកិច្ចប្រជុំជាមួយតំណាងអង្គការសង្គមស៊ីវិលចំនួន ០៦លើក ដើម្បីពិនិត្យពិភាក្សាលើសំណើសុំកែសម្រួលមាត្រាចំនួន ១៤មាត្រា នៃច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ផងដែរ ។

### ២.៤-ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

#### ក-សភាពការណ៍អន្តរជាតិ ដែលពាក់ព័ន្ធដល់សន្តិសុខជាតិ

ឆ្នាំ២០២០ ពិភពលោកទាំងមូលបានជួបប្រឈមយ៉ាងធ្ងន់ធ្ងរនូវវិបត្តិសុខភាពសាធារណៈ ដោយសារការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដែលបានបង្កឱ្យមានអ្នកឆ្លង និងស្លាប់រាប់សិបលាននាក់ និងជះឥទ្ធិពលអវិជ្ជមានដល់នយោបាយ-សេដ្ឋកិច្ច-សន្តិសុខសកល ខណៈដែលបញ្ហាប្រឈមជាច្រើនពុំទាន់រកឃើញច្រកចេញនៅឡើយ ធ្វើឱ្យសភាពការណ៍នយោបាយ សេដ្ឋកិច្ចសង្គម សន្តិសុខជាទូទៅ កាន់តែធ្លាក់ក្នុងស្ថានភាពស្មុគស្មាញ និងគួរឱ្យព្រួយបារម្ភ ក្នុងនោះ អធិករណ៍ដែលមានហានិភ័យគំរាមកំហែងខ្ពស់ គឺវិវាទនៃកិច្ចព្រមព្រៀងអាវុធនុយក្លេអ៊ែរ សង្គ្រាមពាណិជ្ជកម្ម ជម្លោះទឹកដី ដែនកោះ និងដែនសមុទ្រ អំពើភេរវកម្មអន្តរជាតិ សង្គ្រាមស៊ីវិល និងការប្រជែងឧត្តមភាពយោធារវាងមហាអំណាច ដើម្បីពង្រីកឥទ្ធិពលគ្រប់គ្រងភូមិសាស្ត្រនយោបាយ ការទូត និងសេដ្ឋកិច្ច...។

#### ខ-ការចាត់តាំង អនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព

រយៈពេល ០១ឆ្នាំ កន្លងទៅនេះ ថ្វីបើកម្ពុជា បាន និងកំពុងតស៊ូយ៉ាងស្វិតស្វាញក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ក្តី ក៏គោលនយោបាយ"**ភូមិ ឃុំ មានសុវត្ថិភាព**" នៅតែត្រូវបានបន្តជំរុញខ្លាំងក្លា ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ដើម្បីធានាឱ្យសហគមន៍ ភូមិ ឃុំ សង្កាត់ ទទួលបាននូវសុខសន្តិភាព សុវត្ថិភាព និងមានសណ្តាប់ធ្នាប់ល្អ ព្រមទាំងចូលរួមជួយសង្គ្រោះប្រជាពលរដ្ឋទាន់ពេលវេលា ក្នុងកាលៈទេសៈនៃវិបត្តិខាងលើនេះ ។ ជាក់ស្តែង វឌ្ឍនភាពនៃដំណើរការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" ក្នុងឆ្នាំ២០២០ រួមមានជាអាទិ៍ ៖

-ខ្លឹមសារលក្ខណសម្បត្តិទាំង ០៩ចំណុច របស់គោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" ក៏ដូចជាបទបញ្ជារបស់រាជរដ្ឋាភិបាល និងវិធានការនានាក្នុងការបង្ការ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយយ៉ាងសកម្មផុលផុស និងទូលំទូលាយបញ្ជ្រាបដល់សាធារណជនគ្រប់មជ្ឈដ្ឋាន ដែលប្រៀបធៀបនឹងឆ្នាំមុន សកម្មភាពផ្សព្វផ្សាយបានកើនឡើងដល់ ១៧% (១៧១.១១២/១៤៦.២៣៤លើក) និងអ្នកចូលរួម កើនឡើង ១៤% (៩.២៩៥.៩៥០/៨.១០៥.០០៦នាក់) ។

-ទោះបីការរៀបចំវេទិកាសាធារណៈមានការថយចុះ ៦% (៧៣.៦០៣/៧៨.៨៨៣លើក) អាស្រ័យដោយការអនុវត្តវិធានសុខាភិបាល និងភាពមមាញឹករបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានក្តី ក៏រាល់សំណូមពរ មតិយោបល់ និងទុក្ខកង្វល់នានារបស់ប្រជាពលរដ្ឋ នៅតែត្រូវបានប្រមូលយកមកពិនិត្យ ដោះស្រាយ និងឆ្លើយតបជាបន្តបន្ទាប់ តាមរយៈប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម ហើយយន្តការនេះ កំពុងទទួលបានការគាំទ្រខ្លាំងពីគ្រប់មជ្ឈដ្ឋាន និងកំពុងក្លាយជាផ្នែកមួយយ៉ាងសំខាន់នៃយន្តការវេទិកាសាធារណៈ ។

-ការងាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល តាមរបត់ថ្មី"**ការងារនគរបាល និងសហគមន៍**" បានពង្រឹងភាពជាដៃគូកាន់តែជិតស្និទ្ធរវាងមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដែលកត្តាទាំងនេះ បានក្លាយជាចលករជំរុញចលនាអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" កាន់តែមានភាពរស់រវើកថែមទៀត ។

-ថ្វីបើចំនួនប្រជាការពារនៅតាមរាជធានី ខេត្ត ថយចុះ ៣% (ចំនួនក្រុមប្រជាការពារថយចុះ ២%) ប៉ុន្តែប្រជាការពារនៅតែជាកម្លាំងជំនួយដ៏សំខាន់ក្នុងការរួមចំណែកជំរុញប្រសិទ្ធភាពការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" ក្នុងនោះ បានជួយរំលែកបន្ទុកការងារជាច្រើនរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល ទាំងលើការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយតាមទីប្រជុំជន សាលារៀន និងពិធីផ្សេងៗនៅក្នុងសហគមន៍ ជាពិសេសការចូលរួមល្បាតយាមកាមនៅតាមសហគមន៍ ភូមិ ឃុំ របស់ខ្លួន ។

តាមរយៈការវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" ក្រុមប្រឹក្សាប្រឡងប្រណាំងក្រសួងមហាផ្ទៃ បានរកឃើញ និងកំណត់ចំណាត់ថ្នាក់ឃុំ សង្កាត់ទាំង ១.៦៤៦ ដូចតទៅ ៖ ចំណាត់ថ្នាក់លេខ១ មាន ១.១៦១ឃុំ-សង្កាត់ ស្មើ ៧០,៥៣% លេខ២ មាន ៤២៧ឃុំ-សង្កាត់ ស្មើ ២៥,៩៥% លេខ៣ មាន ៥៤ឃុំ-សង្កាត់ ស្មើ ៣,២៨% និងគ្មានចំណាត់ថ្នាក់មាន ០៤ឃុំ-សង្កាត់ ស្មើ ០,២៤% ។

ដោយផ្អែកលើលទ្ធផល បទពិសោធន៍ និងស្ថានភាពជាក់ស្តែង ក្រសួងមហាផ្ទៃបានធ្វើបច្ចុប្បន្នភាពលក្ខណសម្បត្តិគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ឡើងវិញ ព្រមទាំងដំឡើងកម្រិតជាគោលនយោបាយរាជរដ្ឋាភិបាលស្តីពី "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" ដែលមានលក្ខណសម្បត្តិចំនួន ០៧ចំណុច គ្របដណ្តប់លើវិស័យសំខាន់ៗពាក់ព័ន្ធដល់ការបម្រើសេវាជូនប្រជាពលរដ្ឋ ការធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាអនាម័យ និងបរិស្ថាន និងដំណោះស្រាយជម្រោះក្រៅប្រព័ន្ធតុលាការ ។

### គ-អំពីការងាររក្សាសន្តិសុខជាតិ

ទោះបីក្នុងឆ្នាំ២០២០ កម្ពុជាបានឆ្លងកាត់កាលៈទេសៈដ៏លំបាកស្មុគស្មាញ បណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ គ្រោះធម្មជាតិ និងការវិវត្តប្រែប្រួលនៃសភាពការណ៍នយោបាយ សេដ្ឋកិច្ច និងសន្តិសុខរបស់ពិភពលោក ព្រមទាំងប្រឈមនឹងការប៉ុនប៉ងបង្កភាពចលាចលវឹកវរក្នុងសង្គម បំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុងជាតិ តាមរបៀបបដិវត្តន៍ពណ៌ពីសំណាក់ក្រុមឧទ្ទាមក្រៅច្បាប់ទាំងក្នុង និងក្រៅប្រទេសក្តី ក៏ប៉ុន្តែតាមរយៈការចាត់វិធានការដែលមានលក្ខណៈជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដោយមានកងកម្លាំងនគរបាលជាតិជាស្នូលក្នុងការជំរុញអនុវត្តទាំងវិធានការជំនាញ វិធានការអប់រំ និងវិធានការច្បាប់មឹងម៉ាត់ ធ្វើឱ្យសភាពការណ៍សន្តិសុខជាតិជាទូទៅនៅតែមានលក្ខណៈល្អប្រសើរ ។ ជាក់ស្តែង ក្នុងរយៈពេល ០១ឆ្នាំនេះ ៖

-បញ្ចៀសបាននូវហានិភ័យដែលបង្កឡើងដោយអំពើភេរវកម្ម ខណៈដែលប្រទេសចំនួន ៤៣ កំពុងទទួលរងនូវការវាយប្រហារដោយអំពើភេរវកម្មយ៉ាងធ្ងន់ធ្ងរ និងសាហាវយង់ឃ្នងចំនួន ១.១០៨លើក ។

-ព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនានា កម្មវិធីបុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍នយោបាយ សរុបប្រមាណជាង ១០.៣២០លើក រួមទាំងគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ វិនិយោគ និងទេសចរណ៍ ត្រូវបានការពារប្រកបដោយសុវត្ថិភាព ។

-សកម្មភាពបាតុកម្ម និងកូដកម្មគ្រប់រូបភាពប្រមាណ ១.០៣២លើក ត្រូវបានគ្រប់គ្រងស្ថានភាពការណ៍ ចាត់វិធានការតាមគោលការណ៍នីតិរដ្ឋ និងសម្របសម្រួលដោះស្រាយប្រកបដោយជោគជ័យ ។

-រាល់ព័ត៌មានប្រឌិតបំភ្លៃសភាពការណ៍ បំពុលបរិយាកាសសង្គម ត្រូវបានស្រាវជ្រាវ និងឆ្លើយតបឬស្រាយបំភ្លឺទាន់ពេលវេលា ព្រមទាំងបានអនុវត្តវិធានការច្បាប់តឹងរ៉ឹង ដោយធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន [illegible]នាក់ ពីបទពាក់ព័ន្ធនឹងការចូលរួមផ្សព្វផ្សាយព័ត៌មានក្លែងក្លាយបម្រើឧបាយកលពួកឧទ្ទាមក្រៅច្បាប់ ចំនួន [illegible]នាក់ ពីបទប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមញុះញង់បង្កឱ្យមានភាពចលាចលវឹកវរ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម

សេចក្ដីថ្លៃថ្នូររបស់សមត្ថកិច្ច និងប៉ះពាល់កិត្តិយសថ្នាក់ដឹកនាំជាតិ ចំនួន ១៨នាក់ ពីបទផ្សព្វផ្សាយលក់ផលិតផលប្រឆាំងវីរុសកូវីដ-១៩ តាមអនឡាញខុសច្បាប់... ។

**ឃ-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស**

-បទល្មើសព្រហ្មទណ្ឌកើតឡើង ៣.២៥៤/៣.១៩៦លើក កើន ៥៨លើក (ឧក្រិដ្ឋ ៦៨២/៧០១លើក ថយ ១៩លើក និងមជ្ឈិម ២.៥៧២/២.៤៩៥លើក កើន ៧៧លើក) ស្លាប់ ២២៨/២១១នាក់ របួស ១.០២៩/៨២៩នាក់ រងគ្រោះ ៧៤៤/១.៤១២នាក់ បាត់រថយន្ត ២៥គ្រឿង ម៉ូតូ ៣៧៥គ្រឿង និងសម្ភារៈ មាសប្រាក់មួយចំនួន។ បើកកិច្ចប្រតិបត្តិការបង្ក្រាបបាន ២.៩៤០ករណី ស្មើ ៩០% នៃបទល្មើសដែលកើតឡើង ឃាត់ខ្លួនជនល្មើសបាន ៤.២៧៦នាក់ (ឧក្រិដ្ឋ ៥៩៣ករណី ស្មើ ៩០៥នាក់ និងមជ្ឈិម ២.៣៤៧ករណី ស្មើ ៣.៣៧១នាក់) ក្នុងចំណោមជនសង្ស័យទាំងនេះ មាន ១.៥៦៧នាក់ ជាប់ពាក់ព័ន្ធប្រើប្រាស់សារធាតុញៀន ។ ដោយឡែក អនុវត្តដីកាឃាត់ខ្លួនជនសង្ស័យបាន ៧៣នាក់/៧២ដីកា ។ វត្ថុតាង និងជនល្មើស ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត អនុវត្តតាមនីតិវិធីច្បាប់ ។ <u>**កត់សម្គាល់៖**</u> បទល្មើសដែលទាញតួលេខឱ្យមានកំណើន រួមមាន លួចមានស្ថានទម្ងន់ បង្ខាំងមនុស្សជំរិតយកប្រាក់ បង្ខាំងមនុស្សខុសច្បាប់ មនុស្សឃាតអចេតនា អំពើហិង្សា អំពើហិង្សាក្នុងគ្រួសារ និងប្រើអាវុធខុសច្បាប់ ។

-បង្ក្រាបបទល្មើសគ្រឿងញៀនបាន ៨.៨៦០ករណី ឃាត់ខ្លួន ១៧.៨៤៥នាក់ ស្រី ១.០៤៥នាក់ ក្នុងនោះ ជនបរទេស ២៩៨នាក់/១៧សញ្ជាតិ រឹបអូសបានសារធាតុញៀនសរុប ៣.២០២,៤២គ.ក្រ កញ្ឆាក្រៀម ៥៩,២៤ គ.ក្រ ដើមកញ្ឆា ៣៨.៨១៨ដើម សារធាតុគីមីផ្សំ ១.៤០៤,២០១គ.ក្រ អាវុធវែង ៣៧ដើម អាវុធខ្លី ៨០ដើម រថយន្ត ១១៣គ្រឿង ម៉ូតូ ២.២៣៩គ្រឿង ជញ្ជីង ៣៩៤គ្រឿង ទូរស័ព្ទដៃ ៦.០៤៨គ្រឿង និងឧបករណ៍វេចខ្ចប់គ្រឿងញៀនមួយចំនួនទៀត ។ ទន្ទឹមនេះ បានអនុវត្តដីកាបញ្ជូនទៅតុលាការ ៤៤៧ដីកា ស្មើ ៤៣៦នាក់ ស្រី ១១នាក់ ។ វត្ថុតាង និងជនល្មើស ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។

<u>**កត់សម្គាល់ ៖**</u> ក្នុងចំណោមករណីបង្ក្រាបបានខាងលើ មាន ៦៣ករណី ស្មើ ៦៣ក្រុម មនុស្ស ១២៥នាក់ (មេក្លោង ២៤នាក់) ជាក្រុមដែលមានខ្សែបណ្ដាញចាត់តាំងច្បាស់លាស់ ។

-បង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបាន ១៤១ករណី ឃាត់ខ្លួន ១៧១នាក់ ស្រី ៣០នាក់ ក្នុងនោះ ជនបរទេស ១៤នាក់ កសាងសំណុំរឿងបញ្ជូនទៅតុលាការ និងរំដោះជនរងគ្រោះបាន ៥១៥នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១០៧នាក់ អង្គការ ០១នាក់ និងបញ្ជូនទៅអាណាព្យាបាលវិញ ៤០៧នាក់) ។

-បង្ក្រាបក្មេងទំនើងបាន ១.៤៩៥ករណី ឃាត់ខ្លួន ៣.១៧៩នាក់ ស្រី ៩៥នាក់ ក្នុងនោះ អនុវត្តវិធានការច្បាប់ ៧១៩ករណី ស្មើ ១.០៨៣នាក់ ស្រី ៤១នាក់ (ពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ ៣៨៨ករណី/៥៦៨នាក់ ស្រី ២២នាក់ និងពាក់ព័ន្ធគ្រឿងញៀន ៣៣១ករណី/៥១៥នាក់ ស្រី ១៩នាក់) កសាងសំណុំរឿងបញ្ជូនទៅតុលាការ និងអនុវត្តវិធានការរដ្ឋបាល (ធ្វើកិច្ចសន្យាអប់រំ) ៧៧៦ករណី ស្មើ ២.០៩៦នាក់ ស្រី ៥៤នាក់ ។

-បង្ក្រាបល្បែងស៊ីសងបាន ១.២៩២ករណី ឃាត់ខ្លួន ៣.២៦២នាក់ ស្រី ១.៣០០នាក់ រួមទាំងវត្ថុតាងមួយចំនួន ក្នុងនោះ បញ្ជូនទៅតុលាការ ២០១ករណី ស្មើ ៦៣២នាក់ ស្រី ១៥៤នាក់ និងអនុវត្តវិធានការរដ្ឋបាលធ្វើកិច្ចសន្យាអប់រំ ១.០៩១ករណី ស្មើ ២.៦៣០នាក់ ស្រី ១.១៤៦នាក់ ។

-បង្ក្រាបបទល្មើសសេដ្ឋកិច្ចបាន ៣៤៣លើក(ម្ចាស់ការបង្ក្រាប ៣៣លើក) ឃាត់ខ្លួន ១០៨នាក់ ក្នុងនោះ បញ្ជូនទៅតុលាការ ២៦នាក់ ក្រៅពីនេះ បញ្ជូនទៅស្ថាប័នជំនាញពាក់ព័ន្ធ។ បទល្មើសដែលបង្ក្រាបបានភាគច្រើន

ពាក់ព័ន្ធនឹងការនាំចូលទំនិញគេចពន្ធ អាហារខូចគុណភាព បទល្មើសព្រៃឈើ បទល្មើសជលផល កម្មសិទ្ធិបញ្ញា ឱសថក្លែងក្លាយ...។

**ខ-សភាពការណ៍ និងកិច្ចប្រតិបត្តិការរក្សាសណ្តាប់ធ្នាប់សាធារណៈ**

ក្នុងឆ្នាំ២០២០ គ្រោះថ្នាក់សង្គមកើតឡើងសរុប ៧.៨១៨/៨.២១៩លើក ស្លាប់ ៤.៨២៤/៤.៦៨០នាក់ របួស ៥.៧៩៦/៧.០៥៤នាក់ ក្នុងនោះ គ្រោះថ្នាក់ចរាចរណ៍ ៣.១៧៩/៤.១២១លើក (ស្លាប់ ១.៦៤៦/១.៩៨១ នាក់ របួស ៤.៦៨៦/៦.១៤១នាក់) អាវុធជាតិផ្ទុះ ៤២លើក (ស្លាប់ ១៦នាក់ របួស ៤១នាក់) អគ្គិភ័យ ៩៣៧ លើក (ស្លាប់ ២៤នាក់ របួស ៣៦នាក់ ឆេះផ្ទះ ៧០៣ខ្នង តូប ៥៩៤តូប) និងគ្រោះថ្នាក់ផ្សេងៗ ៣.៦៦០លើក (ស្លាប់ ៣.១៦២នាក់ របួស ១.០៧០នាក់ រលំផ្ទះ ៦៥៩ខ្នង របើកដំបូល ៤.៧៧៨ខ្នង និងខូចខាតទ្រព្យសម្បត្តិ មាស ប្រាក់ មួយចំនួន) ។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើនេះ ក្រសួងមហាផ្ទៃបានប្រមូលផ្តុំចាត់វិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះ ដូចខាងក្រោម ៖

-**ការងារចរាចរណ៍** ៖ បានយកចិត្តទុកដាក់ពង្រឹងយន្តការដឹកនាំបញ្ជា ដោយធ្វើការប្រជុំដាក់ចេញគោលការណ៍ និងចង្អុលណែនាំដល់នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីពង្រឹងប្រសិទ្ធភាពការផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ចរាចរណ៍ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការលើដងផ្លូវរបស់មន្ត្រីអនុវត្តច្បាប់ សំដៅកាត់បន្ថយបញ្ហាប្រឈម និងភាពអសកម្មនានា ដែលត្រូវបានសាធារណមតិលើកឡើង។ ជាមួយគ្នានេះ ក៏បានខិតខំជំរុញការផ្សព្វផ្សាយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងចរាចរណ៍ផ្លូវគោកឱ្យកាន់តែសស្រាក់សស្រាំតាមគ្រប់រូបភាព ដើម្បីបញ្ជ្រាបការយល់ដឹងដល់សាធារណជនគ្រប់មជ្ឈដ្ឋាន។ **<u>កត់សម្គាល់៖</u>** បានត្រួតពិនិត្យយានយន្តសរុបចំនួន ១.៧៨០.១០៤គ្រឿង ក្នុងនោះរកឃើញយានយន្តល្មើសចំនួន ៣៥៥.៨៨០គ្រឿង (រថយន្ត ១១៧.៤៤០គ្រឿង ម៉ូតូ ២៣៨.៤៤០គ្រឿង) ។

-**ការងារអគ្គិភ័យ** ៖ បានខិតខំលើកកម្ពស់សមត្ថភាពកម្លាំងប្រតិបត្តិការជួយសង្គ្រោះហេតុការណ៍អគ្គិភ័យ តាមរយៈយកចិត្តទុកដាក់ផ្តល់វគ្គបំប៉នជំនាញបច្ចេកទេសផង និងផ្គត់ផ្គង់មធ្យោបាយ ឧបករណ៍សម្ភារៈបច្ចេកទេសផង ព្រមទាំងបន្តជំរុញការផ្សព្វផ្សាយអប់រំអំពីវិធានការប្រុងប្រយ័ត្ន និងវិធីសាស្ត្របង្ការ ទប់ស្កាត់អគ្គិភ័យ ដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ជាពិសេសនៅតំបន់ដែលមានហានិភ័យខ្ពស់ ។ **<u>កត់សម្គាល់</u> ៖** ក្នុងចំណោមអគ្គិភ័យ ៩៣៧លើក មាន ៨៣០លើក ត្រូវបានក្រុមពន្លត់អគ្គិភ័យ អន្តរាគមន៍ទប់ស្កាត់ការឆេះរាលដាលបាន ក្រៅពីនេះ ត្រូវបានសមត្ថកិច្ច និងក្រុមពន្លត់អគ្គិភ័យស្ម័គ្រចិត្តនៅមូលដ្ឋាន សហការជាមួយប្រជាពលរដ្ឋ ពន្លត់ទាន់ពេល ។

-**ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ** ៖ បានយកចិត្តទុកដាក់ពង្រឹងជាប្រចាំ ទាំងលើការត្រួតពិនិត្យ ការចុះបញ្ជីគ្រប់គ្រង និងការផ្សព្វផ្សាយអប់រំ ។ ជាក់ស្តែង បានផ្តល់ប័ណ្ណប្រើប្រាស់អាវុធថ្មីចំនួន ៣.៧៦២ប័ណ្ណ(ខ្លី ២.៤៩២ ប័ណ្ណ វែង ១.២៧០ប័ណ្ណ) ប្តូរប័ណ្ណអាវុធចំនួន ៦.១៥៤ប័ណ្ណ(ខ្លី ៥.១៣៦ប័ណ្ណ វែង ១.០១៨ប័ណ្ណ) សហការដុតបំផ្លាញចោលសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន ៨.១៩៩គ្រាប់ ប្រគល់អាវុធខូចគុណភាពចំនួន ៨.០៦២ដើម ឱ្យទៅមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា និងធ្វើការផ្សព្វផ្សាយអប់រំអំពីសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន ១៥.៨៥៩លើក (មានប្រជាពលរដ្ឋចូលរួមសរុប ១.០៩៥.៩៦០នាក់ ក្នុងនោះ ប្រជាពលរដ្ឋស្ម័គ្រចិត្តប្រគល់អាវុធចំនួន ១៨១ដើម) ។

**ច-សភាពការណ៍ និងកិច្ចប្រតិបត្តិការរក្សា ការពារសន្តិសុខព្រំដែន**

ក្នុងឆ្នាំ២០២០ សភាពការណ៍សន្តិសុខនៅតាមតំបន់ព្រំដែន ជាទូទៅនៅតែមានស្ថេរភាពល្អប្រសើរ បើទោះជាកើតមានបាតុភាពមិនប្រក្រតីមួយចំនួនបង្កដោយភាគីវៀតណាម ដែលបានបោះតង់ និងសង់តោង(ឃ្លាតពី

ខ្សែបន្ទាត់ព្រំដែនពី ១៥ម៉ែត្រ ទៅ ៥០០ម៉ែត្រ) សរុប ២៩១តង់/០៩ខេត្ត ក្រោមហេតុផលដាក់ប៉ុស្តិ៍សង្កេតការណ៍ ទប់ស្កាត់កូវីដ-១៩ ក្នុងនោះសាងសង់លើទីតាំងដែលបានឯកភាពគ្នា ២៤៨តង់ (បានរុះរើចេញ ៥២តង់) និងនៅលើទីតាំងមិនបានឯកភាពគ្នា ៤៣តង់ (បានរុះរើចេញ ៣៧តង់) ។

កងកម្លាំងនគរបាលជាតិ បានសហការជាមួយកងយោធពលខេមរភូមិន្ទ រដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់ផ្នែក បន្តជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនៃប្រទេសជិតខាង ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ព្រមទាំងសម្របសម្រួល បង្កភាពងាយស្រួលដល់ការចេញចូលឆ្លងកាត់ព្រំដែនស្របច្បាប់របស់ប្រជាពលរដ្ឋទាំងសងខាង ពិសេសក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីដ-១៩ ក្នុងនោះ បានជួបប្រជុំជាមួយភាគីថៃ ៥៣៤លើក វៀតណាម ៣៣៤លើក និងឡាវ ២២លើក ។

ក្រៅពីនេះ នគរបាលការពារព្រំដែនបានបន្តចូលរួមសម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងការចុះរុករកវាស់វែង និងបោះបង្គោលព្រំដែនរបស់ក្រុមគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនកម្ពុជា ថៃ និងក្រុមគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនកម្ពុជា វៀតណាម ប្រកបដោយសុវត្ថិភាព ។

(សូមមើលឧបសម្ព័ន្ធទី៨-ទី២២)

## ២.៥-ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

លទ្ធផលសំខាន់ៗក្នុងក្របខ័ណ្ឌការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលក្រសួងមហាផ្ទៃសម្រេចបាន មានជាអាទិ៍ ៖

-សហការរៀបចំ និងដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ព្រមទាំងអនុក្រឹត្យស្តីពី ការរៀបចំ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងអនុក្រឹត្យស្តីពីការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិបង្កក នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ។

-ដោយមានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ កម្លាំងនគរបាលប្រឆាំងការសម្អាតប្រាក់ នៃក្រសួងមហាផ្ទៃ បានបើកការស៊ើបអង្កេត បង្ក្រាបបទល្មើសសម្អាតប្រាក់ចំនួន ១០០ករណី (កសាងសំណុំរឿងទៅស្ថាប័នអយ្យការ ៣០ករណី អយ្យការសម្រេចចោទប្រកាន់បទល្មើសសម្អាតប្រាក់ ០៥ករណី) ។ ទន្ទឹមនេះ បានរៀបចំបែបបទស្នើសុំចាត់វិធានការបង្កកអចលនទ្រព្យចំនួន ១០ទីតាំង ដែលសង្ស័យជាទ្រព្យកខ្វក់កើតចេញពីផលនៃបទល្មើសគ្រឿងញៀន និងផ្អាកសកម្មភាព-បង្កកសាច់ប្រាក់សមាគមចំនួន ០១ទីតាំង ដែលសង្ស័យថា ជាឧបករណ៍សម្អាតប្រាក់ (ក្នុងនោះ សាលាដំបូងរាជធានីភ្នំពេញចេញដីកាបង្កកទ្រព្យសម្បត្តិចំនួន ០៣ដីកា) ។

-បានដំណើរការកម្មវិធីបំប៉នជំនាញ និងបច្ចេកទេសស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មចំនួន ០៥វគ្គ ជូនកងកម្លាំងនគរបាលជាតិចំនួន ៦៥៦រូប ។ ទន្ទឹមគ្នានេះ ក៏បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំវគ្គបណ្តុះបណ្តាលតាមអនឡាញ ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ០១លើក មានអ្នកចូលរួមជាង ៣៤០នាក់ និងរៀបចំសិក្ខាសាលាស្តីពី ការលើកកម្ពស់ហិរញ្ញវត្ថុ មានគោលដៅទាក់ទងនឹងការអនុវត្តហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយផ្តោតសំខាន់

លើ ៖ ទី១.ពន្យល់ពីនិយមន័យនៃការរីកសាយភាយអាវុធមហាប្រល័យ និងអនុក្រឹត្យពាក់ព័ន្ធនានា ទី២.ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុមានគោលដៅ ទី៣.ពិនិត្យលើការអនុលោមច្បាប់ ទី៤.ពង្រីកកិច្ចសហការជាមួយវិស័យឯកជន។

-FATF បានដំណើរការពិនិត្យសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពរបស់កម្ពុជា ដោយបានវាយតម្លៃ ថាក្នុងចំណោមសកម្មភាពសរុប ១៤សកម្មភាព មាន ០៤សកម្មភាព កម្ពុជាអនុវត្តបានភាគច្រើន ក្នុងនោះមាន ០៣ សកម្មភាព ជាសមត្ថកិច្ចរបស់កម្លាំងនគរបាលជាតិ ។

## ២.៦-ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

ក្រោមការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងដោយមានការដឹកនាំ សម្របសម្រួលពីក្រសួងមហាផ្ទៃ ដែលមានអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (**គ.ជ.ប.ជ**) ជាសេនាធិការក្នុងការជំរុញអនុវត្តសកម្មភាព និងយុទ្ធសាស្ត្រនានា ក្នុងរយៈពេល ០១ឆ្នាំនេះ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សម្រេចបានលទ្ធផល ដូចខាងក្រោម ៖

**- អំពីការងារពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ**

- ព្រះរាជាណាចក្រកម្ពុជា តាមរយៈអង្គការទេសន្តប្រវេសន៍អន្តរជាតិ IOM ត្រូវបានអង្គការសហប្រជាជាតិ ទទួលពិនិត្យលក្ខណៈវិនិច្ឆ័យ និងដាក់បញ្ចូលក្នុងបញ្ជីប្រទេសជ័យលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពី ទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ។
- អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** បាន ៖
  + ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការ A21 Foundation ស្តីពីកិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ ការពារ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
  + ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា CAMBODIA ACTs ស្តីពីកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ។
  + ចុះកិច្ចព្រមព្រៀងជាមួយអង្គការឃែរអន្តរជាតិ Care International ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ។
  + សហការជាមួយភាគីថៃ ពិនិត្យបញ្ចប់ និងត្រៀមចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការអនុវត្តច្បាប់ រវាងរាជរដ្ឋាភិបាលថៃ និងរាជរដ្ឋាភិបាលកម្ពុជា ។
  + សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជំនាញពាក់ព័ន្ធ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី របបគោលនយោបាយសម្រាប់ជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ ក្រោយពីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងទៀត ។
  + បន្តពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ តាមរយៈការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកជាប្រចាំ និងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីស្វែងរកគន្លឹះថ្មីៗក្នុងការដោះស្រាយបញ្ហាប្រឈមនានា បន្ថែមលើយន្តការដែលមានស្រាប់ ។
  + សហការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ២០១វគ្គ មានអ្នកចូលរួម [illegible]៣៥នាក់។
- ក្រសួងយុត្តិធម៌ដែលជាអនុប្រធានទទួលបន្ទុកកិច្ចការយុត្តិធម៌ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (MLA) រវាងប្រទេសក្នុងតំបន់ និងកំពុង

រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសឡាវ បារាំង និងកូរ៉េខាងត្បូង ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសប៉េរូ អង់គ្លេស និងឡាវ ស្តីពីការបញ្ជូនទណ្ឌិត ។

- ក្រសួងមហាផ្ទៃ បានសហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រសួងសុខាភិបាល តាក់តែង និងកែសម្រួលគោលនយោបាយជាតិស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ដែលនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាដើមឆ្នាំ២០២១ នេះ ។

**- អំពីការងារបង្ការ ទប់ស្កាត់**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួង ស្ថាប័ន និងកម្លាំងជំនាញពាក់ព័ន្ធ បន្តខិតខំជំរុញលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ពិសេសក្រុមជនងាយរងគ្រោះ តាមរយៈការចុះអប់រំដោយផ្ទាល់ដល់មូលដ្ឋានខ្នងផ្ទះ ការផ្សព្វផ្សាយតាមវេទិកាជាតិអន្តរសាសនា វេទិកាសាធារណៈតាមភូមិ ឃុំ និងតាមប្រព័ន្ធផ្សព្វផ្សាយនានាសរុប ១២៥.៩៤៨លើក មានអ្នកចូលរួម ៦.១៥៦.៣៩៣នាក់ ។

រដ្ឋបាលរាជធានី ខេត្ត និងកងកម្លាំងនគរបាលជាតិគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ បានបន្តដើរតួនាទីស្នូលក្នុងការតាមដាន ទប់ស្កាត់ អប់រំមុខសញ្ញាដែលសង្ស័យប្រព្រឹត្តអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ជាប្រចាំ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា តាក់តែងសៀវភៅមេរៀន និងលំនាំបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលនឹងត្រូវដាក់ឱ្យអនុវត្តជាផ្លូវការនាដើមឆ្នាំ២០២១ នេះ ។

**- ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស**

កម្លាំងអនុវត្តច្បាប់គ្រប់ផ្នែកនៃ គ.ជ.ប.ជ បានបើកការស៊ើបអង្កេត បង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបញ្ជូនទៅសាលាដំបូងរាជធានី ខេត្តបានចំនួន ១៥៥ករណី ឃាត់ខ្លួនជនសង្ស័យបានចំនួន ១៩៣នាក់ ស្រី ៣០នាក់ ។

ដោយឡែក បច្ចុប្បន្នភាពនៃការអនុវត្តនីតិវិធីនៅសាលាដំបូងរាជធានី ខេត្ត រួមមាន ៖ នៅដំណាក់កាលអយ្យការអមសាលាដំបូងចំនួន ៣១៣ករណី (ជនត្រូវចោទ ៥៥២នាក់ ជនរងគ្រោះ ៣៦៩នាក់) ចៅក្រមស៊ើបសួរ ៣៤៨ករណី (ជនត្រូវចោទ ៥៤៦នាក់ ជនរងគ្រោះ ៥៤៧នាក់) និងនៅដំណាក់កាលចៅក្រមជំនុំជម្រះចំនួន ៣៥៥ករណី (ជនជាប់ចោទ ៥១៦នាក់ ជនរងគ្រោះ ៤៩៣នាក់) ។

**- កិច្ចការពារជនរងគ្រោះ និងផ្តល់សេវាគាំទ្រ**

ជនរងគ្រោះដែលសង្គ្រោះបានក្នុងករណីបទល្មើសជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ មានចំនួនសរុប ៤៦៧នាក់ (ក្នុងនោះអាយុក្រោម ១៥ឆ្នាំ ១៣០នាក់ អាយុពី ១៥-១៧ឆ្នាំ ៣៩នាក់ និងអាយុចាប់ពី ១៨ឆ្នាំឡើង ២៩៨នាក់) បញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន ៩៨នាក់ និងប្រគល់ឱ្យគ្រួសារវិញចំនួន ៣៦៩នាក់។

ដោយឡែក ក្រោមកិច្ចសហការ សម្របសម្រួលពីក្រុមការងារអនុវត្តច្បាប់ ក្រុមការងារគាំពារជនរងគ្រោះ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពលរដ្ឋខ្មែរដែលរងគ្រោះអំឡុងពេលធ្វើទេសន្តរប្រវេសន៍នៅប្រទេសគោលដៅចំនួន ១០.៥៧៤នាក់ ស្រី ៤.២៧៥នាក់ ត្រូវបានសម្របសម្រួលរៀបចំបែបបទវិលត្រឡប់មកកម្ពុជាវិញដោយសុវត្ថិភាព ។

ក្នុងការគាំពារ និងផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួលឱ្យជនរងគ្រោះ និងងាយរងគ្រោះចំនួន

៣៧១នាក់ ទទួលបានកន្លែងស្នាក់នៅ និងស្តារនីតិសម្បទា និងជនរងគ្រោះចំនួន ១០៤នាក់ ធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ។

### ២.៧-ការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ

ក្នុងឆ្នាំ២០២០ នេះ ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការចូលរួមសហការ គាំទ្រពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម (គ.ប.ផ.ក) បានខិតខំជំរុញអនុវត្តផែនការ និងយន្តការដែលបានដាក់ចេញ ទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ ក៏ដូចជាការអនុវត្តខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នា (MoU) និងកិច្ចព្រមព្រៀងនានា សម្រេចបានលទ្ធផល ស្នាដៃ និងកសាងបានមូលដ្ឋានគ្រឹះនានាជាច្រើន នៅក្នុងក្របខ័ណ្ឌការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ក្នុងនោះ មានជាអាទិ៍ ៖

- បានបង្កើតមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ ដែលមានសមត្ថភាពខ្ពស់ក្នុងការវិភាគលើគុណភាពរបស់ផលិតផលគ្រប់ប្រភេទ ។
- បានចុះ MoU ជាមួយសមាគមសហព័ន្ធវិនិយោគិនកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងការនាំចូល ការផលិត និងការចែកចាយនូវផលិតផល ឱសថ គ្រឿងសម្អាង ដែលក្លែងក្លាយ នាំចូលគ្មានការអនុញ្ញាត រំលោភកម្មសិទ្ធិបញ្ញា និងរំលោភសិទ្ធិផ្តាច់មុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- បានរៀបចំចុះកិច្ចព្រមព្រៀងជាមួយវិស័យឯកជនចំនួន ០១លើក ដើម្បីជំរុញលើកកម្ពស់កិច្ចសហការលើការងារផ្សព្វផ្សាយអប់រំ ការគ្រប់គ្រងការប្រកបអាជីវកម្មរបស់ក្រុមហ៊ុន និងការគាំពារកម្មសិទ្ធិបញ្ញា ។
- សហការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់នៃផលិតផលក្លែងក្លាយដល់ប្រជាពលរដ្ឋ និងអាជីវករ ដោយផ្ទាល់ និងតាមកម្មវិធីវិទ្យុចំនួន ១៦លើក រួមទាំងតាមបណ្តាញទំនាក់ទំនងសង្គមនានាជាច្រើនលើកទៀត ។
- បានចូលរួមធ្វើបទបង្ហាញក្នុងវេទិកាអាស៊ី-អឺរ៉ុប លើប្រធានបទស្តីពី **ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព** ដោយផ្តោតលើចំណុចសំខាន់ៗចំនួន ០៤ រួមមាន ៖ ១.បន្ទុករបស់ពិភពលោកក្នុងវិបត្តិជំងឺកូវីដ-១៩ និងអភិក្រមពហុវិស័យគោលនយោបាយ និងអនុសាសន៍សម្រាប់ការប្រយុទ្ធប្រឆាំងនឹងឱសថក្លែងក្លាយ និងអន់គុណភាព ២.យន្តការសម្រាប់ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងអន់គុណភាព ៣.កាលានុវត្តភាពសម្រាប់កិច្ចសហប្រតិបត្តិការ ៤.ការស្នើអនុសាសន៍សម្រាប់ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព ។
- បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងច្បាប់ ដល់មន្ត្រីអនុវត្តច្បាប់ចំនួន ០៥វគ្គ ។
- បានស្រាវជ្រាវរកឃើញ និងបង្ក្រាបគោលដៅផលិត គោលដៅនាំចូល និងការចរាចរណ៍ឱសថក្លែងក្លាយ និងអន់គុណភាព ផលិតផលក្លែងក្លាយ-ខូចគុណភាព-អន់គុណភាព និងផលិតផលខុសច្បាប់ផ្សេងៗចំនួន ១៧៧ករណី ឃាត់ខ្លួន ២០នាក់ រឹបអូសវត្ថុតាងបានជិត ១៣ាន់តោន (បាន និងកំពុងធ្វើការដុតកម្ទេចចោលជាបន្តបន្ទាប់) ។

សកម្មភាព និងលទ្ធផលការងារខាងលើនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងចំណូលថវិការដ្ឋ ខណៈដែលកម្ពុជាក៏ដូចជាប្រទេសជាច្រើនក្នុងសកលលោក កំពុងជួបប្រឈមបញ្ហានេះយ៉ាងស្មុគស្មាញ ។ បច្ចុប្បន្ន ដោយផ្អែកលើស្ថានភាពបទល្មើស និងកិច្ចប្រតិបត្តិការកន្លងទៅ ចំពោះមុខនេះ ដើម្បីឈានទៅកាត់បន្ថយបទល្មើសឱ្យ

បានជាអតិបរមា ចាំបាច់តម្រូវឱ្យ ៖ ១-គ្រប់ភាគីពាក់ព័ន្ធ ត្រូវបន្តចូលរួមសហការដោយការប្តេជ្ញាចិត្តខ្ពស់ ២-ធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ឱ្យមានវិសាលភាពគ្របដណ្តប់ទៅលើស្ថានភាពជាក់ស្តែង ៣-មានឧបករណ៍ សម្ភារៈបច្ចេកទេសគ្រប់គ្រាន់ សម្រាប់បម្រើដល់ប្រតិបត្តិការស៊ើបអង្កេត និងបង្ក្រាប ។

### ២.៨-ការងារអត្តសញ្ញាណកម្ម

#### ក.ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់

ក្របខ័ណ្ឌគោលនយោបាយសម្រាប់គាំទ្រ និងតម្រង់ទិសដល់ការងារអត្តសញ្ញាណកម្ម ត្រូវបានយកចិត្តទុកដាក់ជំរុញរៀបចំ កែសម្រួល និងដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការផ្តល់សេវាអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋ ស្របតាមសំណូមពរចាំបាច់ប្រចាំថ្ងៃ ក៏ដូចជាធានានូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ជាមូលដ្ឋានរបស់បុគ្គលផង និងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផង ។

ក្នុងឆ្នាំ២០២០ កន្លងទៅនេះ ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ បានបន្តខិតខំជំរុញការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម យ៉ាងសកម្មផុលផុស (ក្នុងនោះ រៀបចំបានចំនួន ១២ជំពូក ស្មើ ១៦៩មាត្រា)។ ជាមួយគ្នានេះ ដើម្បីឆ្លើយតបតម្រូវការចាំបាច់ក្នុងការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ក្រសួងក៏បានសិក្សារៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គលដែលគ្រោងនឹងគោរពស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល នាពេលខាងមុខ ។

ទន្ទឹមនេះ ក្រសួងមហាផ្ទៃក៏បានសម្រេចកែសម្រួលនីតិវិធី និងសមត្ថកិច្ចក្នុងការផ្តល់សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួល និងឆាប់រហ័សលើការចុះបញ្ជីស្នាក់នៅ និងបញ្ជីគ្រួសារ ជូនប្រជាពលរដ្ឋដែលមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីតម្រង់ទិសដល់ការអនុវត្តការងារនេះ ក្រសួងបានរៀបចំដាក់ចេញនូវប្រកាសស្តីពី ការផ្ទេរសមត្ថកិច្ចក្នុងការផ្តល់សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ និងសេចក្តីណែនាំស្តីពី បែបបទ និងនីតិវិធីនៃការងារចុះបញ្ជី និងគ្រប់គ្រងការស្នាក់នៅ ។

#### ខ.ការងារអត្រានុកូលដ្ឋាន

-ដើម្បីជំរុញការងារកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ទាន់ពេលវេលា ទាំងសំណុំឯកសារដែលបានដាក់ពាក្យស្នើសុំនៅនាយកដ្ឋាន និងនៅតាមបណ្តារាជធានី ខេត្ត ក្រសួងបាន និងកំពុងរៀបចំដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធតាមដានឯកសារស្នើសុំកែតម្រូវ និងមោឃភាពទិន្ន័យនៃបញ្ជីអត្រានុកូលដ្ឋានតាមបណ្តារាជធានី ខេត្ត ។

-គិតពីខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋបានចំនួន ១៩.៤៦៧.០១៣នាក់ ស្រី ៩.២៧៥.៧២៧នាក់។ <u>កត់សម្គាល់៖</u> ក្នុងឆ្នាំ២០២០ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ៥២៧.៤៨៦បញ្ជី ស្មើ ៦១៤.២២៤នាក់ ស្រី ៣០១.១៦[illegible]នាក់ ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៤.៧១០ច្បាប់ ស្មើ ២៩.៤២៣សន្លឹក ចេញសេចក្តីសម្រេចស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ១[illegible]៥២ច្បាប់ កែតម្រូវបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមសេចក្តីសម្រេចបានចំនួន ៤.៩៩៦ច្បាប់ ទទួល[illegible]ក្រុម[illegible]កាកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានចំនួន ១.១៤០ច្បាប់ ។

-បានចេញសេចក្តីសម្រេចស្តីពី ការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសចំនួន ១.០០៨ច្បាប់ រួមមាន ៣១សញ្ជាតិ ។

-បើកផ្តល់ជូនរាជធានី ខេត្តទាំង ២៥ នូវសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៤៧.៧៨៩ក្បាល និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៥.៧៣៣.១០០សន្លឹក ។

**គ.ការគ្រប់គ្រងការស្នាក់នៅ**

-ការបញ្ចូលទិន្នន័យចុះបញ្ជីក្នុងប្រព័ន្ធកុំព្យូទ័រ (នៅខេត្តកែប និងខេត្តកំពត) រួមមាន៖ សៀវភៅស្នាក់នៅបានចំនួន ១.០២៦ក្បាល ស្មើ ៣.៩៤៨នាក់ ស្រី ១.៩៦៤នាក់ និងសៀវភៅគ្រួសារបានចំនួន ៨៩៨ក្បាល ស្មើ ៣.៦៦៩នាក់ ស្រី ១.៨១៧នាក់ ។ គិតមកដល់បច្ចុប្បន្ន បញ្ចូលទិន្នន័យសៀវភៅស្នាក់នៅបានចំនួន ២.៧៨៦ គ្រួសារ ស្មើ ១០.៩២៧នាក់ ស្រី ៥.៥៦៦នាក់ និងសៀវភៅគ្រួសារបានចំនួន ២.៣៨៨គ្រួសារ ស្មើ ៩.៨១៧នាក់ ស្រី ៥.០៥៤នាក់ ។

-ផ្តល់ជូនប្រជាពលរដ្ឋនូវសៀវភៅស្នាក់នៅថ្មីបានចំនួន ១២៣.៥៦៧ក្បាល ទុតិយតា ១០១.៣៧០ក្បាល និងសៀវភៅគ្រួសារថ្មីបានចំនួន ៧៣.៨៧២ក្បាល ទុតិយតា ៦០.៥១៥ក្បាល ។ គិតមកដល់បច្ចុប្បន្ន ផ្តល់សៀវភៅស្នាក់នៅថ្មីបានចំនួន ៣.៣៤៥.៦០៣ក្បាល ទុតិយតា ៣៥៦.៣៣៩ក្បាល និងផ្តល់សៀវភៅគ្រួសារថ្មីបានចំនួន ៣.០៥៨.៨៤៨ក្បាល ទុតិយតា ២១២.៨២៤ក្បាល ។ <u>កត់សម្គាល់ ៖</u> ចំនួនប្រជាពលរដ្ឋដែលបានចុះបញ្ជីស្ថិតិ មាន ១៥.៨៨០.៥៤០នាក់ ស្មើ ៨.១៣០.១៧៩គ្រួសារ ។

-បើកផ្តល់ឯកសារស្ថិតិប្រជាពលរដ្ឋជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តទាំង ២៥ ចំនួន ៣៣៧.១៧៧ ក្បាល ក្នុងនោះ សៀវភៅស្នាក់នៅ ១៧៤.៤៨០ក្បាល សៀវភៅគ្រួសារ ១៥៦.៣៦០ក្បាល ។

-ទទួលពលរដ្ឋខ្មែរដែលធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិកចំនួន ០១លើក មនុស្ស ២៥នាក់ និងបានផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណនានា ដើម្បីឱ្យពួកគាត់ធ្វើសមាហរណកម្មចូលក្នុងសហគមន៍ខ្មែរវិញ។ គិតពីឆ្នាំ ២០០២ មកដល់បច្ចុប្បន្នមានចំនួន ២៥១លើក មនុស្ស ៧៧៤នាក់ ស្រី ១៩នាក់ ។

**ឃ.ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែន**

-ទទួលទិន្នន័យស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីពីបណ្តារាជធានី ខេត្តចំនួន ៤៦៦.២៨៧នាក់ (ក្នុងនោះ ទិន្នន័យបានការ ៤៤៣.៣២៤នាក់ ស្នូនខ្មៅដៃ ២២.០២៣នាក់ និងខូច ៩៤០នាក់) និងសំណើសុំកែតម្រូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលខុសបច្ចេកទេស ខូច បាត់ ចំនួន ៦៦.២០១សន្លឹក ។

-បោះពុម្ពអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(គិតទាំងទិន្នន័យថ្មី និងទិន្នន័យបាត់ ខូច សុំកែតម្រូវ) បានចំនួន ៥៨៤.៧៤១សន្លឹក និងប្រគល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្តបានចំនួន ៦១៩.៣៥៥សន្លឹក ។ គិតមកដល់បច្ចុប្បន្ន ការបោះពុម្ពអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទាំង ០៣ជំហាន មានចំនួន ១០.៩៩២.៣៣៣សន្លឹក និងផ្តល់ជូនរាជធានី ខេត្ត បានចំនួន ១០.៩៨៥.៨៧៣សន្លឹក ស្មើ ៩៦% នៃផែនការ ១១.៤៨៧.៦២៥នាក់ ។

<u>**កត់សម្គាល់៖**</u> ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ នៅស្នាក់ការផ្សារទំនើបអ៊ីអនម៉ល២ បានចំនួន ១៣.២៣១នាក់ នៅនាយកដ្ឋានបានចំនួន ៧.៤៧២នាក់ (ជនបរទេសចូលសញ្ជាតិខ្មែរ ១៥៣នាក់)។ ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋដែលធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិកបានចំនួន ២៥នាក់។ ដោះស្រាយបញ្ហាស្នូនខ្មៅដៃបានចំនួន ៦៤១.៩៨២ករណី នៅសល់ ២៣.២៧២ករណី ។

-បោះពុម្ពលិខិតឆ្លងដែន និងផ្តល់ជូនប្រជាពលរដ្ឋបានចំនួន ១២២.៣៦៥ក្បាល និងបោះពុម្ពលិខិតធ្វើដំណើរជូនពលករកម្ពុជាធ្វើការនៅបរទេសបានចំនួន ២២.៦៣០ក្បាល។ គិតមកដល់បច្ចុប្បន្ន ផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋបានចំនួន ៣.៨៣១.៨៤១ក្បាល និងលិខិតធ្វើដំណើរពលករកម្ពុជាដែលធ្វើការនៅបរទេសបានចំនួន ៦៣១.៣៦៩ក្បាល ។

**ខ.ការងារសញ្ជាតិ**

-បានទទួលសំណុំឯកសារស្នើសុំចូលសញ្ជាតិខ្មែរ និងព្រះរាជក្រឹត្យស្ដីពីការផ្ដល់សញ្ជាតិខ្មែរ ចំនួន ៤០០ករណី ស្មើ ៤០៣នាក់ (ករណីសញ្ជាតូបនីយកម្មចំនួន ៣៨០ករណី ស្មើ ៣៨៣នាក់ និងករណីទាមទារសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ ចំនួន ២០ករណី ស្មើ ២០នាក់) និងទទួលព្រះរាជក្រឹត្យស្ដីពី ការលះបង់សញ្ជាតិខ្មែរ ចំនួន ០៤ករណី ស្មើ ០៤នាក់ ។

គិតពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ន ជនបរទេសសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មសម្រេចបានចំនួន ២.១៤៤ករណី ស្មើ ២.២០៣នាក់ មាន ៤៨សញ្ជាតិ ទាមទារសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍ ៩៦នាក់ មាន ៣២សញ្ជាតិ និងលះបង់សញ្ជាតិខ្មែរ ១៦៥នាក់ ។

**ច.ការងារពង្រឹងយន្តការផ្ដល់សេវាអត្តសញ្ញាណកម្ម**

-ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការផ្ដល់សេវាអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋ ក្រសួងមហាផ្ទៃបានសម្រេចបង្កើតក្រុមការងារ*ប្រចាំការសេវាកម្មអត្តសញ្ញាណកម្ម និងប្រតិកម្មរហ័ស* នៅដើមឆ្នាំ២០១៩ ដើម្បីពង្រឹងយន្តការសេវាអត្តសញ្ញាណកម្ម ។ ក្រុមប្រចាំការនេះ មានភារកិច្ចតាមដាន ស្រង់មតិ យោបល់ សំណូមពរ និងបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដើម្បីយកមកពិនិត្យ ដោះស្រាយតាមរយៈ ៖ ទី១.កម្មវិធីសេវាកម្មអត្តសញ្ញាណកម្មតាមទូរស័ព្ទដៃ ដែលមានឈ្មោះថា GDI eServices ទី២.លេខទូរស័ព្ទប្រចាំការដែលមិនគិតកម្រៃសេវា "១២៧១" ទី៣.ប្រអប់សំបុត្រទទួលមតិ សំណូមពររបស់ប្រជាពលរដ្ឋចំនួន ១១ទីតាំង ទី៤.ទំព័រគណនីហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងទី៥.គណនីហ្វេសប៊ុកផ្លូវការរបស់**សម្ដេចក្រឡាហោម** និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដែលមានព័ត៌មានពាក់ព័ន្ធនឹងសេវាអត្តសញ្ញាណកម្ម។ ជាលទ្ធផលក្នុងឆ្នាំ២០២០ ឆ្លើយតបសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋបានចំនួន ៤.៨០០ករណី និងដោះស្រាយបញ្ហាប្រឈម ឬបណ្ដឹងផ្សេងៗបានចំនួន ២៥៣ករណី ។

-បាន និងកំពុងសហការជាមួយសាលារាជធានីភ្នំពេញ និងដៃគូអភិវឌ្ឍ គ្រោងរៀបចំយន្តការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅថ្នាក់សង្កាត់ ដោយជ្រើសរើសយកសង្កាត់មួយ ក្នុងខណ្ឌនីមួយៗ នៃខណ្ឌទាំង ១៤ របស់រដ្ឋបាលរាជធានីភ្នំពេញ ។

-បានសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន សិក្សា រៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក ជាមួយប្រព័ន្ធអត្តសញ្ញាណកម្ម ។

-បានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំ និងដាក់ឱ្យដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX ។ គិតត្រឹមថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុនដែលបានចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX មានចំនួន ២.៦៩៣ក្រុមហ៊ុន ។

**ឆ.ចន្លានភាពនៃការផ្ដល់ឯកសាររដ្ឋបាលកម្ពុជាឱ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍**

ការផ្ដល់លិខិតស្នាមរដ្ឋបាលឡើងវិញជូនសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍ និងការពិនិត្យសំណុំឯកសារស្នើសុំសញ្ជាតិខ្មែរ ទទួលបានលទ្ធផលដូចខាងក្រោម ៖

-អនុវត្តនីតិវិធីករណីស្នើសុំឯកសារអត្រានុកូលដ្ឋានឡើងវិញបានចំនួន ១២៨ច្បាប់/១៤៣ច្បាប់ ។

-ផ្ដល់សៀវភៅស្នាក់នៅ(ក២) បានចំនួន ២៣០ក្បាល មនុស្ស ៨៩៥នាក់ ស្រី ៤០៨នាក់ និងសៀវភៅគ្រួសារ(ក៤) បានចំនួន ១០០ក្បាល មនុស្ស ២៤៤នាក់ ស្រី ១២៥នាក់ ។

-អនុវត្តនីតិវិធីលើករណីសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសអន្តោប្រវេសន្តចំនួន ០៧ករណី ស្មើ ១១នាក់ ស្រី ០៧នាក់(ស្នាក់នៅជាប់ចាប់ពី ៧ឆ្នាំ ០៣ករណី ស្មើ ០៧នាក់ និងតាមរយៈអាពាហ៍ពិពាហ៍ ០៤ករណី ស្មើ ០៤នាក់) ។ ការអនុវត្តនីតិវិធីផ្តល់សញ្ជាតិនេះ ពុំបានរាប់បញ្ចូលក្នុងការងារសញ្ជាតិខាងលើទេ ។ (សូមមើលឧបសម្ព័ន្ធទី៥-ទី៧)

### ២.៩-ការងារអន្តោប្រវេសន៍

#### ក-ការងារគ្រប់គ្រងដំណើរចេញ ចូលប្រទេស

-ជនបរទេសធ្វើដំណើរចូលមកកម្ពុជាជាលក្ខណៈអន្តរជាតិមានចំនួន ១.៥៨៤.១៨២នាក់ មាន ២១៦សញ្ជាតិ ចូលក្នុងក្របខ័ណ្ឌតំបន់ចំនួន ២៨.៥៤៤នាក់ មាន ០៣សញ្ជាតិ និងចេញទៅវិញជាលក្ខណៈអន្តរជាតិមានចំនួន ១.៦៨៨.៩២៧នាក់ មាន ២១៦សញ្ជាតិ ចេញក្នុងក្របខ័ណ្ឌតំបន់ចំនួន ២៨.៧១០នាក់ មាន ០៣សញ្ជាតិ។ ដោយឡែក ជនបរទេសចូលមកលេងល្បែងក្នុងកាស៊ីណូតាមតំបន់ព្រំដែនមានចំនួន ៥៣១.៩៧១នាក់ មាន ១១សញ្ជាតិ ។

-ពលរដ្ឋខ្មែរធ្វើដំណើរចេញពីប្រទេសជាលក្ខណៈអន្តរជាតិមានចំនួន ៤៥១.៤៤០នាក់ ក្នុងក្របខ័ណ្ឌតំបន់ចំនួន ១.៧៧៧.៣៣៤នាក់ និងចូលមកវិញជាលក្ខណៈអន្តរជាតិមានចំនួន ៤៨៦.១៣៣នាក់ ក្នុងក្របខ័ណ្ឌតំបន់ចំនួន ១.៧៩៤.៤៥៣នាក់។ ដោយឡែក ពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសចំនួន ៥ប្រទេស បញ្ជូនត្រឡប់មកវិញ (ដោយមូលហេតុស្នាក់នៅ ឬធ្វើការខុសច្បាប់) មានចំនួន ៦.៧៤៣នាក់ ស្រី ២.០១០នាក់ និងកុមារ ៤៤២នាក់ និងពលករខ្មែរដែលទៅធ្វើការស្របច្បាប់នៅក្រៅប្រទេសតាមរយៈក្រុមហ៊ុនមានចំនួន ៣២.៤២៧នាក់ ។

ជារួម ពិនិត្យឃើញថា ក្នុងឆ្នាំ២០២០ នេះ ភ្ញៀវទេសចរចូលមកកម្សាន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ថយចុះ ៧៤,៨៣% និងប្រជាពលរដ្ឋខ្មែរចេញទៅដំណើរកម្សាន្តនៅក្រៅប្រទេស ថយចុះ ៧៩,៤១% ។

<u>**កត់សម្គាល់**</u> ៖ ក្នុងដំណើរការត្រួតពិនិត្យបែបបទចេញចូលប្រទេស បានផ្អាកដំណើរចូល និងបណ្តេញឱ្យថយក្រោយវិញនូវជនបរទេសមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ចំនួន ៥៥៤នាក់/៤៦០លើក ។

#### ខ-ការងារគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា

-**ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត** ៖ ក្រោយពីបញ្ចប់ឱសានវាទនៃការដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី និងការដាក់ពាក្យសុំជាជនបរទេសអន្តោប្រវេសន្ត នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ស្ថិតិរួមនៃជនបរទេសអន្តោប្រវេសន្តដែលនៅសល់មានចំនួន ៨៩.៧៨៦នាក់ ស្រី ៤២.៨២៤នាក់ ក្នុងនោះ ធ្វើការដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីបានចំនួន ៣៧.៤៣៦ច្បាប់ ស្មើ ២០.១០៧គ្រួសារ មនុស្ស ៦៩.៩៥៧នាក់ ស្រី ៣៣.៨៧៦នាក់ ។ ចំពោះជនបរទេសដែលត្រូវបានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីខាងលើ ត្រូវបានអនុញ្ញាតឱ្យធ្វើការដាក់ពាក្យសុំឯកសាររដ្ឋបាលកម្ពុជាតាមនីតិវិធីច្បាប់ឡើងវិញ ។ ជាលទ្ធផល ក្នុងឆ្នាំ២០២០ ៖

+ទទួលពាក្យសុំប្រកាសទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន្តនៅព្រះរាជាណាចក្រកម្ពុជាបានចំនួន ៣២.៦៣៧គ្រួសារ មនុស្ស ១០៣.៧៣៨នាក់ ស្រី ៥០.១៩៨នាក់ ក្នុងនោះ ក្រសួងបានចេញប្រកាសទទួលស្គាល់ចំនួន ៣២.៥១៨គ្រួសារ មនុស្ស ៧១.៧៨៦នាក់ ស្រី ៣៤.៩៥៥នាក់ ។

+ទទួលពាក្យសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍បានចំនួន ២៨.៩៤៥គ្រួសារ មនុស្ស ៨៩.៧៨៦នាក់ ស្រី ៤២.៩២៤នាក់ ក្នុងនោះ ក្រសួងបានចេញប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចំនួន ១៦.០១៧គ្រួសារ មនុស្ស ៧៥.៨៤២នាក់ ស្រី ៣៦.៤០៥នាក់ ។

ទន្ទឹមនេះ បានទទួលពាក្យបណ្តឹងតវ៉ាទាមទារសញ្ជាតិខ្មែរពីជនបរទេសដែលត្រូវបានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីចំនួន ១១៣ករណី ក្នុងនោះ សម្របសម្រួលដោះស្រាយបានចំនួន ១១១ករណី ។

**-ការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត**

+បានផ្តល់ទិដ្ឋាការចូលប្រទេសចំនួន ៥៦២.៣៣៨នាក់ ទិដ្ឋាការចេញ ២.៨៦២នាក់ និងពន្យារទិដ្ឋាការស្នាក់នៅចំនួន ៣៥៣.១៥៥នាក់ ។ ដោយឡែក ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ ក្រសួងបានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន ១៦១.៩៨០ដុល្លារ បង់ចូលថវិកាជាតិ ។

+បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា Foreign Presence in Cambodia System (FPCS) ដោយភ្ជាប់គណនីនៃប្រព័ន្ធនេះជូនមន្ត្រីនគរបាលមានសមត្ថកិច្ចនៅតាមរាជធានី ខេត្ត និងម្ចាស់លំនៅឋានដែលមានជនបរទេសស្នាក់នៅ។ ជាលទ្ធផល ចាប់ពីខែកក្កដា ឆ្នាំ២០២០ មកទល់ពេលនេះ ចុះវត្តមានជនបរទេសបានចំនួន ២៧៥.១១៣នាក់ ស្រី ៦៩.៥៥៦នាក់ ។

**-ការងារគ្រប់គ្រងជនភៀសខ្លួន** ៖ គិតមកដល់បច្ចុប្បន្ន ជនបរទេសដែលទទួលបានឋានៈជាជនភៀសខ្លួនមានចំនួន ៦៤នាក់ ស្រី ១៥នាក់ មាន ០៨សញ្ជាតិ អ្នកសុំសិទ្ធិជ្រកកោនមានចំនួន ២១នាក់ ស្រី ១១នាក់ មាន ០៦សញ្ជាតិ និងជនជាតិម៉ុងតាញ៉ានៅសល់ចំនួន ១២នាក់ ស្រី ០២នាក់។ ក្នុងរយៈពេល ០១ឆ្នាំនេះ ក្រសួងបានអនុវត្តនីតិវិធីលើករណីជនជាតិម៉ុងតាញ៉ាស្ម័គ្រចិត្តវិលត្រឡប់ទៅប្រទេសកំណើតវិញចំនួន ១២នាក់ ស្រី ០៥នាក់។

### គ-ការងារគ្រប់គ្រងជនបរទេសជាអ្នកវិនិយោគ និងពលកម្មបរទេស

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុនវិនិយោគមានចំនួនសរុប ២.៨៦៥ក្រុមហ៊ុន (ធៀបឆ្នាំ២០១៩ កើន ១៤៣ក្រុមហ៊ុន) ក្នុងនោះវិស័យកសិកម្មចំនួន ២៥២ក្រុមហ៊ុន មាន ១៩សញ្ជាតិ វិស័យទេសចរណ៍ ១២៥ក្រុមហ៊ុន មាន ១៧សញ្ជាតិ វិស័យហេដ្ឋារចនាសម្ព័ន្ធ ១៦១ក្រុមហ៊ុន មាន ១៧សញ្ជាតិ និងវិស័យរោងចក្រ សហគ្រាស ចំនួន ២.៣២៧ក្រុមហ៊ុន មាន ៤២សញ្ជាតិ ។

ក្នុងការគ្រប់គ្រងការប្រកបមុខរបររបស់ជនបរទេស ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តជំរុញការងារចុះធ្វើអធិការកិច្ចពលករបរទេសនៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថាននានាបានចំនួន ៣.៥៨៨គោលដៅ មានពលករបរទេសចំនួន ៣៥.៩០៣នាក់ ក្នុងនោះរកឃើញគ្មានប័ណ្ណការងារចំនួន ៩២៨នាក់ ធ្វើការផាកពិន័យជាទឹកប្រាក់សរុបចំនួន ៤៤៦.០០០.០០០រៀល ។

### ឃ-ការងារស៊ើបអង្កេត និងអនុវត្តនីតិវិធី

ដើម្បីទប់ស្កាត់ និងកាត់បន្ថយជាអតិបរមានូវជនបរទេសខុសច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ខ្ពស់លើការងារស្រាវជ្រាវ ស៊ើបអង្កេត ស្វែងរកចាប់ខ្លួនជនបរទេសដែលជ្រៀតចូលមកស្នាក់នៅខុសច្បាប់ ឬស្នាក់នៅលើសរយៈពេលកំណត់ និងជនបរទេសមានពាក់ព័ន្ធបទល្មើសផ្សេងៗ ដែលក្នុងរយៈពេល ០១ឆ្នាំនេះ បានឃាត់ខ្លួន និងបណ្តេញជនបរទេសល្មើសច្បាប់ចេញពីប្រទេសកម្ពុជាតាមនីតិវិធីច្បាប់ចំនួន ៧៩៦នាក់/៤៨សញ្ជាតិ ។

<u>**កត់សម្គាល់**</u> ៖ ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុ និងបទល្មើសផ្សេងៗមានចំនួន ៣៧១លើក ស្មើ ៤១៦នាក់/៥០សញ្ជាតិ ក្នុងនោះ ស្លាប់ ២៥៥នាក់ របួស ១១០នាក់ និងបាត់សម្ភារៈ ៥១នាក់ ។ បង្ក្រាបជនបរទេសប្រព្រឹត្តបទល្មើសផ្សេងៗនៅក្នុងប្រទេសបានចំនួន ៣៧៧លើក ស្មើ ១.០០៨នាក់/៥២សញ្ជាតិ និងនៅតាមបណ្តាច្រកទ្វារព្រំដែនចំនួន ៤០៧លើក ស្មើ ៤៩១នាក់/៧១សញ្ជាតិ ។ (សូមមើលឧបសម្ព័ន្ធទី២៣-២៤)

## ២.១០-ការងារគ្រប់គ្រងពន្ធនាគារ

ការងារគ្រប់គ្រងពន្ធនាគារ ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ និងដោយមានការចូលរួមជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍនានា ត្រូវបានបន្តជំរុញធ្វើកំណែទម្រង់គ្រប់ផ្នែកឱ្យមានការវិវត្តឥត

ឈប់ឈរ ដើម្បីធានាការគ្រប់គ្រងប្រកបដោយសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងមនុស្សធម៌ផង និងចូលរួមចំណែកកាត់បន្ថយបទល្មើសនានាក្នុងសង្គមផង ។ ជាក់ស្តែង ក្នុងអំឡុងពេល ០១ឆ្នាំ នេះ ៖

-ជាមួយនឹងការខិតខំជំរុញអនុវត្តយន្តការដែលមានស្រាប់ គោលការណ៍ និងវិធានការជាច្រើន ក៏ត្រូវបានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់ សម្រាប់ជួយគាំទ្រដល់ការងារពង្រឹងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងពន្ធនាគារ និងសុខភាព-អនាម័យរបស់ជនជាប់ឃុំផងដែរ ។ <u>កត់សម្គាល់៖</u> គ្រប់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត បានអនុវត្តត្រឹមត្រូវតាមវិធានសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ទន្ទឹមគ្នានេះ បានត្រួតពិនិត្យឆែកឆេររកឃើញ និងដកហូតបានទូរស័ព្ទដៃ ៧៤គ្រឿង និងសម្ភារៈហាមឃាត់មួយចំនួនទៀតពីជនជាប់ឃុំ ។ ប៉ុន្តែក៏មានករណីជនជាប់ឃុំលួចរត់គេចខ្លួនបានសម្រេច ០៣ករណី ស្មើ ០៣នាក់ ផងដែរ ។

-មានជនជាប់ឃុំចំនួន ២.៨៩១នាក់ ស្រី ៣៥៣នាក់ ទទួលបានការបណ្តុះបណ្តាលលើជំនាញវិជ្ជាជីវៈ ដូចជា ៖ កាត់ដេរ កាត់សក់ សំអាងការ ប្រើប្រាស់ និងជួសជុលកុំព្យូទ័រ ជួសជុលម៉ូតូ យានយន្ត និងបរិក្ខារត្រជាក់ បច្ចេកទេសកសិកម្ម សិប្បកម្ម សំណង់ស៊ីវិល អេឡិចត្រូនិច ជំនាញផលិតកម្ម ... ក្នុងនោះ មាន ៣៩២នាក់ ស្រី ១៤នាក់ ទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា។ ក្រៅពីទទួលបានការបណ្តុះបណ្តាលមុខជំនាញ ជនជាប់ឃុំក៏ត្រូវបានបង្រៀនពីបទបញ្ជាផ្ទៃក្នុង អក្ខរកម្ម ថ្នាក់បឋមសិក្សា ភាសាបរទេស បំណិនជីវិត សីលធម៌ អប់រំផ្សេងៗ បញ្ចេញឱ្យលេងកីឡា ហាត់ប្រាណ និងចូលអានសៀវភៅក្នុងបណ្ណាល័យផងដែរ ។

-បានពិនិត្យ ព្យាបាលជំងឺជូនជនជាប់ឃុំចំនួន ៣៣៩.៤៩៧ករណី(ករណីសង្គ្រោះបន្ទាន់ ៥.៨៤១ករណី) ក្នុងនោះ នៅប៉ុស្តិ៍សុខភាពពន្ធនាគារ ៣៣៤.៦៨១ករណី និងបញ្ជូនទៅមន្ទីរពេទ្យខាងក្រៅ ៤.៨១៦ករណី ។

-អគារ ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបច្ចេកទេសនៅតាមបណ្តាមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត ត្រូវបានសាងសង់ ជួសជុលកែលម្អ និងបំពាក់បន្ថែមជាបន្តបន្ទាប់ ក្រោមគម្រោងប្រើប្រាស់ថវិការដ្ឋចំនួន ០៤គម្រោង គម្រោងផ្ទាល់របស់ក្រសួងចំនួន ០១គម្រោង គម្រោងវិនិយោគជាមួយវិស័យឯកជនចំនួន ០១គម្រោង គម្រោងសហការជាមួយដៃគូនានាចំនួន ២៤៦គម្រោង និងគម្រោងសាងសង់បន្ទប់មេធាវីចំនួន ១១គម្រោង ដែលក្នុងនោះ មានគម្រោងចំនួន ២៥៦គម្រោង ត្រូវបានបញ្ចប់ជាស្ថាពរ និង ០៧គម្រោងទៀត កំពុងដំណើរការ ។

<u>កត់សម្គាល់</u> ៖ ក្នុងរយៈពេល ០១ឆ្នាំនេះ ស្ថានភាពចំនួនជនជាប់ឃុំមានការប្រែប្រួលជាអាទិ៍៖ ចាប់ចូលថ្មីចំនួន ២២.២៩៥នាក់ ស្រី ១.៥៦៤នាក់ ដោះលែងចំនួន ១៩.៧៦៨នាក់ ស្រី ១.៥៤៥នាក់ ស្លាប់ចំនួន ២១៣នាក់ ស្រី ០៦នាក់ រត់រួចចំនួន ០៣នាក់ និងបត្យាប័នចេញ ០១នាក់។ ជារួម គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ជនជាប់ឃុំមានចំនួនសរុប ៣៩.៣១៧នាក់ ស្រី ២.៥៩៧នាក់ ក្នុងនោះ ជនត្រូវចោទ ៦.១៣៦នាក់ (ស្រី ៤៧១នាក់ ជនបរទេស ៤២៧នាក់ អនីតិជន ៤០៥នាក់) ជនជាប់ចោទ ៣.៧៩៦នាក់ (ស្រី ២៤៧នាក់ ជនបរទេស ១៩១នាក់ អនីតិជន ២៩៦នាក់) ពិរុទ្ធជន ១៦.៧២១នាក់ (ស្រី ១.០៥៤នាក់ ជនបរទេស ៨៦៣នាក់ អនីតិជន ៧៥៥នាក់) និងទណ្ឌិត ១២.៦៦៤នាក់ (ស្រី ៨២៥នាក់ ជនបរទេស ៣៥៤នាក់ អនីតិជន ២៣១នាក់) ។

(សូមមើលឧបសម្ព័ន្ធទី២៥)

## ២.១១-ការងារបណ្តុះបណ្តាលនគរបាលជាតិ

ដើម្បីឆ្លើយតបទៅនឹងផែនការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួងមហាផ្ទៃ និងគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល ធានាបាននូវភាពម្ចាស់ការលើការអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំ គ្រប់គ្រង និងការអនុវត្តតួនាទី ភារកិច្ចរបស់មន្ត្រី សំដៅលើកស្ទួយកិត្យានុភាព ឧត្តមភាពកម្ពុជា នៅលើ

ឆាកអន្តរជាតិ ក្រសួងមហាផ្ទៃ បានបន្តយកចិត្តទុកដាក់ជំរុញកិច្ចការសំខាន់ៗដែលជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលដូចជា ធ្វើការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងជាប្រចាំ ដើរទន្ទឹមនឹងការខិតខំអភិវឌ្ឍគុណវុឌ្ឍិ-សមត្ថភាពគ្រូបង្រៀន កម្មវិធីសិក្សា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត-សម្ភារៈសិក្សាគ្រប់ប្រភេទ និងការរឹតបន្តឹងការអនុវត្តវិន័យ...។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២០ ៖

-បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារចំនួន ៣១ថ្នាក់-វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សសរុបចំនួន ៣.០១២រូប ស្រី ៥៧០រូប ក្នុងនោះថ្នាក់-វគ្គសិក្សាបានបញ្ចប់ជាស្ថាពរចំនួន ០១ថ្នាក់ និង ០៩វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សចំនួន ១.៧៩៦រូប ស្រី ៣៧៥រូប និងថ្នាក់-វគ្គសិក្សាដែលស្ថិតក្នុងកម្មវិធីបណ្តុះបណ្តាលឆ្នាំ២០២០ តែមិនទាន់ចប់ ហើយត្រូវរំកិលទៅអនុវត្តក្នុងឆ្នាំ២០២១ ចំនួន ១៦ថ្នាក់ និង ០៥វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សចំនួន ១.២១៦រូប ស្រី ១៩៥រូប ។

-បានបន្តលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំ និងគ្រូនគរបាលជាតិ តាមរយៈការបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងចាត់បញ្ជូនទៅសិក្សានៅក្នុង និងក្រៅប្រទេស សរុបចំនួន ៦២១រូប ។

-បានកែសម្រួលកម្មវិធីសិក្សាទាំងរយៈពេលវែង និងខ្លីចំនួន ៣១កម្មវិធី ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការអង្គភាពប្រើប្រាស់កងកម្លាំង និងសភាពការណ៍វិវត្តនៃបទល្មើសជាក់ស្តែង ក៏ដូចជាធ្វើឱ្យមានលក្ខណៈប្រហាក់ប្រហែលទៅនឹងកម្មវិធីអប់រំកម្រិតអាស៊ាន និងតំបន់ ។

-បានចុះ MoU ជាមួយមហាវិទ្យាល័យនគរបាលទីក្រុងឡុងដ៍ នៃប្រទេសអង់គ្លេស ។ អនុវត្តតាមខ្លឹមសារ MoU ក្រសួងបានរៀបចំកិច្ចប្រជុំអនឡាញជាមួយមហាវិទ្យាល័យនគរបាលទីក្រុងឡុងដ៍ ស្តីពីការធ្វើបច្ចុប្បន្នភាពនៃកម្មវិធីអប់រំថ្នាក់បរិញ្ញាបត្រភាសាអង់គ្លេសជំនាញកិច្ចការនគរបាល និងត្រួតពិនិត្យឡើងវិញផែនការសកម្មភាពរវាងបណ្ឌិត្យសភាននគរបាលកម្ពុជា និងមហាវិទ្យាល័យនគរបាលទីក្រុងឡុងដ៍ ។ ទន្ទឹមនេះ ក៏បានចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចការនគរបាលក្នុងគ្រារាតត្បាតនៃជំងឺកូវីដ-១៩ ដែលរៀបចំដោយមហាវិទ្យាល័យនគរបាលទីក្រុងឡុងដ៍ ចំនួន ០៥លើក ផងដែរ ។

-អនុវត្តវិន័យ និងទណ្ឌកម្មតាមគ្រប់រូបភាព ដល់និស្សិត សិក្ខាកាម និងសិស្សចំនួន ៤១៩រូប លុបឈ្មោះចេញពីវគ្គសិក្សា ៨៣រូប និងមិនផ្តល់សញ្ញាបត្រ វិញ្ញាបនបត្រចំនួន ០២រូប ។

-បាន និងកំពុងជំរុញអនុវត្តគម្រោងសាងសង់ ជួសជុលអគារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាបម្រើដល់ការងារបណ្តុះបណ្តាលកងកម្លាំងនៅបណ្ឌិត្យសភាននគរបាលកម្ពុជាចំនួន ០២គម្រោង អគារស្នាក់នៅរបស់សិក្ខាកាមនៅសាលានគរបាលជាតិភូមិភាគ២ ភូមិភាគ៣ និងភូមិភាគ៦ ចំនួន ០៣គម្រោង និងទីលានបាញ់គ្រាប់ពិតនៅសាលានគរបាលជាតិភូមិភាគ៣ ភូមិភាគ៤ និងភូមិភាគ៦ ចំនួន ០៣គម្រោង ។ (សូមមើលឧបសម្ព័ន្ធទី២៦)

## ២.១២-ការងារឥស្សរការ និងហិរញ្ញវត្ថុ

ក្នុងក្របខ័ណ្ឌនៃការពង្រឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមការទទួលខុសត្រូវរបស់ខ្លួន នៅក្នុងឆ្នាំ២០២០ នេះ ក្រសួងមហាផ្ទៃបានបន្តយកចិត្តទុកដាក់ជំរុញការផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធផង និងបើកវគ្គបណ្តុះបណ្តាលតម្រង់ទិសផង ដើម្បីបង្កើនសមត្ថភាពក្នុងការអនុវត្តថវិកា។ ក្រៅពីនោះ បានផ្សព្វផ្សាយសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០២០ និងផែនការសកម្មភាពលម្អិត ព្រមទាំងបើកវគ្គបណ្តុះបណ្តាលស្តីពីវិធាន និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ និងការអនុវត្តផែនការសកម្មភាពលម្អិតឆ្នាំ២០២០ ។ លើសពីនេះ ក៏បានរៀបចំបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន FMIS សម្រាប់បម្រើដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ។

**-អំពីការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ**

***+ផ្នែកសន្តិសុខសាធារណៈ ៖*** អនុវត្តឥណទានបាន ៩៩,៥៣% នៃឥណទានប្រចាំឆ្នាំ និងប្រមូលចំណូលបង់ចូលថវិកាជាតិបាន ៤៩,១៩% នៃផែនការឆ្នាំ។ អនុវត្តកិច្ចលទ្ធកម្មចំនួន ៧០គម្រោង និងរៀបចំនីតិវិធីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវរថយន្ត ២៧០គ្រឿង ទោចក្រយានយន្ត ៤៩៤គ្រឿង កប៉ាល់ ០៤គ្រឿង នាវា ០២គ្រឿង និងម៉ាស៊ីនភ្លើង ១៤គ្រឿង ព្រមទាំងរៀបចំនីតិវិធីជម្រុះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវអគារចំនួន ១៤ខ្នង រថយន្ត ៣០៩គ្រឿង ទោចក្រយានយន្ត ១.២៧៧គ្រឿង និងមធ្យោបាយ សម្ភារៈបរិក្ខារហួសសុពលភាពមួយចំនួនទៀត ។

***+ផ្នែករដ្ឋបាលទូទៅ ៖*** អនុវត្តឥណទានបាន ៩៩,៨៤% នៃឥណទានប្រចាំឆ្នាំ ។ អនុវត្តកិច្ចលទ្ធកម្មចំនួន ២៤គម្រោង និងបញ្ចប់នីតិវិធីដោះដូរ និងផ្ទេរអចលនទ្រព្យចំនួន ០២គម្រោង ។

**-ការផ្គត់ផ្គង់ភស្តុភារ និងស្រាវជ្រាវឧបករណ៍ សម្ភារៈបច្ចេកទេស** ៖ ការផ្គត់ផ្គង់សម្ភារៈ ប្រេងឥន្ធនៈ ស្បៀង ឯកសណ្ឋាន និងឧបករណ៍ សម្ភារៈបច្ចេកទេស គឺបានរ៉ាប់រងយ៉ាងល្អប្រសើរ បម្រើដល់កិច្ចប្រតិបត្តិការតាមវិស័យការងារ ។ ជាក់ស្តែង បានផ្គត់ផ្គង់ប្រេងសាំងចំនួន ៦.៧៦៤.២៦៥លីត្រ ប្រេងម៉ាស៊ូត ២.៧២០.០៩៩លីត្រ ប្រេងម៉ាស៊ីន ១៦.២០៣លីត្រ ប្រេងម៉ាស៊ីនស៊ុបពែរ ២០.២៩០លីត្រ ប្រេងសាំងស៊ុបពែរ ២៤៨.៥៨៥លីត្រ អង្ករគោលដៅ ៧២៦.៥១១គ.ក្រ មីកញ្ចប់ ៣២.៤៥២កេសតូច និងត្រីខកំប៉ុង ៣.៤៩៨កេស ។ ទន្ទឹមនេះ ក៏បានផ្គត់ផ្គង់ឯកសណ្ឋាន លក្ខណៈសញ្ញាស័ក្តិ សម្ភារៈបន្ទាប់បន្សំ សម្ភារៈប្រើប្រាស់ ស្បៀងក្រៀម សម្ភារៈការិយាល័យ សម្ភារៈសង្ហារិម និងសម្ភារៈបច្ចេកទេសក្នុងគោលរបបឆ្នាំ២០២០ ទាន់ផែនការកំណត់ ព្រមទាំងដឹកជញ្ជូនទៅតាមបណ្តាគោលដៅចំនួន ៣០៩លើក ។

ដោយឡែក បានបញ្ចប់ការសិក្សាបទដ្ឋានបច្ចេកទេសបម្រើឱ្យការងារជំនាញរបស់កងកម្លាំងនគរបាលជាតិចំនួន ១០មុខ និងធ្វើបច្ចុប្បន្នភាពឧបករណ៍សម្ភារៈបច្ចេកទេសនៅតាមអង្គភាពចំនួន ១០អង្គភាព ។

**-អំពីការងារស្ថាបនា** ៖ ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានបន្តខិតខំសាងសង់សំណង់គ្រប់ប្រភេទសម្រាប់ជាជម្រក កន្លែងធ្វើការ-សិក្សារបស់មន្ត្រីក្រោមឱវាទ ការប្រតិបត្តិការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសម្រាប់ទ្រទ្រង់ដល់ការអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ។ ជាក់ស្តែង បាន និងកំពុងដំណើរការគម្រោងសាងសង់ ជួសជុលអគារចំនួន ២០គម្រោង ស្មើអគារចំនួន ១០៥ខ្នង (បញ្ចប់ជាស្ថាពរ ១៦គម្រោង ស្មើអគារ ៩០ខ្នង) និងបានបញ្ចប់គម្រោងសាងសង់ផ្លូវថ្នល់ ស្ពាន លូ ចំនួន ១៩គម្រោង ស្មើ ៦៨.២៣៤ម៉ែត្រ ។

**-ការងារសុខាភិបាល** ៖ ទន្ទឹមនឹងការខិតខំពិនិត្យ ព្យាបាលជំងឺទាំងមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងប្រជាពលរដ្ឋ ក្រសួងក៏បានយកចិត្តទុកដាក់ទៅលើការបង្ការ ទប់ស្កាត់ជំងឺឆ្លងនានា ដោយធ្វើការចុះផ្សព្វផ្សាយអប់រំសុខភាពជាប្រចាំនៅតាមអង្គភាពប្រតិបត្តិការនីមួយៗ និងខិតខំជំរុញលើកកម្ពស់ការងារផ្គត់ផ្គង់ឱសថ បរិក្ខារវេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ចាំបាច់នានាផងដែរ។ <u>**កត់សម្គាល់៖**</u> បានពិនិត្យ ព្យាបាលជំងឺកងកម្លាំងនគរបាលជាតិចំនួន ៤៣.២៧៥នាក់ ចុះគាំទ្រការងារអប់រំសុខភាពប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់នៅស្នងការដ្ឋាននគរបាលខេត្តចំនួន ១២ខេត្ត ព្រមទាំងបានចែកមុងចំនួន ៧.៤០០មុង ចាត់បញ្ជូនមន្ត្រីចំនួន ៩៦រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី វិធានការទប់ស្កាត់ជំងឺកូវីដ-១៩ រៀបចំសិក្ខាសាលាស្តីពី សុខភាពនគរបាលចំនួន ០៣លើក និងទទួលសម្ភារៈវេជ្ជសាស្ត្រសម្រាប់បង្ការ ទប់ស្កាត់វីរុសកូវីដ-១៩ ពីក្រសួង ស្ថាប័ននានាចំនួន ០[illegible]លើក ។

**-ការងារអប់រំ ផ្សព្វផ្សាយព័ត៌មាន** ៖ ក្នុងឆ្នាំ២០២០ បានផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ និងគ្រូជំនាញក្នុងកម្មវិធីនាទីសន្តិសុខមាតុភូមិតាមស្ថានីយទូរទស្សន៍ជាតិ ទូរទស្សន៍ឯកជន និងទូរទស្សន៍ប្រជាប្រិយចំនួន ៥២៥

លើក ស្មើ ៣.៤៨៥អត្ថបទ ។ ក្រៅពីការចាក់ផ្សាយព័ត៌មានតាមទូរទស្សន៍ ក្រសួងក៏បានធ្វើការផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គមផងដែរ និងបោះពុម្ពចែកផ្សាយទស្សនាវដ្តីមិត្តនគរបាលជាតិចំនួន ០៦លេខ ស្មើ ៤៥.០០០ ក្បាល និងទស្សនាវដ្តីក្រសួងមហាផ្ទៃចំនួន ១២លេខ ស្មើ ២៥.២០០ក្បាល ។

## ២.១៣-ការងារអធិការកិច្ច

ក្នុងឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានទទួលរបាយការណ៍បំភ្លឺពីបណ្តារាជធានី ខេត្តចំនួន ៣៥៧របាយការណ៍ និងពាក្យបណ្តឹងចំនួន ១.២២១សំណុំរឿង គិតទាំងបណ្តឹងដែលនៅសេសសល់ពីឆ្នាំមុនចំនួន ៣៧៥សំណុំរឿង សរុបបណ្តឹងចំនួន ១.៥៩៦សំណុំរឿង ក្នុងនោះ រួមមាន ៖

-**ផ្នែករដ្ឋបាល** ៖ របាយការណ៍បំភ្លឺពីបណ្តារាជធានី ខេត្តចំនួន ១៤៧របាយការណ៍ និងបណ្តឹងចូលថ្មីចំនួន ៦៦៦សំណុំរឿង រួមទាំងបណ្តឹងនៅសល់ពីឆ្នាំមុនចំនួន ២២០សំណុំរឿង សរុបបណ្តឹងចំនួន ៨៨៦សំណុំរឿង ។

-**ផ្នែកនគរបាល** ៖ របាយការណ៍បំភ្លឺពីបណ្តារាជធានី ខេត្តចំនួន ២១០របាយការណ៍ និងបណ្តឹងចូលថ្មីចំនួន ៥៥៥សំណុំរឿង រួមទាំងបណ្តឹងនៅសល់ពីឆ្នាំមុនចំនួន ១៥៥សំណុំរឿង សរុបបណ្តឹងចំនួន ៧១០សំណុំរឿង ។

ក្នុងចំណោមបណ្តឹងដែលទទួលបានចំនួន ១.២២១សំណុំរឿង មាន ៤៨២សំណុំរឿង ពាក់ព័ន្ធនឹងវិវាទរវាងប្រជាពលរដ្ឋ ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីនគរបាលជាតិ ៧២៥សំណុំរឿង ពាក់ព័ន្ធនឹងការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីនគរបាល និង ១៤សំណុំរឿង ពាក់ព័ន្ធនឹងវិវាទរវាងមន្ត្រីរាជការ ជាមួយមន្ត្រីរាជការ ។

ជាលទ្ធផល ក្រសួងបានដោះស្រាយបញ្ចប់ និងបង្វែរបណ្តឹងជូនទៅស្ថាប័នពាក់ព័ន្ធ និងសាមីបណ្តឹងវិញ សរុបចំនួន ១.២៩១សំណុំរឿង នៅសល់បណ្តឹងចំនួន ៣០៥សំណុំរឿងទៀត កំពុងធ្វើការអង្កេតស្រាវជ្រាវ និងបន្តដោះស្រាយតាមនីតិវិធី ។ ទន្ទឹមនេះ ក្រសួងក៏បានចុះអធិការកិច្ចលើសេចក្តីជូនដំណឹងនានាដែលក្រសួងមហាផ្ទៃបានដាក់ចេញនាពេលកន្លងមកចំនួន ៦៧សជណ ផងដែរ។

ផ្អែកតាមការចុះដោះស្រាយពាក្យបណ្តឹង និងខ្លឹមសាររបាយការណ៍ស្រាយបំភ្លឺ សង្កេតឃើញថា សារព័ត៌មានមួយចំនួន បានបង្ហាញច្បាស់នូវភាពខ្វះចន្លោះក្នុងការអនុវត្តតួនាទី ភារកិច្ច របស់មន្ត្រីរាជការមួយចំនួនតូច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះ ក៏ពិនិត្យឃើញបណ្តាសារព័ត៌មានមួយចំនួនទៀត បានចុះផ្សាយព័ត៌មានមិនពិត និង/ឬគ្មានប្រភពច្បាស់លាស់ ជារឿយៗ ដែលបានធ្វើឱ្យសាធារណជនមានការយល់ច្រឡំ និងជះឥទ្ធិពលមិនល្អដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីរាជការ ។

## ២.១៤-ការងារសវនកម្មផ្ទៃក្នុង

គោលបំណងចម្បងនៃការចុះធ្វើសវនកម្មតាមបណ្តាគោលដៅសវនដ្ឋានចំណុះក្រសួងមហាផ្ទៃ គឺដើម្បីតម្រង់ទិស និងកែលម្អប្រព័ន្ធប្រតិបត្តិការផ្ទៃក្នុងឱ្យអនុលោមតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយផ្តោតជាសំខាន់លើការស្វែងរកហានិភ័យ ចំណុចខ្លាំង ចំណុចខ្សោយ ព្រមទាំងបញ្ហាប្រឈមនានា ដើម្បីប្រមូលផ្តុំដាក់ចេញវិធានការ ក្នុងការឈានទៅលុបបំបាត់ចំណុចអសកម្មទាំងឡាយឱ្យបានជាអតិបរមា ផ្តោតលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការងារគ្រប់គ្រងបញ្ជីបុគ្គលិក និងការងារគ្រប់គ្រងជនជាប់ឃុំ ។ នៅក្នុងផែនការឆ្នាំ២០២០ ក្រសួងបានគ្រោងចុះធ្វើសវនកម្មចំនួន ១.៥៧៥គោលដៅ (ផ្នែករដ្ឋបាលស៊ីវិល ១៥៣គោលដៅ សន្តិសុខសាធារណៈ ១.៣៩៤គោលដៅ និងផ្នែកពន្ធនាគារ ២៨គោលដៅ) តែដោយសារស្ថិតក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីដ-១៩ គោលដៅដែលគ្រោងខាងលើ ត្រូវបានផ្អាកដំណើរការ ។ ទោះបីផែនការ

ចុះធ្វើសវនកម្មត្រូវបានផ្អាកដំណើរការក្តី ដើម្បីពង្រឹងសមត្ថភាពមន្ត្រីសវនកម្ម ក៏ដូចជាត្រៀមលក្ខណៈសម្រាប់គាំទ្រដល់ការចុះធ្វើសវនកម្មនៅពេលស្ថានភាពធូរស្រាលឡើងវិញ ក្រសួងបានពិនិត្យ រៀបចំបែងចែកឡើងវិញនូវតំបន់សវនដ្ឋាននៅតាមភូមិសាស្ត្ររាជធានី ខេត្ត និងបានរៀបចំវគ្គបណ្តុះបណ្តាលតាមអនឡាញចំនួន ០២លើក (ទី១.ស្តីពីសវនកម្ម សមិទ្ធកម្មលើគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន និង ទី២.ស្តីពីកិច្ចលទ្ធកម្មសាធារណៈ ថវិកាកម្មវិធី និងសវនកម្ម) ។

ក្រៅពីការងារសវនកម្ម ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសុចរិតភាព និងអភិបាលកិច្ចល្អផងដែរ ដោយបានសហការជាមួយអង្គការជាដៃគូជាតិ និងអន្តរជាតិ ជំរុញកិច្ចការអាទិភាពសំខាន់ៗដូចជា ការរៀបចំវេទិកាសាធារណៈ និងការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពិសេសកម្មវិធីកំណែទម្រង់នានាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ។

### ២.១៥-ការងារទំនាក់ទំនងអន្តរជាតិ

ទោះបីប្រឈមនឹងស្ថានភាពដ៏ស្មុគស្មាញក្រោមវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ កន្លងទៅនេះ ក្រសួងមហាផ្ទៃនៅតែបន្តយកចិត្តទុកដាក់ជំរុញ និងលើកកម្ពស់ការងារទំនាក់ទំនងអន្តរជាតិយ៉ាងសកម្ម តាមរយៈការបន្តអនុវត្តយន្តការសហប្រតិបត្តិការប្រចាំឆ្នាំក្នុងក្របខ័ណ្ឌទ្វេភាគី ការចូលរួមក្នុងវេទិកាកិច្ចប្រជុំអន្តរជាតិ និងការជួបប្រាស្រ័យទំនាក់ទំនងជាមួយបណ្តាអង្គទូត អង្គការអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍនានា ក្នុងគោលដៅពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យនៃការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ជាពិសេសវិស័យសន្តិសុខ និងកិច្ចការពាក់ព័ន្ធនឹងការសម្របសម្រួលការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ជាក់ស្តែងក្នុងឆ្នាំ២០២០ នេះ ក្រសួងមហាផ្ទៃបានចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការទ្វេភាគីចំនួន ០២ ជាមួយស្ថាប័នសន្តិសុខជាសមភាគី គឺ៖ ទី១-ផែនការកិច្ចសហប្រតិបត្តិការឆ្នាំ២០២០ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម និងទី២-កំណត់ហេតុកិច្ចសហប្រតិបត្តិការឆ្នាំ២០២០ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ។ តាមរយៈប្រព័ន្ធ I-24/7 ក្រសួងបានទទួលសំណើ ២៥៣ករណី ក្នុងនោះឆ្លើយតបទៅសាមីប្រទេសវិញបាន ៩៩ករណី ។ អនុវត្តផែនការសម្រាប់ឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងមហាផ្ទៃកម្ពុជា ជាមួយក្រសួងសន្តិសុខសាធារណៈចិន (គិតពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០) បង្ក្រាបបទល្មើសបង្កដោយជនជាតិចិនបាន ២៣០ករណី ឃាត់ខ្លួនជនសង្ស័យបាន ១.៨៥៦នាក់ ស្រី ៧៦នាក់ (ក្នុងនោះ កសាងសំណុំរឿងបញ្ជូនទៅតុលាការផ្តន្ទាទោសដាក់ពន្ធនាគារនៅកម្ពុជា ៧៨៨នាក់)។

សមិទ្ធផលទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃកម្ពុជា ជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសជាមិត្ត ព្រមទាំងបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនបម្រើដល់ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេសការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ការជួយគាំទ្រគ្នាទៅវិញទៅមកលើការងារអភិវឌ្ឍធនធានមនុស្ស និងការគាំទ្រផ្នែកសម្ភារៈបច្ចេកទេស ។

ក្រៅពីកិច្ចការខាងលើនេះ ក្រសួងមហាផ្ទៃក៏បានខិតខំពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នសន្តិសុខក្នុងតំបន់ និងអន្តរជាតិ តាមរយៈការបន្តពិនិត្យ ពិភាក្សាលើឯកសារនានា ដើម្បីបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀត និងបានបន្តធ្វើបច្ចុប្បន្នភាពឯកសារសហប្រតិបត្តិការដែលមានស្រាប់ ជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសជាមិត្ត សំដៅកែលម្អខ្លឹមសារឱ្យស្របតាមបរិបទជាក់ស្តែងនៃសភាពការណ៍

សន្តិសុខសកលលោក និងដើម្បីឆ្លើយតបបានទៅនឹងសភាពការណ៍ជាក់ស្តែងក្នុងតំបន់ ក៏ដូចជាឆ្លើយតបបានសមស្របដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងសង្គមជាតិកម្ពុជា ។

យ៉ាងណាមិញ ក៏គួររំលឹកដែរថា ដោយសារបញ្ហាវិបត្តិជំងឺកូវីដ-១៩ មានយន្តការសហប្រតិបត្តិការទ្វេភាគីមួយចំនួន ត្រូវបានខកខានមិនបានអនុវត្ត ក្នុងនោះមានជាអាទិ៍ ៖ ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់ ការផ្លាស់ប្តូរគណៈប្រតិភូជំនាញ ការចាត់បញ្ជូនសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស និងការឧបត្ថម្ភគាំទ្រផ្នែកសម្ភារៈបច្ចេកទេស ដែលកិច្ចការទាំងនេះ មានសារៈសំខាន់បម្រើដល់វិស័យសន្តិសុខកម្ពុជា ។ ទន្ទឹមនេះ ក៏មានព្រឹត្តិការណ៍អន្តរជាតិធំៗមួយចំនួនត្រូវបានលើកពេលផងដែរ ដូចជា សន្និសីទអាស៊ានណាប៉ូលលើកទី៤០ កិច្ចប្រជុំកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម លើកទី១១ និងកិច្ចប្រជុំប្រចាំឆ្នាំជាមួយស្ថាប័នសន្តិសុខ នៃប្រទេសសមភាគីមួយចំនួនទៀត ដែលក្រសួងមហាផ្ទៃត្រូវធ្វើជាម្ចាស់ផ្ទះ ។

(សូមមើលឧបសម្ព័ន្ធទី២៧)

### ២.១៦-ការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន **ICT** បាន និងកំពុងផ្តល់នូវអត្ថប្រយោជន៍ដែលមានវិសាលភាពយ៉ាងទូលំទូលាយបម្រើដល់ការផ្តល់ព័ត៌មាន ការគ្រប់គ្រងទិន្នន័យ-ឯកសារ ការប្រកបអាជីវកម្ម និងកិច្ចប្រតិបត្តិការផ្សេងៗ ប៉ុន្តែទន្ទឹមគ្នានោះ ក៏មានភ្ជាប់មកជាមួយនូវគុណវិបត្តិគួរឱ្យព្រួយបារម្ភផងដែរ ពិសេសពាក់ព័ន្ធនឹងវិស័យសន្តិសុខ ។ យ៉ាងណាមិញ ក្រសួងមហាផ្ទៃ ដែលជាស្ថាប័នស្នូលទទួលខុសត្រូវលើការងារថែរក្សាសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សង្គម បាន និងកំពុងយកចិត្តទុកដាក់ក្នុងការជំរុញ លើកកម្ពស់វិស័យ **ICT** នេះ ដើម្បីបម្រើដល់បុព្វហេតុការងារនានាក្រោមការទទួលខុសត្រូវរបស់ខ្លួនផង ក៏ដូចជាចូលរួមគាំទ្រគោលនយោបាយរដ្ឋបាលឌីជីថលរបស់រាជរដ្ឋាភិបាល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤.០ ផង ។ ជាក់ស្តែង សកម្មភាព និងលទ្ធផលសំខាន់ៗ ដែលសម្រេចបាននៅក្នុងឆ្នាំ២០២០ នេះ រួមមាន ៖

- បានរៀបចំប្លង់ប្រព័ន្ធបច្ចេកទេសបណ្តាញមេសម្រាប់ទីស្តីការក្រសួងមហាផ្ទៃ និងរៀបចំរួចរាល់ សម្រាប់ក្របខ័ណ្ឌបច្ចេកទេសបណ្តាញបច្ចុប្បន្ន ក្នុងការបញ្ចូលគ្នាជាមួយប្រព័ន្ធបណ្តាញថ្មី **(NOC)** ។
- បាន និងកំពុងរៀបចំសេចក្តីព្រាងផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បម្រើដល់ការផ្តល់សេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ និងផែនការយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន **ICT** របស់ក្រសួងមហាផ្ទៃ ។
- បាន និងកំពុងសិក្សាលើមូលដ្ឋានចាំបាច់នានា ដើម្បីឈានដល់បង្កើតលេខាធិការដ្ឋាននៃក្រុមការងារគ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ ។
- បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំដំឡើងល្បឿនអ៊ីនធឺណែតក្នុងទីស្តីការក្រសួងមហាផ្ទៃ ពី ១០០Mb ដល់ ៣០០Mb ក្នុងនោះ បានផ្គត់ផ្គង់សេវាអ៊ីនធឺណែតដល់អគារនានាក្នុងទីស្តីការក្រសួងមហាផ្ទៃបានចំនួន ៥០បន្ទប់ ។ ជាមួយគ្នានេះ ក៏បានរៀបចំប្រព័ន្ធទូរស័ព្ទ Hotline លេខ ១៧៧ នៅមជ្ឈមណ្ឌលប្រចាំបញ្ជា ដើម្បីទទួលព័ត៌មានទាន់ហេតុការណ៍ និងឆ្លើយតបទៅប្រជាពលរដ្ឋ (បច្ចុប្បន្ន កំពុងបន្តរៀបចំតភ្ជាប់បណ្តាញនេះ ទៅបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស) ។
- បានបង្កើតប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍នៅលើទូរស័ព្ទចល័ត (ទាំង **IOS** និង **Android**) ដើម្បីពង្រីកវិសាលភាពផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងសមត្ថកិច្ចក្រសួងមហាផ្ទៃ ឱ្យកាន់តែទូលំទូលាយ ។

- បានរៀបចំវគ្គបំប៉នជំនាញ ICT ដល់មន្ត្រីរាជការចំណុះក្រសួងមហាផ្ទៃ (ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ចំនួន ១១វគ្គ មានសិក្ខាកាមចូលរួម ៤៧៣រូប និងរៀបចំសិក្ខាសាលាតាមអនឡាញស្តីពីសន្តិសុខបណ្តាញអ៊ីនធឺណែត និងព័ត៌មាន ០១លើក សិក្ខាកាមចូលរួម ២៥២រូប ។
- បានរៀបចំបន្ទប់ពិសោធន៍សម្រាប់បម្រើដល់ការងារបណ្តុះបណ្តាលលើជំនាញពាក់ព័ន្ធនឹងវិស័យ ICT និងបង្កើតក្រុមការងារបច្ចេកទេសត្រួតពិនិត្យ ថែទាំប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក និងហេដ្ឋារចនាសម្ព័ន្ធ ICT ក្រសួងមហាផ្ទៃ ។
- បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធកត់ត្រាទិន្នន័យបទល្មើស E-Crime 2020 និងប្រព័ន្ធគ្រប់គ្រងបទល្មើសចរាចរណ៍ ។
- ស្រាវជ្រាវ កំណត់មុខសញ្ញាប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានចំនួន ១.៣០៩ករណី។

## II-សេចក្តីសន្និដ្ឋាន

ឆ្នាំ២០២០ កន្លងទៅនេះ បានផ្តល់នូវមេរៀនបទពិសោធន៍ជាច្រើនក្នុងការពង្រឹងភាពជាម្ចាស់របស់កម្ពុជាតស៊ូជំនះបាននូវបញ្ហាប្រឈមនានា ដើម្បីរក្សាប្រក្រតីភាពនៃជីវភាពសង្គមលើគ្រប់វិស័យ និងការបន្តជំរុញកិច្ចការនានាឱ្យសម្រេចបានតាមគោលបំណងដែលបានគ្រោងទុក ក្នុងកាលៈទេសៈទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជំងឺឆ្លងរាតត្បាតសកល និងគ្រោះធម្មជាតិ។ អាជ្ញាធរមានសមត្ថកិច្ច និងកងកម្លាំងនគរបាលជាតិ ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ បានចូលរួមយ៉ាងសំខាន់ក្នុងការកសាងសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល ដោយបានធ្វើជាស្នូលក្នុងការរក្សាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គម ខណៈអនុវត្តវិធានសុខាភិបាលក្នុងការបង្ការ ទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ការទប់ស្កាត់ និងបង្ក្រាបបំបាត់ប្រសិទ្ធភាពឧបាយកលបំផុសបំផុល ញុះញង់បំបែកបំបាក់សាមគ្គីភាពផ្ទៃក្នុង និងប៉ុនប៉ងបង្កភាពចលាចលវឹកវរក្នុងសង្គម ក្នុងគោលបំណងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់តាមរបៀបបដិវត្តន៍ពណ៌ ពីសំណាក់ក្រុមឧទ្ទាមក្រៅច្បាប់នៅក្នុង និងក្រៅប្រទេស និងការសហការជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត ។ ទន្ទឹមនេះ អាជ្ញាធរដែនដី និងកងកម្លាំងនគរបាលជាតិ ក៏បានសហការជាមួយកងយោធពលខេមរភូមិន្ទ ខិតខំប្រឹងប្រែងរួមគ្នាថែរក្សា ការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដីកម្ពុជា បានយ៉ាងគត់មត់ ។

ទន្ទឹមនឹងការរ៉ាប់រងបំពេញតួនាទីក្នុងស្ថានភាពការណ៍ខាងលើ អាជ្ញាធរដែនដី និងកងកម្លាំងនគរបាលជាតិ ក៏បានបន្តខិតខំជំរុញអនុវត្តគោលនយោបាយ"**ភូមិ ឃុំ មានសុវត្ថិភាព**" ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទក្នុងសង្គមដោយមិនខ្លាចនឿយហត់ ។ បទល្មើសជារួម (ធៀបនឹងឆ្នាំ២០១៩) ទោះបីមានការកើនឡើង ២% ប៉ុន្តែសកម្មភាពបង្ក្រាបមានកម្រិតខ្ពស់រហូតដល់ ៩០% នៃបទល្មើសដែលកើតមាន រីឯបទល្មើសព្រហ្មទណ្ឌដែលធ្វើឱ្យប៉ះពាល់ដល់ចិត្តសាស្ត្រសង្គម មានការថយចុះ ៣% ខណៈគ្រោះថ្នាក់ចរាចរណ៍ក៏មានការថយចុះ ២៣% ផងដែរ ។

ផ្អែកលើយន្តការដែលក្រសួងមហាផ្ទៃបានបង្កើតឡើង និងការពង្រឹងតួនាទីដឹកនាំ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ក្នុងការជំរុញសកម្មភាពការងារផ្សព្វផ្សាយអប់រំ ការងារបង្ការ ទប់ស្កាត់ បង្ក្រាប និងការអនុវត្តវិធានការនានាជាច្រើនទៀត ធ្វើឱ្យដំណើរការជាប់ជាប្រចាំ ដោយមានការគាំទ្រ និងការចូលរួមកាន់តែច្រើនពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ទាំងលើយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ការងារបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សកម្មភាពក្មេង

ទំនើង ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងវិធានការបង្ការ ទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ គ្រោះអគ្គិភ័យ និងអាវុធជាតិផ្ទុះ...។

ដើម្បីអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ការគ្រប់គ្រងជនបរទេស ត្រូវបានបង្កើនការប្រុងប្រយ័ត្នខ្ពស់ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងការចេញចូលនៅតាមច្រកទ្វារនានា និងការគ្រប់គ្រងវត្តមានស្នាក់នៅរបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពមន្ត្រី ការតាមដានត្រួតពិនិត្យការអនុវត្តការងារ និងការខិតខំបំពាក់មធ្យោបាយ ឧបករណ៍ សម្ភារៈបច្ចេកទេស និងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗបម្រើឱ្យការងារគ្រប់គ្រងជនបរទេស និងសម្ភារៈការពារការឆ្លងជំងឺកូវីដ-១៩ ។ ផ្អែកលើកិច្ចខិតខំប្រឹងប្រែងទាំងនេះ បានរួមចំណែកទាំងក្នុងការទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ មកក្នុងប្រទេស និងការចម្លងជំងឺនេះទ្រង់ទ្រាយធំចូលក្នុងសហគមន៍ និងការកាត់បន្ថយបទល្មើសគ្រប់ប្រភេទដែលបង្កដោយជនបរទេស ។

ការងារអត្តសញ្ញាណកម្ម មានសារៈសំខាន់ និងជាគន្លឹះពាក់ព័ន្ធវិស័យការងារជាច្រើនរបស់រាជរដ្ឋាភិបាល។ ជារួម ការងារនេះបានបង្កប់នូវចរិតលក្ខណៈពិសេស ០២ គឺការគ្រប់គ្រងប្រជាពលរដ្ឋ និងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ។ ការងារអត្តសញ្ញាណកម្ម ត្រូវបានបន្តជំរុញទាំងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ ការផ្គត់ផ្គង់ឧបករណ៍ សម្ភារៈបច្ចេកទេស ការបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រី ការពង្រឹងសមត្ថភាពស្ថាប័ន និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងអត្តសញ្ញាណបុគ្គល ឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ ក៏ដូចជាបម្រើដល់កិច្ចអភិវឌ្ឍលើវិស័យនានាដែលប្រើប្រាស់ទិន្នន័យបុគ្គល ។ ទន្ទឹមនេះ សមិទ្ធផលដែលសម្រេចបានកន្លងមកក្នុងការងារអត្តសញ្ញាណកម្ម បានរួមចំណែកដ៏សំខាន់ក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏សម្រេចបានសមិទ្ធផលនានាជាច្រើន ។ ជាក់ស្តែង កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(២០១០-២០២០) ត្រូវបានអនុវត្តបញ្ចប់នៅដំណាច់ឆ្នាំ២០២០ នេះ ជាមួយសមិទ្ធផលសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការផ្ទេរបុគ្គលិក ការកសាងសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់សមភាព សមធម៌យេនឌ័រក្នុងដំណើរការកំណែទម្រង់ និងការផ្តល់សេវាសាធារណៈមានការឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា។ ដោយឡែក ការងារសំខាន់ៗដែលសម្រេចបាននៅក្នុងឆ្នាំ២០២០ នេះ រួមមាន ការរៀបចំ និងអនុវត្តរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការរៀបចំ និងដាក់ឱ្យដំណើរការមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ការរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការផ្ទេរមុខងារ និងធនធាន និងការបែងចែកចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធរវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលក្រុង ស្រុក ការរៀបចំការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យស្របតាមរចនាសម្ព័ន្ធថ្មី និងការសម្រេចបានឯកសារទស្សនទានសម្រាប់ការតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ។

ក្រៅពីសមិទ្ធផលខាងលើនេះ នៅមានសមិទ្ធផលជាច្រើនទៀតដែលអគ្គនាយកដ្ឋាន និងអង្គភាពនានានៃក្រសួងមហាផ្ទៃខិតខំសម្រេចបាន ដូចជា ការងារកសាងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌ

យុទ្ធសាស្ត្រ ការងារបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ការងារគ្រប់គ្រងពន្ធនាគារ ការងារអធិការកិច្ច និងដោះស្រាយពាក្យបណ្តឹង និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ ការងារធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ការងារអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន កិច្ចសហប្រតិបត្តិការអន្តរស្ថាប័នជាមួយក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា និងការងារទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការផ្លាស់ប្តូរបទពិសោធន៍ជាមួយប្រទេសនៅក្នុង និងក្រៅតំបន់ ពាក់ព័ន្ធវិស័យសន្តិសុខ និងការធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនឹងសមិទ្ធផលខាងលើនេះ ក៏នៅមានសេសសល់បញ្ហាប្រឈមមួយចំនួន តម្រូវឱ្យមានការយកចិត្តទុកដាក់ដោះស្រាយឱ្យបានសមស្របបន្ថែមទៀត ក្នុងនោះបញ្ហាចម្បងៗ មាន ៖

វិបត្តិនៃជំងឺកូវីដ-១៩ ជាសកល និងការវិវត្តប្រែប្រួលឆាប់រហ័សនៃសភាពការណ៍អន្តរជាតិ បណ្តាលមកពីការប្រកួតប្រជែងកាន់តែស្រួចស្រាល់រវាងប្រទេសមហាអំណាច នឹងបន្តជះឥទ្ធិពលអវិជ្ជមានដល់សន្តិសុខក្នុងតំបន់ រួមទាំងកម្ពុជាយើងផងដែរ ។ ទន្ទឹមនេះ ក្នុងផ្ទៃក្នុងប្រទេស ពួកឧទ្ទាមក្រៅច្បាប់នៅតែចិញ្ចឹមមហិច្ឆិតាប៉ុនប៉ងបង្កភាពចលាចលវឹកវរក្នុងសង្គម ដើម្បីឈានទៅផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់តាមរបៀបបដិវត្តន៍ពណ៌ ផ្អែកលើសភាពការណ៍នេះ តម្រូវឱ្យអាជ្ញាធរ កងកម្លាំងនគរបាលជាតិ និងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់តាមដានក្តាប់សភាពការណ៍ឱ្យបានជាប់ជាប្រចាំ ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដោយមិនត្រូវធ្វេសប្រហែសឡើយ។ ទន្ទឹមនេះ ការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ បទល្មើសគ្រឿងញៀនខុសច្បាប់ អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ បទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ បទល្មើសឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសតាមបច្ចេកវិទ្យា ទោះបីកន្លងមក មានការខិតខំប្រឹងប្រែងសម្រេចបានសមិទ្ធផលជាច្រើនក្តី ប៉ុន្តែបទល្មើសឧក្រិដ្ឋ បទល្មើសគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ នៅមានបញ្ហាប្រឈមស្មុគស្មាញ ដែលទាមទារត្រូវធ្វើការពិនិត្យ វាយតម្លៃរកឱ្យឃើញមូលហេតុដែលនាំឱ្យមានបញ្ហាប្រឈមទាំងនេះ ដើម្បីដាក់ចេញវិធានការឱ្យបានសមស្របថែមទៀត ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅជួបប្រទះបញ្ហាប្រឈមជាចម្បងមួយចំនួនពាក់ព័ន្ធការតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយដែលបានស្រុះស្រួលឯកភាពគ្នារបស់ក្រសួង ស្ថាប័នខ្លះ ក្នុងដំណើរការកំណែទម្រង់ពិសេសពាក់ព័ន្ធការផ្ទេរមុខងារ និងធនធាន និងការចូលរួមគាំទ្រដល់ការគ្រប់គ្រង ការចាត់ចែងអនុវត្តមុខងារ និងធនធានដែលបានផ្ទេររួចហើយទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធអភិបាលកិច្ចបែបវិមជ្ឈការ។ ប្រការនេះបានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នៃរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងភាពជាម្ចាស់របស់មូលដ្ឋាន ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនក៏មិនទាន់បានយកចិត្តទុកដាក់ខ្ពស់ក្នុងការកែប្រែទម្លាប់ឥរិយាបថ និងការពង្រឹងសមត្ថភាពក្នុងការបំពេញការងារតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ជាហេតុធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃកំណែទម្រង់ ។ ការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលនៅថ្នាក់ក្រោមជាតិ អំពីវិធាន និងគោលការណ៍នៃការគ្រប់គ្រងបែបវិមជ្ឈការ និងការងារជំនាញក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន នៅមានកម្រិតនៅឡើយ ។

ចំពោះការងារផ្សេងៗទៀតក្នុងសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ក៏នៅមានសេសសល់បញ្ហាប្រឈមផងដែរ ក្នុងនោះប្រមូលផ្តុំសំខាន់គឺ បញ្ហាសមត្ថភាព ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន រចនាសម្ព័ន្ធ ប្រព័ន្ធ និងមធ្យោបាយ ឧបករណ៍សម្រាប់បម្រើការងារស្នូលនៅតាមអង្គភាពនីមួយៗ ។ បញ្ហាប្រឈមទាំងនេះ

ទាមទារត្រូវសិក្សារៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលខ្លី និងរយៈពេលពីមធ្យមទៅរយៈពេលវែង ដើម្បីដាក់ចេញវិធានការឆ្លើយតបឱ្យបានសមស្រប ។

## III-ទិសដៅការងារឆ្នាំ២០២១

ឆ្នាំ២០២១ នេះ ជាឆ្នាំទី៣ នៃការអនុវត្តកម្មវិធីកំណែទម្រង់ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា និងជាឆ្នាំដំបូងនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ហើយក៏ជាឆ្នាំដែលប្រទេសយើងត្រូវត្រៀមលក្ខណសម្បត្តិនានាសម្រាប់បម្រើដល់ការរៀបចំការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី៥ នាឆ្នាំ២០២២ ផងដែរ ។ អាស្រ័យហេតុនេះ មន្ត្រីរដ្ឋបាលស៊ីវិល កងកម្លាំងនគរបាលជាតិ និងរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ត្រូវបន្តរួមគ្នាសម្រេចឱ្យបាននូវទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន ០៤ ដូចតទៅ ៖

**ទីមួយ ៖** បន្តខិតខំថែរក្សា ការពារឱ្យបាននូវឯករាជ្យ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី សន្តិភាព និងស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បង្កបរិយាកាសដល់ការស្តារឡើងវិញនូវផលប៉ះពាល់នានាបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់នាចុងរដូវវស្សាកន្លងមក និងធានាការពារ លើកស្ទួយសិទ្ធិ សេរីភាពគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិច្បាប់ជាធរមាន សំដៅជំរុញលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម លើគ្រប់វិស័យ ។

**ទីពីរ ៖** បន្តខិតខំជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ជាពិសេសការកែទម្រង់មន្ត្រីនគរបាលជាតិកម្ពុជា ការកែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) និងគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ដែលត្រូវដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២១ នេះ ។

**ទីបី ៖** បន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការដោះស្រាយសំណើ សំណូមពររបស់ប្រជាពលរដ្ឋ ក៏ដូចជាបញ្ហាប្រឈមនានានៅមូលដ្ឋាន សំដៅធានាការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងលើកិច្ចការគ្រប់វិស័យក្នុងសង្គម ។

**ទីបួន ៖** បន្តពង្រឹងការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងស្មើភាព ដើរទន្ទឹមនឹងការខិតខំពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអនុវត្តច្បាប់ ដើម្បីរួមគ្នាលុបបំបាត់នូវបាតុភាពអសកម្មនានា សំដៅបង្កើនជំនឿទុកចិត្តដល់ប្រជាពលរដ្ឋក្នុងការចូលរួមគោរព អនុវត្តច្បាប់ និងពង្រឹងយុត្តិធម៌ក្នុងសង្គម ។

ផ្អែកលើទិសដៅជាយុទ្ធសាស្ត្រខាងលើ កិច្ចការសំខាន់ៗដែលត្រូវយកចិត្តទុកដាក់អនុវត្តក្នុងឆ្នាំ២០២១ នេះ រួមមានជាអាទិ៍ ៖

### ១-ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បន្តសហការរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្តដែលបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ។

-បន្តសិក្សា ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ដែលនៅសេសសល់ និងសិក្សាស្រាវជ្រាវ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែម សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា ។

## ២-ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស

-រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កំណែទម្រង់មន្ត្រីនគរបាលជាតិកម្ពុជា និងមន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ ។

-បន្តជំរុញការវិភាគមុខងារ ដើម្បីកំណត់មុខដំណែង និងកំណត់ក្របខ័ណ្ឌសម្រាប់រយៈពេលខ្លី និងរយៈពេលពីមធ្យមទៅរយៈពេលវែង នៅតាមអគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃ ។

-បន្តរៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋាន និងអង្គភាពថ្នាក់ប្រហាក់ប្រហែលនានា ដោយរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃឱ្យបានច្បាស់លាស់ និងទៀងទាត់ ។

-បន្តពង្រឹងរបៀបរបបការងារនៅតាមអគ្គនាយកដ្ឋាន អង្គភាពថ្នាក់ប្រហាក់ប្រហែល និងអង្គភាពចំណុះ និងពង្រឹងការគ្រប់គ្រង និងការបំពេញការងាររបស់មន្ត្រី ទាំងមន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីនគរបាលជាតិ នៅគ្រប់លំដាប់ថ្នាក់ ។

-ពិនិត្យ កែលម្អផែនការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីនគរបាលជាតិ មន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងារ ឆ្លើយតបតាមការវិវត្តរីកចម្រើនរបស់សង្គម ។

-បន្តចាត់បញ្ជូនមន្ត្រីទៅធ្វើទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា និងសិក្សាឯកទេសនៅបរទេសតាមផែនការសហប្រតិបត្តិការជាមួយប្រទេសនានា ។

## ៣-អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ក-ការអភិវឌ្ឍគោលនយោបាយ ប្រព័ន្ធ និងរចនាសម្ព័ន្ធអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តសហការរៀបចំបញ្ចប់នូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ រយៈពេល ១០ឆ្នាំ (២០២១-២០៣០) និងសហការចូលរួមរៀបចំផែនការសកម្មភាពអនុវត្តកម្មវិធីជាតិនេះ ។

-បន្តពិនិត្យ កែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

-បន្តពង្រឹងនូវយន្តការនានាដែលគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

-បន្តសហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

-ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ដើម្បីជួយគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់រយៈពេលមធ្យម ។

-បន្តផ្តល់ការគាំទ្រដល់ដំណើរការការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរចនាសម្ព័ន្ធថ្មី ។

-រៀបចំក្របខ័ណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តទីក្រុងឆ្លាតវៃ ។

-បន្តសហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការគាំទ្រ និងតាមដាន ត្រួតពិនិត្យលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការរៀបចំឯកសារបច្ចេកទេស ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ ។

-ពិនិត្យ កែសម្រួលគោលការណ៍ណែនាំបច្ចេកទេសស្តីពី ការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យស្របតាមគោលនយោបាយស្តីពី ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-បន្តសហការជំរុញ និងលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន ក្នុងការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើតម្រូវការតាមមូលដ្ឋាននីមួយៗ ។

**ខ-ការផ្ទេរធនធានពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ**

-បន្តគាំទ្រ និងសម្របសម្រួលដល់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក សម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ។

-បន្តសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្ទេរទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈនានា ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ។

-បន្តសម្របសម្រួល និងពិនិត្យការអនុវត្តតាមលក្ខខណ្ឌនានា ដើម្បីក្រុង ស្រុក និងឃុំ សង្កាត់ អាចទទួលបានថវិកាវិភាជន៍ទាន់ពេលវេលា ជាពិសេសការអនុវត្តគម្រោងអភិវឌ្ឍដែលប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ព្រមទាំងកសាងសមត្ថភាព និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឱ្យមានសមត្ថភាព និងលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍនានា ។

-សិក្សា ពិនិត្យ និងកែសម្រួលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ។

-បន្តពង្រឹងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រួមទាំងការគ្រប់គ្រងបញ្ជីសារពើភណ្ឌ ឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់នៃច្បាប់ ។

-បន្តពង្រឹងការប្រើប្រាស់ថវិការបស់រាជធានី ខេត្ត និងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យចំគោលដៅ មានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

-បន្តសម្របសម្រួល និងកៀរគរដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ។

-បន្តតាមដានដំណើរការនៃការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**គ-ការផ្តល់សេវារដ្ឋបាល**

-បន្តតាមដាន ត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់ការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

-សិក្សា និងរៀបចំបែបបទ នីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលឃុំ សង្កាត់ ។

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចុះតាមដានការអនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការផ្តល់សេវារដ្ឋបាលរបស់អង្គភាព-ការិយាល័យច្រកចេញចូលតែមួយ ។

-បន្តគាំទ្របច្ចេកទេសលើការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាព និង ការិយាល័យច្រកចេញចូលតែមួយ ។

-បន្តគាំទ្របច្ចេកទេស និងចុះពង្រឹងការផ្តល់សេវារដ្ឋបាល ការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ព្រមទាំងបន្ត

រៀបចំបង្កើតប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញ (Online) នៅការិយាល័យច្រកចេញចូលតែមួយដែលមិនទាន់មានប្រព័ន្ធនេះ ។

-បន្តសហការផ្សព្វផ្សាយ ផ្តល់វគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីដែលទើបជ្រើសរើសថ្មី និងមន្ត្រីដែលកំពុងបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ អំពីគោលការណ៍ និងលិខិតបទដ្ឋានថ្មីៗ ទាក់ទិននឹងការអនុវត្តការងាររបស់ការិយាល័យទាំងនេះ ។

**ឃ-ការសម្របសម្រួល និងសហការអនុវត្តគម្រោងដោយផ្សែកនានា**

-បន្តសហការជាមួយដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពអនុវត្តគម្រោងដែលកំពុងដំណើរការក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ។

-ពង្រឹងយន្តការអនុវត្តគម្រោងឱ្យសម្រេចបានជោគជ័យតាមការរំពឹងទុក និងកាន់តែមានប្រសិទ្ធភាព ។

-បន្តសម្របសម្រួលជាមួយដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំបង្កើតគម្រោងថ្មីផ្សេងទៀត សម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងនោះរួមទាំងគម្រោងសាងសង់អគារសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) ផងដែរ ។

**ង-ការងារជំនាញដទៃទៀត**

**ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

-បន្តពិនិត្យ សិក្សា និងកែលម្អប្រព័ន្ធនីតិវិធី និងយន្តការគ្រប់គ្រងច្រកទ្វារព្រំដែន ។

-បន្តពិនិត្យលទ្ធភាពក្នុងការបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនថ្មី ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ និងជំរុញការអភិវឌ្ឍតំបន់ព្រំដែន ។

-សហការរៀបចំពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការនូវច្រកទ្វារអន្តរជាតិម៉ឺនជ័យ ។

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកសាងផែនការសកម្មភាពសម្រាប់ការសាងសង់ច្រាំងទន្លេបាសាក់ និងព្រែកជ្រៃធំ រយៈពេលវែង សំដៅការពារស្ថិរភាពច្រាំង និងខ្សែបន្ទាត់ព្រំដែន កុំឱ្យមានការប្រែប្រួល។

-បន្តជំរុញការងារផ្តល់ប័ណ្ណព្រំដែន ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋចេញចូលឆ្លងកាត់ព្រំដែន។

-សិក្សា អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែន និងពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក និងច្រកទ្វារព្រំដែន ។

**រាជធានី ខេត្ត សម្ព័ន្ធមេត្រីភាព**

បន្តពិនិត្យ សម្រេចលើសំណើរបស់រដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការជាមួយខេត្ត ក្រុងនៃប្រទេសជាមិត្ត។ ទន្ទឹមនេះ បន្តពិនិត្យ វាយតម្លៃអំពីសកម្មភាព និងអត្ថប្រយោជន៍នានាដែលរាជធានី ខេត្ត ក្រុង ទទួលបានពីការចងសម្ព័ន្ធមេត្រីភាព ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរបទពិសោធន៍ល្អៗ សំដៅទាញយកផលប្រយោជន៍សម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ ទេសចរណ៍ នៅមូលដ្ឋាន ។

**៤-ការងារគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច**

-បន្តសម្របសម្រួល ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់គណបក្សនយោបាយក្នុងការដាក់របាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ស្របតាមច្បាប់ស្តីពី គណបក្សនយោបាយ ។

-បន្តអនុវត្តនីតិវិធីលើសំណើសុំចុះបញ្ជី សុំបង្កើត និងសំណើផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារគណបក្សនយោបាយ ។

-បន្តរៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ។

-បន្តអនុវត្តតាមនីតិវិធីលើសំណើសុំចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដែលពាក់ព័ន្ធនឹងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច ។

-បន្តសម្របសម្រួល ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារប្រចាំឆ្នាំ ស្របតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

-រៀបចំវេទិកាស្តីពី ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ប្រចាំឆ្នាំ២០២១ ។

## ៥-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

-តម្កល់ស្មារតីប្រុងប្រយ័ត្នខ្ពស់បំផុតក្នុងការថែរក្សាព្រំដែនសន្តិភាព និងខឿនឯករាជ្យជាតិ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ។

-បន្តលើកស្ទួយគោលនយោបាយសុខដុមនីយកម្មឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធានាថែរក្សារឹងមាំនូវធ្លុងសាមគ្គីភាព ឯកភាពផ្ទៃក្នុងជាតិ មិនទុកឱ្យមានភាពចន្លោះប្រហោងណាមួយដែលកម្លាំងអមិត្តអាចឆ្លៀតប្រើប្រាស់ដើម្បីញុះញង់បង្កើតនូវកម្លាំងប្រឆាំង ឬកម្លាំងប្រដាប់អាវុធខុសច្បាប់មកបំផ្លិចបំផ្លាញសមិទ្ធផលសង្គមជាតិ ក៏ដូចជាសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋឡើយ ។

-រក្សាសន្តិសុខផ្ទៃក្នុងឱ្យបានរឹងមាំ ធានាការពារប្រក្រតីភាពនៃដំណើរការ និងការប្រព្រឹត្តទៅរបស់ស្ថាប័នជាតិ ធានាព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ សុវត្ថិភាពថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ ព្រមទាំងគ្រប់គោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍...។ ប្រឆាំងដាច់ខាតការធ្វើសកម្មភាពបដិវត្តន៍ពណ៌ក្នុងបំណងផ្តួលរំលំរាជរដ្ឋាភិបាលដែលប្រសូត្រចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋ ប្រឆាំងរាល់សកម្មភាពកុប្បកម្ម ការធ្វើវិទ្ធង្សនា និងវិទ្ធទកម្មគ្រប់រូបភាព ព្រមទាំងឧបាយកលប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង ។

-បើកទូលាយកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារប្រតិបត្តិច្បាប់នៃប្រទេសជាដៃគូក្នុងតំបន់ និងក្រៅតំបន់ ដើម្បីទប់ស្កាត់មិនឱ្យកើតមាននូវអំពើភេរវកម្ម ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងជំរុញការងារបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសបទល្មើសគ្រឿងញៀន បទល្មើសបច្ចេកវិទ្យា បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ...។

-លើកកម្ពស់សន្តិសុខ សុវត្ថិភាពសង្គម សំដៅធ្វើឱ្យជនគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសន្តិសុខទាំងផ្លូវកាយ និងផ្លូវចិត្ត តាមរយៈការធ្វើឱ្យបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទមានការថយចុះជាអតិបរមា ជាពិសេសបទល្មើសដែលធ្វើឱ្យប៉ះពាល់ចិត្តសាស្ត្រសង្គម ។

-បន្តថែរក្សាបរិយាកាសសង្គមកម្ពុជា ជាសង្គមថ្លៃថ្នូរ គ្មានក្រុមសង្គមងងឹត ក្រុមជនពាល និងជនទំនើង ធ្វើឱ្យគ្រប់សហគមន៍ ភូមិ ឃុំ សង្កាត់ កាន់តែទទួលបានសុវត្ថិភាព អំណោយផលដល់ប្រជាពលរដ្ឋក្នុងការប្រកបមុខរបរបង្កើនសេដ្ឋកិច្ចគ្រួសារ ។

-រៀបចំសណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់ចរាចរណ៍ ឱ្យមានរបៀបរៀបរយល្អ ជាពិសេសនៅតាមប៉ូលនៃរាជធានី ខេត្ត ទីប្រជុំជន និងតំបន់ទេសចរណ៍សំខាន់ៗ តាមរយៈលើកកម្ពស់ការបើកបរ និងការគោរពប្រតិបត្តិច្បាប់ឱ្យបានគ្រប់ៗគ្នា សំដៅធ្វើឱ្យគ្រោះថ្នាក់ចរាចរណ៍ត្រូវបានកាត់បន្ថយ ការកកស្ទះចរាចរណ៍ត្រូវបានដោះស្រាយ និងគ្រោះថ្នាក់សង្គមដទៃទៀតមានការថយចុះ របៀបរបបរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយភាពស៊ីវីល័យ ។

-យកចិត្តទុកដាក់ជំរុញការផ្តល់សេវាសន្តិសុខជូនប្រជាពលរដ្ឋ និងសេវាតម្រូវការចាំបាច់ផ្សេងៗទៀត ឱ្យបានលឿនរហ័ស និងមានតម្លាភាព ។

-រៀបចំផែនការសកម្មភាព រួមទាំងចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ។

-បន្តពង្រឹងការងារនគរបាល និងសហគមន៍ ដោយខិតខំលើកកម្ពស់សមត្ថភាព គុណភាពការងាររបស់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល ដែលជាកម្លាំងស្នូល និងជាកម្លាំងចលករចាំបាច់មិនអាចខ្វះបាន ក្នុងការជំរុញចលនាអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលស្តីពី "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ។

ផ្តើមចេញពីទស្សនទានទាំងនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវរៀបចំយន្តការ និងផែនការសកម្មភាពស្របតាមជំនាញ ទាំងក្នុងកម្រិតដឹកនាំ គ្រប់គ្រង និងកម្រិតជំនាញបច្ចេកទេស ។

## ៦-ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

-បន្តសហការសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គ.ប.ស.ហ ក្នុងការអនុវត្តបណ្តាផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងផែនការសកម្មភាពដែលក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកបានដាក់ចេញ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រុមការងារ ICRG-JG របស់ FATF ។

-ជំរុញផ្សព្វផ្សាយសេចក្តីណែនាំលេខ ០៣៤សណន ស្តីពីការបង្កើនស្មារតីយកចិត្តទុកដាក់អនុវត្តច្បាប់ក្នុងប្រតិបត្តិការស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់ក្រសួងមហាផ្ទៃ ។

-ផ្តល់កិច្ចសហការប្រឹក្សាយោបល់ និងគាំទ្រផ្នែកបច្ចេកទេសលើនីតិវិធីដោះស្រាយបណ្តឹង ឬសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចអន្តរជាតិ ពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ ។

-ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ ក្នុងការតាមដាន ទប់ស្កាត់ ស៊ើបអង្កេត ការចោទប្រកាន់ ការបង្កក និងឃាត់ទុកផលសំអាងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## ៧-ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

-ជំរុញការអនុវត្តផែនការជាតិស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៩-២០២៣) ។

-បន្តរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ។

-បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការ ទប់ស្កាត់ និងវិធានការសង្គ្រោះ និងការពារជនរងគ្រោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

-បន្តពង្រឹងយន្តការដឹកនាំបញ្ជា ដោយធ្វើការប្រជុំដាក់ចេញគោលការណ៍ និងចង្អុលណែនាំដល់គ្រប់ក្បាលម៉ាស៊ីនដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានប្រសិទ្ធផលខ្ពស់ ។

-បន្តពង្រឹងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ក្នុងការរៀបចំយន្តការគ្រប់គ្រងលំហូរពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី និងការការពារផលប្រយោជន៍ពលករនៅក្នុងប្រទេសគោលដៅ ។

-បន្តជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល ។

### ៨-ការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ

-រៀបចំដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល ០៥ឆ្នាំ (២០២១-២០២៥) ។

-បន្តសហការពិនិត្យ សិក្សា រៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងឱសថ ផលិតផលក្លែងក្លាយ និងសារធាតុគីមីខុសច្បាប់ ឱ្យស្របទៅនឹងការវិវត្តនៃសភាពការណ៍បទល្មើស ។

-បន្តជំរុញកិច្ចសហការសម្របសម្រួលជាមួយស្ថាប័នជំនាញអន្តរក្រសួង ក្នុងសកម្មភាពកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ពិសេសការអនុវត្ត "ប្រកាសរួម" និង "ផែនការអនុវត្តរួម" រវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ។

-បន្តកៀរគរការចូលរួមអនុវត្តច្បាប់ពីគ្រប់តួអង្គពាក់ព័ន្ធ ពិសេសក្រុមហ៊ុន រោងចក្រ សហគ្រាស និងគ្រឹះស្ថាននានា តាមរយៈការពង្រឹងយន្តការអនុវត្តច្បាប់មឺងម៉ាត់ផង ជំរុញការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់នៃផលិតផលក្លែងក្លាយ និងអន់គុណភាព-ខូចគុណភាព ផង ។

-បន្តពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងអន្តរជាតិ ជាពិសេសជាមួយបណ្តាប្រទេស ឬដៃគូនានា ដែលបានចុះ MoU និងកិច្ចព្រមព្រៀងជាមួយកម្ពុជា ។

### ៩-ការងារអត្តសញ្ញាណកម្ម

-បន្តខិតខំជំរុញបញ្ចប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗ ពិសេសសេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ព្រមទាំងពិនិត្យឡើងវិញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធការងារអត្តសញ្ញាណកម្ម ដើម្បីធ្វើវិសោធនកម្មឱ្យស្របតាមទស្សនទាននានាដែលមានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម (ឆ្នាំ២០១៧-២០២៦) ។

-បន្តជំរុញដំណើរការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅឃុំ សង្កាត់ដែលកំពុងអនុវត្តសាកល្បងក្នុងខេត្តគោលដៅ ព្រមទាំងពិនិត្យលទ្ធភាពពង្រីកទៅឃុំ សង្កាត់នៃរាជធានី ខេត្តផ្សេងទៀត ដែលចំពោះមុខនេះនឹងរៀបចំដាក់ឱ្យដំណើរការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅសង្កាត់ចំនួន ១៤ នៃរាជធានីភ្នំពេញ។

-បន្តជំរុញអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញលើការងារអត្តសញ្ញាណកម្ម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានជាប់ជាប្រចាំ ព្រមជាមួយនឹងការខិតខំផ្សព្វផ្សាយអប់រំណែនាំដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់ប្រភេទ និងការថែរក្សាទុកឯកសារទាំងនេះឱ្យបានគង់វង្ស ដើម្បីចៀសវាងការបាត់ ឬខូចដោយប្រការផ្សេងៗ ដែលនាំឱ្យតម្រូវការនៃការស្នើសុំមានច្រើន ។

-បន្តអនុវត្តនីតិវិធីលើករណីសុំរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងពលរដ្ឋខ្មែរ និងករណីសុំចូលសញ្ជាតិខ្មែរ ទាមទារសញ្ជាតិខ្មែរ លះបង់សញ្ជាតិខ្មែរ ។

-បន្តជំរុញ និងតាមដានការអនុវត្តប្រកាសលេខ ២៨៨៤ ប្រ.ក របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្ទេរសមត្ថកិច្ចក្នុងការផ្តល់សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ និងសេចក្តីណែនាំលេខ ០០១ស.ណ.ន ស្តីពីវិធានបទ និងនីតិវិធីនៃការងារចុះបញ្ជី និងការគ្រប់គ្រងការស្នាក់នៅ របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

-បន្តជំរុញការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ពិសេសប្រជាពលរដ្ឋដែលស្ថិតក្នុងផែនការត្រូវផ្តល់ចាប់ពីឆ្នាំ២០២១-២០២៣ ដើម្បីត្រៀមលក្ខណៈបម្រើដល់ការចុះឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នៃរដ្ឋសភា នាឆ្នាំ២០២៣ ។

-បន្តពង្រឹងប្រសិទ្ធភាពការផ្តល់សេវាអត្តសញ្ញាណកម្មបន្ថែមទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាឱ្យការផ្តល់សេវាកាន់តែងាយស្រួល មានគុណភាព តម្លាភាព និងទទួលបានជំនឿចិត្តពីប្រជាពលរដ្ឋ តាមរយៈការបន្តជំរុញយន្តការសេវាកម្មអត្តសញ្ញាណកម្ម និងប្រតិកម្មរហ័ស និងការចុះទៅបណ្តុះបណ្តាល ផ្សព្វផ្សាយអប់រំបន្ថែមដល់មូលដ្ឋាន ។

-បន្តសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការជំរុញដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោកជាមួយប្រព័ន្ធអត្តសញ្ញាណកម្ម និងជាមួយក្រសួងសុខាភិបាល ក្នុងការតភ្ជាប់ប្រព័ន្ធសុខាភិបាលមូលដ្ឋានជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ។

-បន្តពង្រឹង និងពង្រីកកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម ជាពិសេសពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ។

-បន្តរៀបចំផ្សព្វផ្សាយ ផ្តល់វគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រី អំពីគោលការណ៍ និងលិខិតបទដ្ឋានថ្មីៗពាក់ព័ន្ធនឹងការងារអត្តសញ្ញាណកម្ម ។

**១០-ការងារអន្តោប្រវេសន៍**

-ពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធការងារអន្តោប្រវេសន៍ ដើម្បីកែសម្រួល ឬធ្វើវិសោធនកម្មឱ្យស្របតាមខ្លឹមសារច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលនឹងត្រូវធ្វើការកែសម្រួលថ្មីនាពេលខាងមុខ។

-បន្តយកចិត្តទុកដាក់ពង្រឹង និងលើកកម្ពស់សមត្ថភាពជំនាញ ក្រមសីលធម៌ មនសិការវិជ្ជាជីវៈ ឆន្ទៈ និងស្មារតីទទួលខុសត្រូវរបស់មន្ត្រីនគរបាលអន្តោប្រវេសន៍គ្រប់កម្រិត គ្រប់ផ្នែក ។

-បន្តលើកកម្ពស់វិធានការគ្រប់គ្រងការចេញចូលប្រទេសឱ្យកាន់តែមានប្រសិទ្ធភាព សំដៅបង្ការ ទប់ស្កាត់មិនឱ្យមានជនបរទេសស្នាក់នៅខុសច្បាប់ បង្ការ ទប់ស្កាត់អំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ដើម្បីគាំទ្រគោលនយោបាយបើកចំហរជើងមេឃរបស់រាជរដ្ឋាភិបាល ។

-បន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាអន្តោប្រវេសន៍ឱ្យមានលក្ខណៈគ្របដណ្តប់បានគ្រប់ជំនាញអន្តោប្រវេសន៍។ ចំពោះមុខ ក្រសួងនឹងរៀបចំដំឡើងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកដំណើរមុនពេលមកដល់ (APIS) សម្រាប់បម្រើឱ្យការងារវិនិច្ឆ័យព័ត៌មានស្វែងរកមុខសញ្ញា ព្រមទាំងបន្តត្រួតពិនិត្យ និងធ្វើសុក្រឹត្យភាពលើប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងទិន្នន័យមុខសញ្ញា ដែលបានដាក់ឱ្យដំណើរការនាពេលកន្លងមក ។

-រៀបចំកសាងឯកសារ-បទដ្ឋានគតិយុត្តសម្រាប់បម្រើឱ្យការងារគ្រប់គ្រងការចេញចូលតាមច្រកទ្វារផ្លូវដែក ដើម្បីមានភាពម្ចាស់ការពេលដាក់ឱ្យដំណើរការអយស្ម័យយានឆ្លងកាត់ព្រំដែន ។ ទន្ទឹមនេះ ក៏ត្រូវធ្វើបច្ចុប្បន្នភាពឡើងវិញនូវឯកសារជំនាញគ្រប់គ្រងច្រកទ្វារទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ផងដែរ។

-បន្តជំរុញអនុវត្តសេចក្តីណែនាំលេខ ០២៨ សណន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានមូលដ្ឋានក្នុងការធានាសន្តិសុខ សុវត្ថិភាព ជូនជនបរទេស ក៏ដូចជាការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបង្កដោយជនបរទេសប្រកបដោយប្រសិទ្ធភាព។

-បន្តជំរុញកិច្ចសហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការគ្រប់គ្រងការប្រកបមុខរបររបស់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានហ្មត់ចត់ ក្នុងនោះ ត្រូវយកចិត្តទុកដាក់ចំពោះគោលដៅតាមតំបន់ព្រំដែន និងតំបន់ដាច់ស្រយាលដែលមិនធ្លាប់បានធ្វើអធិការកិច្ចកន្លងមក ។

-បន្តអនុវត្តការងារជនភៀសខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្ន សំដៅឆ្លើយតបនូវតួនាទីជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៥១ និងពិធីសារ ឆ្នាំ១៩៦៧ ទាក់ទិននឹងឋានៈជនភៀសខ្លួនផង និងសំណូមពរនៃការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ក៏ដូចជាការអភិវឌ្ឍមាតុភូមិកម្ពុជាផង ។

-បន្តជំរុញវិធានការស៊ើបអង្កេត ស្វែងរកជនបរទេសដែលលួចជ្រៀតចូលមកស្នាក់នៅខុសច្បាប់ ស្នាក់នៅហួសរយៈពេលកំណត់ និងជនបរទេសពាក់ព័ន្ធការប្រព្រឹត្តបទល្មើសនានា ដើម្បីរៀបចំនីតិវិធីបណ្ដេញចេញទាន់ពេលវេលា ។

-បន្តជំរុញកិច្ចសហការអន្តរជាតិ ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយដៃគូហត្ថលេខី និងកិច្ចសហការជាមួយប្រទេសជិតខាង និងក្នុងតំបន់ លើការងារអន្តោប្រវេសន៍ ព្រមទាំងបង្កើនសកម្មភាពសហការផ្លាស់ប្ដូរព័ត៌មានបម្រើឱ្យការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ។

## ១១-ការងារពន្ធនាគារ

-បន្តខិតខំអភិវឌ្ឍមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត លើគ្រប់ផ្នែក ដោយសហការជាមួយដៃគូអភិវឌ្ឍនានា សំដៅលើកកម្ពស់ការអនុវត្តកម្មវិធីអប់រំកែប្រែស្មារតីសម្បទា កម្មវិធីអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមុខរបរ កម្មវិធីសមាហរណកម្ម និងកម្មវិធីសេវាសុខភាពពន្ធនាគារ ។

-បន្តជំរុញគម្រោងសាងសង់ ជួសជុល កែលម្អអគារឃុំឃាំង និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងពន្ធនាគារ ដើម្បីដោះស្រាយបញ្ហាចង្អៀតណែន ។

-បន្តជំរុញ តាមដាន និងគាំទ្រការងារធ្វើចំណាត់ថ្នាក់សន្តិសុខជនជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ រាជធានី ខេត្ត ដើរទន្ទឹមនឹងការយកចិត្តទុកដាក់ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីពន្ធនាគារ ដើម្បីទប់ស្កាត់បទល្មើស និងហានិភ័យផ្សេងៗ ដែលកើតមានជាយថាហេតុ សំដៅធានារក្សាសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់ក្នុងពន្ធនាគារ និងងាយស្រួលក្នុងការតាមដាន វាយតម្លៃកម្រិតកែខ្លួនរបស់ទណ្ឌិត ។

-បន្តសហការជាមួយស្ថាប័នតុលាការ ដើម្បីគ្រប់គ្រងពន្ធនាគារ ស្របតាមច្បាប់ជាធរមាន ។

-បន្តសិក្សា រៀបចំ និងកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនានា ឱ្យស្របតាមសភាពការណ៍វិវត្តនៃវិស័យពន្ធនាគារ ។

## ១២-ការងារបណ្ឌិត្យសភានគរបាលកម្ពុជា

-បន្តពិនិត្យ រៀបចំ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌគតិយុត្តចាំបាច់នានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងគុណភាពអប់រំ និងធានាបានក្នុងភាពម្ចាស់ការលើការងារបណ្ដុះបណ្ដាល ។

-បន្តលើកកម្ពស់កម្មវិធីបណ្ដុះបណ្ដាល បំពាក់បំប៉នមុខជំនាញឯកទេសនានាដល់និស្សិត សិក្ខាកាម សិស្សដែលជាមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពប្រកបដោយកម្លាំង ។

-បន្តពង្រីកវិសាលភាពបណ្ដុះបណ្ដាលមុខជំនាញឯកទេសនានាដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ និងបន្តអភិវឌ្ឍកម្មវិធីអប់រំ ខ្លឹមសារមេរៀន ព្រមទាំងខិតខំស្រាវជ្រាវ រៀបចំចងក្រងឯកសារសម្រាប់បង្ហាត់បង្រៀន និងសៀវភៅគោលឱ្យបានគ្រប់មុខវិជ្ជា ។

-បន្តពង្រឹងគុណវុឌ្ឍិគ្រូនគរបាលជាតិ និងលើកកម្ពស់គុណភាពសិក្សារបស់និស្សិត ក្រោមទិសស្លោក "យើងរួមគ្នាកសាងវប្បធម៌គុណភាព" ។

-បន្តជំរុញ និងគាំទ្រការងារអភិវឌ្ឍធនធានសិក្សា និងធនធានរូបវន្តគ្រប់ប្រភេទ ព្រមទាំងផ្គត់ផ្គង់សម្ភារៈឱ្យបានសមស្រប ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលគ្រប់វគ្គ និងគ្រប់កម្រិត ។

-បន្តអនុវត្តប្រព័ន្ធធានាគុណភាពអប់រំទ្វេភាព (ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងការវាយតម្លៃទទួលស្គាល់គុណភាពអប់រំពីខាងក្រៅ) ដើម្បីធ្វើឱ្យគុណភាពអប់រំប្រសើរឡើងជាលំដាប់ ។

-បន្តទំនាក់ទំនង ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាដៃគូនានា ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារគ្រប់គ្រង ការងារបង្ហាត់បង្រៀន ធ្វើអន្តរនីយកម្មកម្មវិធីអប់រំសម្រាប់គាំទ្រដល់ការបណ្តុះបណ្តាលគ្រប់កម្រិត ព្រមទាំងកៀរគរជំនួយបច្ចេកទេស សម្ភារៈ និងហិរញ្ញវត្ថុ ។

### ១៣-ការងារភស្តុភារ និងហិរញ្ញវត្ថុ

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា ០៣ឆ្នាំរំកិល (២០២២-២០២៤) និងគម្រោងចំណូលចំណាយថវិកាឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ។

-បន្តពង្រឹងការរៀបចំកម្មវិធីចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សមិទ្ធកម្ម តាមបណ្តាអង្គភាពនានាចំណុះក្រសួង ។

-បន្តពង្រឹងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បន្តជំរុញការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងលទ្ធកម្មសាធារណៈ ឱ្យស្របតាមប្រតិទិនកំណត់ ។

-ដាក់ឱ្យដំណើរការស្ថានីយវិទ្យុផ្សាយសំឡេងរបស់ក្រសួងមហាផ្ទៃ ។

-បន្តតាមដាន និងជំរុញពន្លឿនការអនុវត្តគម្រោងជួសជុល និងសាងសង់សំណង់គ្រប់ប្រភេទ ទាំងគម្រោងកំពុងដំណើរការ និងគម្រោងនៃផែនការឆ្នាំ២០២១ ព្រមទាំងបន្តសិក្សា រៀបចំគម្រោងនានាបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ។

-បន្តជំរុញការផ្សព្វផ្សាយអប់រំសុខភាពដល់នគរបាលជាតិនៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងលើកកម្ពស់សមត្ថភាពជំនាញរបស់មន្ត្រីពេទ្យ ព្រមជាមួយនឹងការយកចិត្តទុកដាក់ផ្គត់ផ្គង់សម្ភារៈបច្ចេកទេស បរិក្ខារវេជ្ជសាស្ត្រឱ្យសមស្រប ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការព្យាបាលជំងឺជូនកងកម្លាំងនគរបាលជាតិ ។

-បន្តស្វែងយល់អំពីតម្រូវការ និងបរិមាណ គុណភាពនៃឧបករណ៍ សម្ភារៈបច្ចេកទេស ដែលប្រទេសមួយចំនួនកំពុងប្រើប្រាស់ សំដៅបង្កើនប្រសិទ្ធភាពដល់កិច្ចប្រតិបត្តិការនានាស្ថិតក្នុងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ ។

### ១៤-ការងារអធិការកិច្ច

-ពិនិត្យ កែសម្រួលនីតិវិធីនៃការធ្វើអធិការកិច្ច និងអង្កេតស្រាវជ្រាវរបស់អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងសិក្សា រៀបចំឡើងវិញនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញតួនាទី ភារកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះ ក៏នឹងធ្វើការពិនិត្យ កែសម្រួលឡើងវិញនូវបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារអធិការកិច្ច និងដោះស្រាយពាក្យបណ្តឹង ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ។

-បន្តពង្រឹងយន្តការទទួលពាក្យបណ្តឹង និងការតាមដាន ស្រង់ព័ត៌មានពីគ្រប់ប្រភពសារព័ត៌មាន ព្រមទាំងជំរុញការចុះអធិការកិច្ច អង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹងឱ្យបានឆាប់រហ័ស មានប្រសិទ្ធភាព និងសម្រេចឱ្យបាន ៨០% នៃបណ្តឹងចូលថ្មី ។

-បន្តជំរុញការចុះអធិការកិច្ចលើសេចក្តីជូនដំណឹងនានាដែលក្រសួងបានដាក់ចេញ និងសំណុំរឿងដែលក្រសួងបង្វែរជូនអង្គភាពពាក់ព័ន្ធអនុវត្តជាសមត្ថកិច្ច នាពេលកន្លងមក ។

### ១៥-ការងារសវនកម្មផ្ទៃក្នុង

-បន្តប្រតិបត្តិការដោយយកចិត្តទុកដាក់អនុវត្តនូវរាល់គោលការណ៍ បែបបទកំណត់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ជាពិសេសកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងប្រសិទ្ធភាពការងាររបស់ក្រសួងមហាផ្ទៃឱ្យកាន់តែប្រសើរឡើង ។

-បន្តពង្រឹងយន្តការប្រមូល វិភាគឯកសារ ទិន្នន័យ និងភស្តុតាង ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីជំរុញប្រសិទ្ធភាពការងារសវនកម្ម។ ទន្ទឹមនេះ ត្រៀមចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៩ ការិយបរិច្ឆេទ២០២០ និងឆ្នាំពាក់ព័ន្ធ សរុបចំនួន ១.៥៧៥គោលដៅ ។

-បន្តជំរុញកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការបញ្ជ្រាបគោលគំនិតសុចរិតភាព និងអភិបាលកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ។

### ១៦-ការងារទំនាក់ទំនងអន្តរជាតិ

-បន្តពង្រឹង ពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឱ្យកាន់តែរឹងមាំ និងទូលំទូលាយ សំដៅជំរុញលើកកម្ពស់ប្រសិទ្ធភាពការងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ក៏ដូចជាបម្រើដល់ឧត្តមប្រយោជន៍ជាតិទាំងមូល ពិសេសលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យរដ្ឋបាលសាធារណៈ ។

-បន្តសហការ សម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសសមាជិក ដើម្បីជំរុញដំណើរការអនុវត្តឯកសារសហប្រតិបត្តិការដែលនៅជាធរមាន និងបន្តអនុវត្តយន្តការសហប្រតិបត្តិការប្រចាំឆ្នាំ និងយន្តការដទៃទៀតដែលបានខកខានកន្លងមក ។

### ១៧-ការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)

-បន្តជំរុញ និងគាំទ្រដល់ដំណើរការរៀបចំ និងអនុវត្តផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងមហាផ្ទៃ ។

-បន្តកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់បណ្តាញចែកចាយ បញ្ជូនព័ត៌មាន និងប្រព័ន្ធអ៊ីនធឺណែតមានខ្សែ (Cable) និងគ្មានខ្សែ (Wireless) នៅក្នុងទីស្តីការក្រសួងមហាផ្ទៃ ។ ទន្ទឹមនេះ ក៏នឹងរៀបចំតភ្ជាប់បណ្តាញ Fiber Optic ក្រោមដី ពីទីស្តីការក្រសួងមហាផ្ទៃទៅបណ្តាអគ្គនាយកដ្ឋានចំណុះនានា និងគោលដៅផ្សេងទៀត។

-បន្តជំរុញ និងផ្តល់កិច្ចអន្តរាគមន៍ដល់ការងារថែទាំប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិក និងហេដ្ឋារចនាសម្ព័ន្ធ ICT ក្រសួងមហាផ្ទៃ ។

-បន្តជំរុញដំណើរការសិក្សាស្រាវជ្រាវបម្រើដល់ការអភិវឌ្ឍធនធានមនុស្ស និងឧបករណ៍សម្ភារៈបច្ចេកទេសលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការងារសន្តិសុខព័ត៌មាន។

-បន្តពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញលើកកម្ពស់វិស័យ ICT ក្រសួងមហាផ្ទៃ ឱ្យមានការរីកចម្រើនជាលំដាប់ ។

### ១៨-កិច្ចសហការសម្របសម្រួលអន្តរស្ថាប័ន

-សហការសម្របសម្រួលអន្តរស្ថាប័ន ក្នុងការជំរុញអនុវត្តកម្មវិធីកំណែទម្រង់នានាស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ។

-បន្តពង្រឹងសហប្រតិបត្តិការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការងារនានាដែលពាក់ព័ន្ធនឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ។

**ដើម្បីសម្រេចនូវទិសដៅការងារដូចបានដាក់ចេញនេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដី និងកងកម្លាំងនគរបាលជាតិគ្រប់លំដាប់ថ្នាក់ ត្រូវសកម្មចូលរួមអនុវត្តដោយឈរលើស្មារតីប្ដេជ្ញា សាមគ្គី ឯកភាពខ្ពស់ សំដៅបង្កើតនូវកាលានុវត្តភាព និងសមិទ្ធផលថ្មីៗថែមទៀតនៅក្នុងឆ្នាំ២០២១ នេះ ៕**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (គណៈកម្មការទី៤)
- អគ្គលេខាធិការដ្ឋានរដ្ឋសភា (គណៈកម្មការទី៤)
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អង្គភាពចំណុះក្រសួងមហាផ្ទៃ
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ការងារកសាងលិខិតបទដ្ឋានគតិយុត្ត

## ● លិខិតបទដ្ឋានគតិយុត្ត ដែលបានអនុម័តរួចហើយ

- ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- អនុក្រឹត្យស្តីពី ការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យស្តីពី ការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា
- អនុក្រឹត្យស្តីពី ការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- អនុក្រឹត្យស្តីពី ការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- អនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ៤៤អនក្រ.បក ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក
- អនុក្រឹត្យស្តីពី ការប្រឡងប្រជែងជ្រើសរើសនិស្សិតអាហារូបករណ៍សិក្សានៅបណ្ឌិត្យសភានគរបាលកម្ពុជា
- អនុក្រឹត្យស្តីពី ការកំណត់លក្ខណសម្បត្តិ និងឋានៈគ្រូនគរបាលជាតិកម្ពុជា
- អនុក្រឹត្យស្តីពី ការរៀបចំ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- អនុក្រឹត្យស្តីពី ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិបង្កក នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## ● ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលបាន និងកំពុងតាក់តែង

- សេចក្តីព្រាងច្បាប់ស្តីពី សណ្តាប់ធ្នាប់សាធារណៈ
- សេចក្តីព្រាងច្បាប់ស្តីពី នគរបាលជាតិកម្ពុជា
- សេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន
- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី អន្តោប្រវេសន៍
- សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម (គ.ជ.ប.ទ)
- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក
- សេចក្តីព្រាងការកែសម្រួលព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងសន្តិសុខ និងការចុះបញ្ជីស្នាក់នៅតាមទីតាំងប្រមូលផ្តុំ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការផ្តល់របបឧបត្ថម្ភសម្រាប់ឋានៈសាស្ត្រាចារ្យ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក/ជូន
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- សេចក្តីព្រាងអនុក្រឹត្យស្តីពី គោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

- សេចក្ដីព្រាងការកែសម្រួលអនុក្រឹត្យលេខ ១០៩អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

ក្រៅពីលិខិតបទដ្ឋានគតិយុត្តខាងលើ ក្រសួងក៏បានចូលរួមនៅក្នុងយន្តការរៀបចំតាក់តែងសេចក្ដីព្រាងប្រកាស សេចក្ដីព្រាង សេចក្ដីណែនាំ និងលិខិតបទដ្ឋាននានាជាច្រើនទៀត ផងដែរ ។

---

## ឧបសម្ព័ន្ធទី២ ចំនួនរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក សង្កាត់ ឃុំ និងភូមិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

| ល.រ | រាជធានី ខេត្ត | ខណ្ឌ | ក្រុង | ស្រុក | សរុប ខណ្ឌ ក្រុង ស្រុក | សង្កាត់ | ឃុំ | សរុបឃុំ សង្កាត់ | ចំនួនភូមិ សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | ខេត្ត បន្ទាយមានជ័យ | | ០២ | ០៧ | ០៩ | ១០ | ៥៥ | ៦៥ | ៦៥៨ |
| ២ | ខេត្ត បាត់ដំបង | | ០១ | ១៣ | ១៤ | ១០ | ៩២ | ១០២ | ៨២៩ |
| ៣ | ខេត្ត កំពង់ចាម | | ០១ | ០៩ | ១០ | ០៤ | ១០៥ | ១០៩ | ៩១៦ |
| ៤ | ខេត្ត កំពង់ឆ្នាំង | | ០១ | ០៧ | ០៨ | ០៤ | ៦៦ | ៧០ | ៥៦៩ |
| ៥ | ខេត្ត កំពង់ស្ពឺ | | ០១ | ០៧ | ០៨ | ០៥ | ៨២ | ៨៧ | ១.៣៦៨ |
| ៦ | ខេត្ត កំពង់ធំ | | ០១ | ០៨ | ០៩ | ០៨ | ៧៣ | ៨១ | ៧៦៥ |
| ៧ | ខេត្ត កំពត | | ០១ | ០៧ | ០៨ | ០៥ | ៨៨ | ៩៣ | ៤៨៨ |
| ៨ | ខេត្ត កណ្ដាល | | ០១ | ១០ | ១១ | ១០ | ១១៧ | ១២៧ | ១.០០៥ |
| ៩ | ខេត្ត កោះកុង | | ០១ | ០៦ | ០៧ | ០៣ | ២៦ | ២៩ | ១២០ |
| ១០ | ខេត្ត ក្រចេះ | | ០១ | ០៥ | ០៦ | ០៥ | ៤២ | ៤៧ | ២៥៨ |
| ១១ | ខេត្ត មណ្ឌលគិរី | | ០១ | ០៤ | ០៥ | ០៤ | ១៧ | ២១ | ៩២ |
| ១២ | រាជធានីភ្នំពេញ | ១៤ | | | ១៤ | ១០៥ | | ១០៥ | ៩៥៨ |
| ១៣ | ខេត្ត ព្រះវិហារ | | ០១ | ០៧ | ០៨ | ០២ | ៤៩ | ៥១ | ២៣២ |
| ១៤ | ខេត្ត ព្រៃវែង | | ០១ | ១២ | ១៣ | ០៤ | ១១២ | ១១៦ | ១.១៤៩ |
| ១៥ | ខេត្ត ពោធិ៍សាត់ | | ០១ | ០៦ | ០៧ | ០៧ | ៤២ | ៤៩ | ៥១១ |
| ១៦ | ខេត្ត រតនគិរី | | ០១ | ០៨ | ០៩ | ០៤ | ៤៦ | ៥០ | ២៤៣ |
| ១៧ | ខេត្ត សៀមរាប | | ០១ | ១១ | ១២ | ១២ | ៨៨ | ១០០ | ៩១០ |
| ១៨ | ខេត្ត ព្រះសីហនុ | | ០២ | ០៣ | ០៥ | ០៦ | ២៣ | ២៩ | ១១០ |
| ១៩ | ខេត្ត ស្ទឹងត្រែង | | ០១ | ០៥ | ០៦ | ០៤ | ៣០ | ៣៤ | ១២៨ |
| ២០ | ខេត្ត ស្វាយរៀង | | ០២ | ០៦ | ០៨ | ១២ | ៦៨ | ៨០ | ៦៩០ |
| ២១ | ខេត្ត តាកែវ | | ០១ | ០៩ | ១០ | ០៣ | ៩៧ | ១០០ | ១.១២១ |
| ២២ | ខេត្ត ឧត្ដរមានជ័យ | | ០១ | ០៤ | ០៥ | ០៥ | ១៩ | ២៤ | ៣០៩ |
| ២៣ | ខេត្ត កែប | | ០១ | ០១ | ០២ | ០៣ | ០២ | ០៥ | ១៩ |
| ២៤ | ខេត្ត ប៉ៃលិន | | ០១ | ០១ | ០២ | ០៤ | ០៤ | ០៨ | ៩០ |
| ២៥ | ខេត្ត ត្បូងឃ្មុំ | | ០១ | ០៦ | ០៧ | ០២ | ៦២ | ៦៤ | ៩៧៨ |
| សរុប | | ១៤ | ២៧ | ១៦២ | ២០៣ | ២៤១ | ១.៤០៥ | ១.៦៤៦ | ១៤.៤០៥ |

## ឧបសម្ព័ន្ធទី៣

## ចំនួនសេវាតាមវិស័យនីមួយៗដែលបានផ្តល់ក្នុងរយៈពេល ០១ឆ្នាំ តាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត




## ចំណូលដែលទទួលបានពីការផ្តល់សេវាតាមវិស័យនីមួយៗ ក្នុងរយៈពេល ០១ឆ្នាំ



ឧបសម្ព័ន្ធទី៤

## ចំនួនសេវាតាមវិស័យនីមួយៗដែលបានផ្តល់ក្នុងរយៈពេល ០១ឆ្នាំ
## តាមរយៈការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ




## ចំណូលដែលទទួលបានពីការផ្តល់សេវាតាមវិស័យនីមួយៗ ក្នុងរយៈពេល ០១ឆ្នាំ



ឧបសម្ព័ន្ធទី៥

# តារាងគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ប្រចាំឆ្នាំ២០២០

| ល.រ | រាជធានី ខេត្ត | ចំនួនគ្រួសារ | ចំនួនមនុស្សរួម | | អាយុ ១៥ឆ្នាំឡើង | | អាយុ ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | រាជធានីភ្នំពេញ | ៣១៦.៧៤១ | ១.៥៧២.១៣២ | ៨១៤.៣៦៦ | ១.២២៨.៣៥០ | ៦៤៤.៥៣០ | ១.១៧២.៤៤៤ | ៦១៦.៩០០ |
| ២ | ខេត្ត កណ្ដាល | ៣០៣.៤០២ | ១.៣១៧.៩៣២ | ៦៨៤.៨៧១ | ១.០១៦.៧៧៨ | ៥១១.៤២៤ | ៩៤៨.២៨៦ | ៤៧៨.២០៦ |
| ៣ | ខេត្ត កំពង់ស្ពឺ | ២១៧.៨២៥ | ៨៦៧.៣០៤ | ៤៣៧.០០៣ | ៦២៧.៩២២ | ៣២២.៦៦៩ | ៥៨៩.៣៨៥ | ៣០៣.៤៨៤ |
| ៤ | ខេត្ត កំពង់ឆ្នាំង | ១៣៩.៦៥៤ | ៥៧០.២៩២ | ២៩០.៦៩៩ | ៤១៧.០២៣ | ២០៩.៥៩៨ | ៣៨៥.៥៧០ | ១៩៤.០២៨ |
| ៥ | ខេត្ត ព្រៃវែង | ២៨៧.៣៣០ | ១.២៣២.៥៦៧ | ៦៣៦.៦៣៦ | ៨៨៦.៤៣៦ | ៤៦៣.២៣៤ | ៨១៨.៣៦០ | ៤២៩.៣១០ |
| ៦ | ខេត្ត កំពង់ចាម | ២៧៩.៩០៧ | ១.០៨៧.០៩៣ | ៥៥៧.៤១៨ | ៨២២.០៥៤ | ៤២១.៤៣៨ | ៧៦១.៨១៦ | ៣៩១.៧៦១ |
| ៧ | ខេត្ត ក្រចេះ | ៨៧.៥៩១ | ៣៩៣.១៨១ | ១៩៧.៥៩៥ | ២៩៣.៦១១ | ១៤៨.៣៣៦ | ២៧២.៥៩៨ | ១៣៧.៩៩៣ |
| ៨ | ខេត្ត ស្ទឹងត្រែង | ៣៦.០៨៥ | ១៥០.០៧៩ | ៧៥.៧៨៤ | ១០៥.២៥៣ | ៥១.២៩៨ | ៩៥.៩៤៤ | ៤៦.៨៦៣ |
| ៩ | ខេត្ត ស្វាយរៀង | ១៥៣.៨៩៤ | ៦៣១.៥៩១ | ៣២៧.៩៣០ | ៤៨៦.៥៥៨ | ២៥៦.៦៧៥ | ៤៥៦.៩០២ | ២៤២.០៧៥ |
| ១០ | ខេត្ត តាកែវ | ២២៦.៥៥៤ | ១.០០៩.៣៦៨ | ៥១៩.២៩០ | ៨០២.៨៨៦ | ៤១៥.៣២៨ | ៧៤៣.៨៦៥ | ៣៨៥.៣១៧ |
| ១១ | ខេត្ត កំពត | ១៦៤.៦៧៤ | ៦៦៣.០៧៨ | ៣៤២.០៣៣ | ៥៣៦.០២៥ | ២៧៦.៨៤២ | ៩៩៩.៦៤០ | ២៥៨.៦៦៣ |
| ១២ | ខេត្ត កែប | ៩.៩២៣ | ៤១.៣៣៨ | ២១.៣៦០ | ២៩.៣៤២ | ១៤.៨៧៩ | ២៧.០០៥ | ១៣.៧៩១ |
| ១៣ | ខេត្ត ព្រះសីហនុ | ៤៩.៣៦១ | ២២១.៥៥៨ | ១១១.០១២ | ១៥៧.៥៥៩ | ៧៥.៣៦២ | ១៤៦.៩០៧ | ៧០.១៦២ |
| ១៤ | ខេត្ត កោះកុង | ៣១.១៣៤ | ១៣៨.៨៤៣ | ៦៩.៤៧៦ | ៩៩.០៦០ | ៥០.៤២៦ | ៨៩.៣៥០ | ៤៥.២៤៦ |
| ១៥ | ខេត្ត កំពង់ធំ | ១៦៤.១៦២ | ៧៥៦.២១៩ | ៣៨៧.៤៧៨ | ៥៦១.៥៨៨ | ២៨៧.០០៩ | ៥២០.៥២៧ | ២៦៦.៨០៨ |
| ១៦ | ខេត្ត ពោធិ៍សាត់ | ១២១.២០៩ | ៤៩៥.៨៧៩ | ២៥៤.៤៧២ | ៣៤៩.៩៧៩ | ១៧៩.៧៩៤ | ៣១៨.៧៣០ | ១៦៤.៥៤៤ |
| ១៧ | ខេត្ត បាត់ដំបង | ២៧៧.៥១៤ | ១.១៩១.៤៧៧ | ៥៧៩.៨៦១ | ៩១៦.៨១៧ | ៤៧២.៥៣៥ | ៨៥៨.៤១៩ | ៤៣៥.១១៧ |
| ១៨ | ខេត្ត សៀមរាប | ២៣៧.៣៥១ | ១.០៩៩.៥១៧ | ៥៦០.១៨៤ | ៧៩៥.៤២៧ | ៤០៧.៦១៤ | ៧៣៧.៧២៥ | ៣៧៩.២១៧ |
| ១៩ | ខេត្ត បន្ទាយមានជ័យ | ១៩០.៣៤៧ | ៧៧៧.៥៤៩ | ៣៩៤.២២៩ | ៥៥៨.៦៣៤ | ២៨២.៣៥៦ | ៥១៥.៤២១ | ២៦១.៣៣៩ |
| ២០ | ខេត្ត ឧត្តរមានជ័យ | ៦៣.១៧៨ | ២៥៧.៨៩២ | ១២៦.៨៣៨ | ១៨១.១៣៧ | ៩៣.៥៦៧ | ១៦៣.៧៤៤ | ៨៤.៦១៨ |
| ២១ | ខេត្ត ប៉ៃលិន | ១៦.៩៧១ | ៧១.៦៣៧ | ៣៥.៥៩៤ | ៤៩.២៩០ | ២៤.៧៦៦ | ៤៣.៩៤២ | ២២.០២០ |
| ២២ | ខេត្ត ព្រះវិហារ | ៦០.៤៦៨ | ២៤៨.៥៩៤ | ១២៧.៨៩៩ | ១៧១.៥៥២ | ៨៧.៤៥៤ | ១៥៦.[illegible] | [illegible] |
| ២៣ | ខេត្ត មណ្ឌលគិរី | ២២.៣០០ | ៩២.០១៦ | ៤៥.០៨០ | ៦១.៦០០ | ៣០.១២៩ | [illegible].៨១៨ | ២៧.២[illegible] |
| ២៤ | ខេត្ត រតនគិរី | ៤៩.០៩៨ | ២០៨.៨០០ | ១០២.៥០០ | ១៣៥.៧០០ | ៦៥.៥៦១ | [illegible]៨.៣៣៦ | [illegible].៦៩១ |
| ២៥ | ខេត្ត ត្បូងឃ្មុំ | ១៩៤.១៩១ | ៨៣៤.៦១៤ | ៤៣០.៥៧១ | ៥៩០.៩៦៨ | ២៩៨.០៤២ | ៥[illegible]៦.៩៥១ | [illegible] |
| សរុប | | ៣.៧០០.៨១៤ | ១៥.៨៨០.៥៥០ | ៨.១៣០.១៧៩ | ១១.៨៨១.៥៣៩ | ៦.០៩០.៨៦៦ | ១១.០៤៤.៨[illegible] | [illegible].៦[illegible].៩៣៨ |

## ឧបសម្ព័ន្ធទី៦

## ស្ថិតិប្រជាពលរដ្ឋចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២០

| ឆ្នាំ | សំបុត្រកំណើត | | បញ្ជាក់កំណើត | | អាពាហ៍ពិពាហ៍ ខ្មែរ-ខ្មែរ | បញ្ជាក់អាពាហ៍ពិពាហ៍ ខ្មែរ-ខ្មែរ | មរណភាព | | បញ្ជាក់មរណភាព | | អាពាហ៍ពិពាហ៍ ខ្មែរ-បរទេស | សំបុត្រកំណើត ជនបរទេស | អាពាហ៍ពិពាហ៍ បរទេស | មរណភាព ជនបរទេស |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | គូ | គូ | សរុប | ស្រី | សរុប | ស្រី | គូ | នាក់ | គូ | នាក់ |
| ២០០២-២០០៦ | ៧១៦.៦០៨ | ៣៩១.៣១៩ | ១១.១១១.៦០០ | ៥.៥៧៥.៤៤៧ | ៦៧.៥០០ | ១១៤.៣៣៥ | ២៤.៩៤៧ | ៧.៨៥០ | ១២.៤២៦ | ៣.៨១០ | | | | |
| ២០០៧ | ៥៦.២៣៥ | ២៧.៥៥៨ | ៨៧.១០៨ | ៤៣.៥៤៧ | ១៦.១០៥ | ១.៥៥៣ | ៧.១៧៦ | ២.៧១៧ | ៦៨៦ | ២៥១ | | | | |
| ២០០៨ | ៤៥.១៣០ | ២២.២៦៧ | ៨៧.៧២៤ | ៤២.៣៩៦ | ១៧.៥០១ | ២៦០ | ៧.៤៧៨ | ២.៩៧៥ | ១៣៨ | ៥២ | | | | |
| ២០០៩ | ៩៨.៧២២ | ៤៧.៥៦៧ | ១៩៥.៩១១ | ៩៥.៩៤២ | ៣២.៨៩៣ | | ១៤.៥៣៨ | ៣.២៨៥ | | | | | | |
| ២០១០ | ៦៩.៥៣៧ | ៣៤.២០៥ | ១៥៦.០៣៧ | ៧១.២០៩ | ២៥.៣៦៧ | | ១០.៩៩៧ | ៤.៤៣៣ | | | | | | |
| ២០១១ | ៧៤៤.៧៣៧ | ៣៤.៤០៦ | ១៦៩.៩៧២ | ៨២.៨៨០ | ៣៣.៦២៧ | | ១៣.៩១២ | ៥.៥៧៩ | | | ១.០៩១ | ១៥ | | ១៣ |
| ២០១២ | ១០៨.០៩៨ | ៥២.៩១៧ | ២៦២.២៤៧ | ១២៥.៩០៩ | ៤៨.៤៤០ | | ១៩.០០០ | ៧.៧៤៨ | | | ១.២៤៧ | ០៦ | | ១៤ |
| ២០១៣ | ១៣៤.៨៨២ | ៦៥.១៦៣ | ២៦៨.០៤៣ | ១៣១.៩០៧ | ៤៥.១៧៨ | | ២២.៧៨៥ | ៩.៤៥៣ | | | ១.២៩១ | ២៥ | ២៩ | ៤៥ |
| ២០១៤ | ១៤៥.២៤៧ | ៧១.១៥៦ | ២៦៥.៤៩៨ | ១២៧.៣១១ | ៤៩.៤៨២ | | ២៥.៩៧៧ | ១១.១៥៤ | | | ៨៨៥ | ២២ | ០១ | ១៥ |
| ២០១៥ | ១៨៣.៧០៦ | ៨៨.៨១២ | ៤២៨.១៥៨ | ២០៩.៦១១ | ៥៨.៧៥៥ | | ៣០.៩៦៤ | ១៣.១៦៤ | | | ១.០២១ | ៥៤ | ០១ | ៥៦ |
| ២០១៦ | ១៨០.០៤៨ | ៨៨.៥៥៧ | ៣៩២.១៦២ | ១៨៦.៧៤៧ | ៥២.៣៨២ | | ៣៥.៥៥៤ | ១៥.៦៨១ | | | ៧៧៤ | ៣១ | [illegible] | ៤៥ |
| ២០១៧ | ១២៨.៩៤១ | ៦២.២១៤ | ២៣០.១៦៥ | ១០៤.៨២៣ | ៤៤.០៥៨ | | ២៦.៩៧៣ | ១១.៥៣៣ | | | ៦០១ | ១៨ | [illegible] | ២៣ |
| ២០១៨ | ១៩៥.១៩៩ | ៦៩.៩០៦ | ២៨២.៧៧៣ | ១២៩.៧២២ | ៥៦.២៥៩ | | ៣១.១៦៣ | ១៣.៤៩៩ | | | ១.៦០៣ | ០៨ | [illegible] | [illegible] |
| ២០១៩ | ១៧៥.៦៦៨ | ៨៣.៧៦៧ | ២៦១.២៨៥ | ១២៧.១៧៧ | ៧៧.៧៦១ | | ៤១.៨០៧ | ១៨.៣០៨ | | | ១.៣២២ | [illegible] | [illegible] | [illegible] |
| ២០២០ | ១៦២.០៧២ | ៧៨.៦៨០ | ១៦៦.៨៣២ | ៨៣.០២២ | ៧០.៦២៥ | | ៣៦.០២៩ | ១៦.០៥២ | | | ៦២៧ | | | |
| សរុប | ៣.០៩៣.៩៨០ | ១.១៦៧.៩៩៤ | ១៤.៣៦៥.៥១៥ | ៧.១៣៧.៦៥០ | ៦៩៥.៩៣៣ | ១១៦.១៤៨ | ៣៤៨.៨០០ | ១៤៣.៤៣១ | ១៣.២៥០ | ៤.១១៣ | ១០.៤២២ | ១៧៩ | [illegible] | ២១១ |
| សរុបរួម | ១៩.៤៦៧.០១៣នាក់ (ស្រី ៩.២៧៥.៧២៧នាក់) | | | | | | | | | | | | | |

# លទ្ធផលផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រចាំឆ្នាំ២០២០

| ល.រ | រាជធានី ខេត្ត | ផែនការត្រូវផ្តល់ | ទិន្នន័យទទួលបាន | | | | ចំនួនអត្តសញ្ញាណប័ណ្ណ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនសរុប | បានការ | មិនបានការ | | បោះពុម្ព | ប្រគល់ |
| | | | | | ខូច | ស្ទួន | | |
| ១ | រាជធានីភ្នំពេញ | ១.០២៧.៧៣១ | ១.០០៧.៥៦៣ | ៩៦៥.៥២៥ | ៦.៨៤៣ | ៣៥.១៨៥ | ៩៦២.៩១៣ | ៩៦២.៩១៣ |
| ២ | ខេត្ត កណ្ដាល | ៩១២.៨៤៧ | ៨៩៩.៧២៤ | ៨៧៩.៣០៤ | ៣.៧៣០ | ១៦.៦៩០ | ៨៧៩.៣៦៧ | ៨៧៩.៣៦៧ |
| ៣ | ខេត្ត កំពង់ស្ពឺ | ៦៦៤.៨៩០ | ៦៧០.៦៦៦ | ៦២៥.៩១៥ | ៩.៣០៥ | ៣៥.៤៤៦ | ៦២៥.០៦៣ | ៦២៣.៩៥៣ |
| ៤ | ខេត្ត កំពង់ឆ្នាំង | ៤០៧.៣៤៥ | ៤១២.៣៨២ | ៣៩៣.៤៨៨ | ៦.១០២ | ១២.៧៩២ | ៣៩២.៩៧២ | ៣៩២.៩៧២ |
| ៥ | ខេត្ត ព្រៃវែង | ៩៣៣.១៦១ | ៩២៨.៥០៣ | ៨៨៣.៩៥៦ | ២.៨៣៣ | ៤១.៧១៤ | ៨៨៣.៤៨០ | ៨៨២.៧៩០ |
| ៦ | ខេត្ត កំពង់ចាម | ៨៥២.១៥២ | ៨៤៧.៨០០ | ៨១៥.៧៧២ | ១.៥១២ | ៣០.៥១៦ | ៨១៥.៤៧៦ | ៨១៥.៤៧៦ |
| ៧ | ខេត្ត ក្រចេះ | ២៥៩.៧២៨ | ២៦៦.៨៦០ | ២៤៦.៨៥២ | ៩.៩៦៥ | ១០.០៤៣ | ២៤៥.៧០៩ | ២៤៥.៧០៩ |
| ៨ | ខេត្ត ស្ទឹងត្រែង | ៩២.៨៤៣ | ៩៣.៩២៨ | ៩០.៩៨៩ | ៤៨៤ | ២.៤៥៥ | ៩០.៩៨៩ | ៩០.៦០៤ |
| ៩ | ខេត្ត ស្វាយរៀង | ៤៨៣.៤៨០ | ៤៩៨.៦០៩ | ៤៦៣.៧១៦ | ៣.៨៨១ | ៣១.០១២ | ៤៦២.៧៤១ | ៤៦១.៤៣៨ |
| ១០ | ខេត្ត តាកែវ | ៧៧៨.១៦៣ | ៧៨០.៣៦៦ | ៧៥៣.៩៣៦ | ៣.១៧៤ | ២៣.២៥៦ | ៧៥៣.២៤០ | ៧៥២.៥៤៦ |
| ១១ | ខេត្ត កំពត | ៥១៣.៧១៦ | ៥១៨.១៦២ | ៥០៣.៦៣១ | ៣.៧៧២ | ១០.៧៥៩ | ៥០៣.២៩៣ | ៥០៣.២៩៣ |
| ១២ | ខេត្ត កែប | ៣១.៦៤៧ | ៣២.៣៨៤ | ៣១.៧១៥ | ១០៧ | ៥៦២ | ៣១.៦៦០ | ៣១.៦៦០ |
| ១៣ | ខេត្ត ព្រះសីហនុ | ១៦១.៣៧៧ | ១៦០.២៨៤ | ១៥៥.៩៧៩ | ៣៣៤ | ៣.៩៧១ | ១៥៥.៩១៨ | ១៥៥.៨៨២ |
| ១៤ | ខេត្ត កោះកុង | ១០៧.២៨៦ | ១០២.១៣៨ | ៩៨.១០៦ | ២៤៣ | ៣.៧៨៩ | ៩៧.៨៩៦ | ៩៧.៨៩៦ |
| ១៥ | ខេត្ត កំពង់ធំ | ៥៤៩.៨៣៤ | ៥៥៤.១២៨ | ៥២៥.០១៣ | ១០.៤១៨ | ១៨.៦៩៧ | ៥២៤.៥៥៩ | ៥២៤.៥៥៩ |
| ១៦ | ខេត្ត ពោធិ៍សាត់ | ៣៥៩.៤៩២ | ៣៥៩.១១២ | ៣៤២.៧០៦ | ៣.៨០១ | ១២.៦០៥ | ៣៤២.៣៦២ | ៣៤២.៣១៣ |
| ១៧ | ខេត្ត បាត់ដំបង | ៨៦៣.៦៩៨ | ៨៦៥.៩២៥ | ៨៣៨.៨០២ | ៦.៨២៥ | ២០.២៩៨ | ៨៣៧.៨៥៧ | ៨៣៦.៧៨៩ |
| ១៨ | ខេត្ត សៀមរាប | ៧៥៣.៥៤៥ | ៧៦១.៨៤៩ | ៧២៩.៥៧៤ | ១៦.៥២៩ | ១៥.៧៤៦ | ៧២៩.១២៨ | ៧២៨.៤៦៣ |
| ១៩ | ខេត្ត បន្ទាយមានជ័យ | ៥៦៤.០៤៦ | ៥៧៣.៤៨០ | ៥៤៩.៩៨៧ | ៣.៦១១ | ១៩.៨៨២ | ៥៤៩.៧៨៣ | ៥៤៩.៧៨៣ |
| ២០ | ខេត្ត ឧត្តរមានជ័យ | ១៨៣.៤៩១ | ១៨៥.៨១៧ | ១៧៨.២២៩ | ១.៤២៤ | ៦.១៦៤ | ១៧៧.៩៣២ | ១៧៧.៤៧២ |
| ២១ | ខេត្ត ប៉ៃលិន | ៥១.២៣៥ | ៥១.១៨៦ | ៤៩.៤៨៦ | ១៩១ | ១.៥០៩ | ៤៩.៤៨៦ | ៤៩.៤៨៦ |
| ២២ | ខេត្ត ព្រះវិហារ | ១៥២.០៨៧ | ១៥១.៦៨៤ | ១៤៤.៩៤២ | ១.៣៥៩ | ៥.៣៨៣ | ១៤៤.៩០៩ | ១៤៤.៩០៩ |
| ២៣ | ខេត្ត មណ្ឌលគិរី | ៥៩.៤០៨ | ៤៩.១១០ | ៤៧.៤៩៦ | ២០៩ | ១.៤០៥ | ៤៦.៨៣៨ | ៤៦.៨៣៨ |
| ២៤ | ខេត្ត រតនគិរី | ១៣៩.៥៥០ | ១២៩.៦៨២ | ១២៤.៤២៥ | ៨៧ | ៥.១៧០ | ១២៤.៣៦៣ | ១២៤.៣៦៣ |
| ២៥ | ខេត្ត ត្បូងឃ្មុំ | ៥៨៤.៨៣៣ | ៥៩១.៣៣៣ | ៥៦៨.៧០១ | ២.៥០៩ | ២០.១២៣ | ៥៦៤.៨៩៩ | ៥៦៤.៨៩៩ |
| សរុប | | ១១.៤៨៧.៦២៥ | ១១.៤៩២.៦៧៥ | ១១.០០៨.២៤៥ | ៩៩.២៥៨ | ៣៨៥.១៧២ | ១០.៩៩២.៣៣៣ | ១០.៩៨៥.៨៧៣ |

## ឧបសម្ព័ន្ធទី៨ ស្ថិតិបទល្មើសព្រហ្មទណ្ឌទូទាំងប្រទេស ប្រចាំឆ្នាំ២០២០ ប្រៀបធៀបឆ្នាំ២០១៩

| ល.រ | ប្រភេទបទល្មើស | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | កើន/ថយ | | ការខូចខាត |
|---|---|---|---|---|---|---|
| | | | | ចំនួន | % | |
| I | **បទល្មើសឧក្រិដ្ឋ** | ៦៨២លើក | ៧០១លើក | -១៩ | -៣% | |
| ១ | លួចមានស្ថានទម្ងន់ | ១២៩ | ១២១ | ០៨ | ៧% | ស្លាប់ ២២៨នាក់ |
| ២ | ឃាតកម្ម | ២០៨ | ២០៨ | ០ | ០% | របួស ១.០២៩នាក់ |
| ៣ | រំលោភសេពសន្ថវៈ | ២៨៨ | ២៩០ | -២ | -១% | រងគ្រោះ ១៧៨៤នាក់ |
| ៤ | រំលោភសម្លាប់ | ០២ | ០៨ | -៦ | -៧៥% | បាត់ម៉ូតូ ៣៧៥គ្រឿង |
| ៥ | បង្ខាំងមនុស្សជំរិតយកប្រាក់ | ១៩ | ០៨ | ១១ | ១៣៨% | រថយន្ត ២៥គ្រឿង |
| ៦ | បង្ខាំងមនុស្សខុសច្បាប់ | ៣៣ | ៦២ | -២៩ | -៤៧% | និងសម្ភារៈ មាស ប្រាក់មួយចំនួនទៀត ។ |
| ៧ | បោក និងបង្កើគ្រាប់បែក | ០១ | ០២ | -១ | -៥០% | |
| ៨ | ជះទឹកអាស៊ីត | ០២ | ០២ | ០ | ០% | |
| II | **បទល្មើសមជ្ឈិម** | ២.៥៧២លើក | ២.៤៩៥លើក | ៧៧ | ៣% | |
| ១ | មនុស្សឃាតអចេតនា | ២៥ | ១៧ | ០៨ | ៤៧% | |
| ២ | លួច | ១.១០៩ | ១.១៥៦ | -៤៧ | -៤% | |
| ៣ | ឆក់ | ២៥១ | ២៥៨ | -៧ | -៣% | |
| ៤ | ឆបោក.រំលោភទំនុកចិត្ត | ១១៦ | ១២៦ | -១០ | -៨% | |
| ៥ | ហិង្សាដោយចេតនា | ៧០០ | ៦៤២ | ៥៨ | ៩% | |
| ៦ | អំពើហិង្សាក្នុងគ្រួសារ | ២៩៦ | ១៩៩ | ៩៧ | ៤៩% | |
| ៧ | បំពានខាងផ្លូវភេទដទៃ | ៣៨ | ៦១ | -២៣ | -៣៨% | |
| ៨ | ប្រើអាវុធខុសច្បាប់ | ៣៤ | ៣២ | ០២ | ៦% | |
| ៩ | ប្រើប្រាស់ឯកសារសាធារណៈក្លែង | ០៣ | ០៤ | -១ | -២៥% | |
| | សរុប | ៣.២៥៤លើក | ៣.១៩៦លើក | ៥៨ | ២% | |

## ស្ថិតិគ្រោះថ្នាក់សង្គម ប្រចាំឆ្នាំ២០២០ ប្រៀបធៀបឆ្នាំ២០១៩

| ល.រ | ប្រភេទគ្រោះថ្នាក់ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | កើន/ថយ | | ការខូចខាត |
|---|---|---|---|---|---|---|
| | | | | ចំនួន | % | |
| ១ | ចរាចរណ៍ | ៣.១៧៩ | ៤.១២១ | -៩៤២ | -២៣% | -ស្លាប់រួម ៤.៨២៤នាក់ |
| ២ | អាវុធជាតិផ្ទុះ | ៤២ | ៤៧ | -៥ | -១១% | -របួសរួម ៥.៧៩៦នាក់ |
| ៣ | អគ្គិភ័យ | ៩៣៧ | ៧១៧ | ២២០ | ៣១% | -ឆេះតូប ៥៩៤តូប |
| ៤ | ខ្យល់ព្យុះ | ៤៥០ | ៥៤៥ | -៩៥ | -១៧% | -ឆេះផ្ទះ [illegible] |
| ៥ | រន្ទះបាញ់ | ៨៨ | ១០៦ | -១៨ | -១៧% | -របើកដំបូល [illegible] |
| ៦ | ទឹកជំនន់ | ៦៥ | ២១ | ៤៤ | ២១០% | -រលំផ្ទះ [illegible] |
| ៧ | អគ្គឃាត | ៨៦៣ | ៨០០ | ៦៣ | ៨% | និងសម្ភារៈ មាស ប្រាក់[illegible] |
| ៨ | ផ្សេងៗ | ២.១៩៤ | ១.៨៦២ | ៣៣២ | ១៨% | កត់សម្គាល់ ៖ ស្លាប់[illegible] ១.៦៤៦នាក់ [illegible]នាក់ ។ |
| | **សរុប** | ៧.៨១៨លើក | ៨.២១៩លើក | -៤០១ | -៥% | |

# ឧបសម្ព័ន្ធទី៩

# តួលេខបទល្មើសព្រហ្មទណ្ឌទូទាំងប្រទេស ប្រចាំឆ្នាំ២០២០

| ល.រ | រាជធានី ខេត្ត | ចំនួនកើនថយ | សរុបបទល្មើសសរុប | | បទល្មើសឧក្រិដ្ឋ | | | | | | | | | សរុបបទល្មើសឧក្រិដ្ឋ | | បទល្មើសមជ្ឈិម | | | | | | | | | សរុបបទល្មើសមជ្ឈិម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | លួចមានស្ថានទម្ងន់ | | ឃាតកម្ម | រំលោភសេពសន្ថវៈ | | បង្ខាំងមនុស្ស | | ហោក និង បង្ហូរគ្រាប់ | ជះទឹកអាស៊ីត | | | មនុស្សឃាត អ.នា | លួច | ឆក់ | ឆបោក រំលោភទំនុកចិត្ត | ហិង្សា | | បំពានផ្លូវភេទ | ប្រើអាវុធខុសច្បាប់ | ប្រើឯកសារក្លែង | | |
| | | | 2020 | 2019 | ប្រើអាវុធ | មធ្យោបាយផ្សេងៗ | | រំលោភ | រំលោភសម្លាប់ | ចាប់ជំរិត | ខុសច្បាប់ | | | 2020 | 2019 | | | | | ដោយចេតនា | ក្នុងគ្រួសារ | | | | 2020 | 2019 |
| 1 | ខេត្ត បន្ទាយមានជ័យ | -2 | 80 | 82 | | 02 | 11 | 09 | 01 | | | | | 23 | 31 | | 21 | 06 | 02 | 14 | 07 | 07 | | | 57 | 51 |
| 2 | ខេត្ត បាត់ដំបង | 44 | 174 | 130 | | 05 | 09 | 21 | | | | | | 35 | 33 | | 65 | 10 | 03 | 45 | 12 | 04 | | | 139 | 97 |
| 3 | ខេត្ត កំពង់ចាម | -24 | 44 | 68 | | | 06 | 12 | | | | | | 18 | 18 | 01 | 10 | | 02 | 13 | | | | | 26 | 50 |
| 4 | ខេត្ត កំពង់ឆ្នាំង | -10 | 26 | 36 | | | 03 | 04 | | | | | | 07 | 14 | | 08 | | | 07 | 03 | | 01 | | 19 | 22 |
| 5 | ខេត្ត កំពង់ស្ពឺ | 0 | 42 | 42 | | 01 | 09 | 07 | | | | | | 17 | 17 | | 03 | 02 | | 07 | 12 | 01 | | | 25 | 25 |
| 6 | ខេត្ត កំពង់ធំ | 03 | 83 | 80 | | 02 | 13 | 13 | | 01 | | | | 29 | 28 | 02 | 16 | 01 | | 29 | 06 | | | | 54 | 52 |
| 7 | ខេត្ត កំពត | -45 | 87 | 132 | | 02 | 04 | 12 | | | | | | 18 | 28 | | 30 | | 03 | 30 | 04 | 02 | | | 69 | 104 |
| 8 | ខេត្ត កណ្ដាល | 135 | 634 | 499 | 01 | 27 | 14 | 27 | | | 01 | 01 | | 71 | 68 | 02 | 197 | 15 | 37 | 184 | 120 | 05 | 02 | 01 | 563 | 431 |
| 9 | ខេត្ត កោះកុង | 01 | 51 | 50 | | | 02 | 01 | 01 | | | | | 04 | 10 | | 22 | | 03 | 18 | 04 | | | | 47 | 40 |
| 10 | ខេត្ត ក្រចេះ | 14 | 59 | 45 | 01 | 04 | 07 | 21 | | | | | | 33 | 29 | 01 | 10 | | | 08 | 05 | 02 | | | 26 | 16 |
| 11 | ខេត្ត មណ្ឌលគិរី | -2 | 34 | 36 | | | 02 | 01 | | | | | | 03 | 07 | | 12 | | | 10 | 07 | 01 | 01 | | 31 | 29 |
| 12 | រាជធានីភ្នំពេញ | -184 | 654 | 838 | 04 | 48 | 42 | 23 | | 09 | | | | 126 | 108 | 07 | 240 | 173 | 23 | 66 | 07 | 05 | 07 | | 528 | 730 |
| 13 | ខេត្ត ព្រះវិហារ | -8 | 47 | 55 | | | 06 | 10 | | | | | | 16 | 20 | | 15 | | | 07 | 08 | 01 | | | 31 | 35 |
| 14 | ខេត្ត ព្រៃវែង | -32 | 61 | 93 | 02 | 03 | 03 | 23 | | | | | | 31 | 32 | 02 | 14 | | | 09 | 02 | 01 | 02 | | 30 | 61 |
| 15 | ខេត្ត ពោធិ៍សាត់ | 57 | 182 | 125 | 01 | 02 | 11 | 17 | | | | | | 31 | 29 | 02 | 71 | 07 | 06 | 38 | 24 | 01 | 02 | | 151 | 96 |
| 16 | ខេត្ត រតនគិរី | -9 | 38 | 47 | | 02 | 01 | 15 | | | | | | 18 | 15 | | 09 | | | 05 | 05 | | 01 | | 20 | 32 |
| 17 | ខេត្ត សៀមរាប | 32 | 100 | 68 | 01 | 03 | 11 | 17 | | 01 | 02 | | | 35 | 19 | 01 | 37 | 07 | 03 | 14 | 02 | 01 | | | 65 | 49 |
| 18 | ខេត្ត ព្រះសីហនុ | -5 | 332 | 337 | 04 | 01 | 14 | 12 | | 08 | 25 | | | 64 | 104 | 02 | 156 | 25 | 07 | 60 | | | 16 | 02 | 268 | 233 |
| 19 | ខេត្ត ស្ទឹងត្រែង | 06 | 30 | 24 | | 01 | 02 | 07 | | | | | | 10 | 06 | | 07 | | | | 09 | 04 | | | 20 | 18 |
| 20 | ខេត្ត ស្វាយរៀង | 04 | 45 | 41 | 01 | 02 | 11 | 07 | | | 03 | | | 24 | 11 | | 08 | 01 | | 03 | 07 | | 02 | | 21 | 30 |
| 21 | ខេត្ត តាកែវ | 59 | 222 | 163 | | 06 | 12 | 13 | | | | | | 31 | 32 | 03 | 72 | 01 | 10 | 65 | 39 | 01 | | | 191 | 131 |
| 22 | ខេត្ត ឧត្ដរមានជ័យ | 03 | 22 | 19 | | | 01 | | | | | | | 01 | 04 | 02 | 06 | | 01 | 10 | 01 | 01 | | | 21 | 15 |
| 23 | ខេត្ត កែប | 03 | 22 | 19 | | 01 | | 02 | | | | | | 03 | 02 | | 13 | | 01 | 05 | | | | | 19 | 17 |
| 24 | ខេត្ត ប៉ៃលិន | -6 | 85 | 91 | | 02 | 01 | 07 | | | | | 01 | 11 | 09 | | 32 | 01 | 12 | 21 | 07 | 01 | | | 74 | 82 |
| 25 | ខេត្ត ត្បូងឃ្មុំ | 24 | 100 | 76 | | | 13 | 07 | | | 02 | | 01 | 23 | 27 | | 35 | 02 | 03 | 32 | 05 | | | | 77 | 49 |
| សរុប | | 58 | 3.254 | 3.196 | 15 | 114 | 208 | 288 | 02 | 19 | 33 | 01 | 02 | 682 | 701 | 25 | 1.109 | 251 | 116 | 700 | 296 | 38 | 34 | 03 | 2.572 | 2.495 |

# លទ្ធផលបង្ក្រាបបទល្មើសព្រហ្មទណ្ឌទូទាំងប្រទេស ប្រចាំឆ្នាំ២០២០

| ល.រ | ប្រភេទបទល្មើស | បង្ក្រាបរួម | | បង្ក្រាបជាក់ស្តែង | | បង្ក្រាបដោយស៊ើបអង្កេត | | | | ចាប់តាមដីកាក្នុងឆ្នាំ | | វត្ថុតាង | បង្ក្រាបតាមដីកាឆ្នាំចាស់ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ក្នុងរយៈពេល | | មុនរយៈពេល | | | | | | |
| | | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ដីកា | មនុស្ស | | ដីកា | មនុស្ស |
| I | **សរុបបទល្មើសឧក្រិដ្ឋ** | 593 | 905 | 405 | 640 | 188 | 265 | 04 | 04 | 12 | 12 | អាវុធវែង 16ដើម | 87 | 87 |
| 1 | លួចមានស្ថានទម្ងន់(ប្រើអាវុធ) | 09 | 16 | 04 | 07 | 05 | 09 | | | | | អាវុធខ្លី 40ដើម | 05 | 05 |
| 2 | លួចមានស្ថានទម្ងន់(មធ្យោបាយផ្សេងៗ) | 83 | 184 | 54 | 118 | 29 | 66 | 01 | 01 | | | អាវុធកែច្នៃ 24ដើម | 23 | 23 |
| 3 | ឃាតកម្ម | 167 | 226 | 98 | 128 | 69 | 98 | 01 | 01 | 08 | 08 | គ្រាប់បែក 3គ្រាប់ | 25 | 25 |
| 4 | រំលោភសេពសន្ថវៈ | 280 | 290 | 204 | 212 | 76 | 78 | 02 | 02 | 02 | 02 | កាំបិត 213ដើម | 30 | 30 |
| 5 | រំលោភសម្លាប់ | 01 | 01 | | | 01 | 01 | | | 02 | 02 | ម៉ូតូ 713គ្រឿង | | |
| 6 | បង្ខាំងមនុស្សជំរិតយកប្រាក់ | 20 | 59 | 15 | 53 | 05 | 06 | | | | | រថយន្ត 80គ្រឿង | 01 | 01 |
| 7 | បង្ខាំងមនុស្សខុសច្បាប់ | 32 | 128 | 30 | 122 | 02 | 06 | | | | | ជនសង្ស័យស្លាប់ 01នាក់ | | |
| 8 | បោក និងបង្កៃគ្រាប់បែក | | | | | | | | | | | និងឧបករណ៍ផ្សេងៗ ព្រមទាំងសម្ភារៈ មាស ប្រាក់ មួយចំនួន ។ | | |
| 9 | ជះទឹកអាស៊ីត | 01 | 01 | | | 01 | 01 | | | | | | 02 | 02 |
| 10 | ក្លែងឯកសារសាធារណៈ | | | | | | | | | | | | 01 | 01 |
| II | **សរុបបទល្មើសមជ្ឈិម** | 2.347 | 3.371 | 1.925 | 2.710 | 422 | 661 | 15 | 28 | 60 | 61 | | 308 | 309 |
| 1 | មនុស្សឃាតអចេតនា | 24 | 27 | 21 | 24 | 03 | 03 | | | | | | 04 | 04 |
| 2 | លួច | 969 | 1.459 | 739 | 1.078 | 230 | 381 | 09 | 22 | 22 | 23 | | 68 | 67 |
| 3 | ឆក់ | 239 | 416 | 211 | 354 | 28 | 62 | | | | | | 20 | 20 |
| 4 | ឆបោក.រំលោភទំនុកចិត្ត | 104 | 141 | 71 | 103 | 33 | 38 | 06 | 06 | 11 | 11 | | 104 | 107 |
| 5 | ហិង្សាដោយចេតនា | 655 | 932 | 553 | 783 | 102 | 149 | | | 27 | 27 | | 103 | 102 |
| 6 | ហិង្សាក្នុងគ្រួសារ | 288 | 288 | 267 | 267 | 21 | 21 | | | | | | 01 | 01 |
| 7 | បំពានខាងផ្លូវភេទដទៃទៀត | 32 | 32 | 30 | 30 | 02 | 02 | | | | | | | |
| 8 | ប្រើអាវុធខុសច្បាប់ | 33 | 71 | 30 | 66 | 03 | 05 | | | | | | 05 | 05 |
| 9 | ប្រើប្រាស់ឯកសារសាធារណៈក្លែង | 03 | 05 | 03 | 05 | | | | | | | | 03 | 03 |
| | **សរុប I+II** | 2.940 | 4.276 | 2.330 | 3.350 | 610 | 926 | 19 | 32 | 72 | 78 | | 395 | 396 |

## ឧបសម្ព័ន្ធទី១១

## បញ្ជូនសំណុំរឿងទៅតុលាការ បទល្មើសឧក្រិដ្ឋ (ជាក់ស្តែង+ស៊ើបអង្កេត) ប្រចាំឆ្នាំ២០២០

| ល.រ | រាជធានី ខេត្ត | បញ្ជូនរួម | | លួចមានស្ថានទម្ងន់ | | | | ឃាតកម្ម | | រំលោភសេពសន្ថវៈ | | | | បង្ខាំងមនុស្ស | | | | បោក និងបន្លំគ្រាប់បែក | | ជះទឹកអាស៊ីត | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ប្រើអាវុធ | | មធ្យោបាយផ្សេងៗ | | | | រំលោភ | | រំលោភសម្លាប់ | | ជំរិតយកប្រាក់ | | ខុសច្បាប់ | | | | | |
| | | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស |
| 1 | ខេត្ត បន្ទាយមានជ័យ | 18 | 26 | | | 01 | 01 | 08 | 16 | 09 | 09 | | | | | | | | | | |
| 2 | ខេត្ត បាត់ដំបង | 33 | 37 | | | 05 | 08 | 08 | 09 | 20 | 20 | | | | | | | | | | |
| 3 | ខេត្ត កំពង់ចាម | 17 | 19 | | | | | 05 | 05 | 12 | 14 | | | | | | | | | | |
| 4 | ខេត្ត កំពង់ឆ្នាំង | 06 | 06 | | | | | 02 | 02 | 04 | 04 | | | | | | | | | | |
| 5 | ខេត្ត កំពង់ស្ពឺ | 17 | 21 | | | 01 | 01 | 09 | 13 | 07 | 07 | | | | | | | | | | |
| 6 | ខេត្ត កំពង់ធំ | 25 | 26 | | | 01 | 02 | 10 | 10 | 13 | 13 | | | 01 | 01 | | | | | | |
| 7 | ខេត្ត កំពត | 14 | 15 | | | | | 02 | 03 | 12 | 12 | | | | | | | | | | |
| 8 | ខេត្ត កណ្តាល | 54 | 86 | 01 | 02 | 16 | 44 | 10 | 11 | 26 | 27 | | | | | 01 | 02 | | | | |
| 9 | ខេត្ត កោះកុង | 03 | 03 | | | | | 01 | 01 | 01 | 01 | 01 | 01 | | | | | | | | |
| 10 | ខេត្ត ក្រចេះ | 29 | 31 | 01 | 01 | 02 | 04 | 05 | 05 | 21 | 21 | | | | | | | | | | |
| 11 | ខេត្ត មណ្ឌលគិរី | 03 | 05 | | | | | 02 | 04 | 01 | 01 | | | | | | | | | | |
| 12 | រាជធានីភ្នំពេញ | 100 | 171 | | | 37 | 88 | 31 | 41 | 23 | 23 | | | 09 | 19 | | | | | | |
| 13 | ខេត្ត ព្រះវិហារ | 15 | 18 | | | | | 06 | 06 | 09 | 12 | | | | | | | | | | |
| 14 | ខេត្ត ព្រៃវែង | 28 | 32 | | | 02 | 04 | 03 | 05 | 23 | 23 | | | | | | | | | | |
| 15 | ខេត្ត ពោធិ៍សាត់ | 29 | 34 | 01 | 01 | 02 | 03 | 10 | 13 | 16 | 17 | | | | | | | | | | |
| 16 | ខេត្ត រតនគិរី | 16 | 18 | | | 02 | 03 | 01 | 02 | 13 | 13 | | | | | | | | | | |
| 17 | ខេត្ត សៀមរាប | 34 | 63 | 01 | 04 | 03 | 04 | 10 | 27 | 17 | 19 | | | 02 | 06 | 01 | 03 | | | | |
| 18 | ខេត្ត ព្រះសីហនុ | 62 | 171 | 04 | 06 | 01 | 02 | 12 | 16 | 12 | 12 | | | 08 | 33 | 25 | 102 | | | | |
| 19 | ខេត្ត ស្ទឹងត្រែង | 07 | 07 | | | | | 01 | 01 | 06 | 06 | | | | | | | | | | |
| 20 | ខេត្ត ស្វាយរៀង | 23 | 37 | 01 | 02 | 02 | 02 | 10 | 10 | 07 | 08 | | | | | 03 | 15 | | | | |
| 21 | ខេត្ត តាកែវ | 27 | 37 | | | 05 | 12 | 09 | 12 | 13 | 13 | | | | | | | | | | |
| 22 | ខេត្ត ឧត្តរមានជ័យ | 01 | 01 | | | | | 01 | 01 | | | | | | | | | | | | |
| 23 | ខេត្ត កែប | 02 | 04 | | | 01 | 03 | | | 01 | 01 | | | | | | | | | | |
| 24 | ខេត្ត ប៉ៃលិន | 10 | 11 | | | 02 | 03 | 01 | 01 | 07 | 07 | | | | | | | | | | |
| 25 | ខេត្ត ត្បូងឃ្មុំ | 20 | 26 | | | | | 10 | 12 | 07 | 07 | | | | | 02 | 06 | | | 01 | 01 |
| **សរុប** | | 593 | 905 | 09 | 16 | 83 | 184 | 167 | 226 | 280 | 290 | 01 | 01 | 20 | 59 | 32 | 128 | | | 01 | 01 |

# ឧបសម្ព័ន្ធទី១២

## បញ្ជីសំណុំរឿងទៅតុលាការ បទល្មើសមជ្ឈឹម (ជាក់ស្តែង+ស៊ើបអង្កេត) ប្រចាំឆ្នាំ២០២០

| ល.រ | រាជធានី ខេត្ត | បញ្ជីរួម | | មនុស្សឃាត អចេតនា | | លួច | | ឆក់ | | ឆបោក រំលោភទំនុកចិត្ត | | អំពើហិង្សា ដោយចេតនា | | អំពើហិង្សា ក្នុងគ្រួសារ | | បំពានខាង ផ្លូវភេទដទៃទៀត | | ប្រើអាវុធ ខុសច្បាប់ | | ប្រើប្រាស់ ឯកសារក្លែង | | វត្ថុតាង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | ករណី | មនុស្ស | |
| 1 | ខេត្ត បន្ទាយមានជ័យ | 49 | 69 | | | 16 | 32 | 06 | 07 | 01 | 01 | 12 | 15 | 07 | 07 | 07 | 07 | | | | | អាវុធវែង 16ដើម |
| 2 | ខេត្ត បាត់ដំបង | 134 | 193 | | | 61 | 83 | 10 | 20 | 03 | 04 | 44 | 70 | 12 | 12 | 04 | 04 | | | | | អាវុធខ្លី 40ដើម |
| 3 | ខេត្ត កំពង់ចាម | 26 | 57 | 01 | 02 | 10 | 14 | | | 02 | 02 | 13 | 39 | | | | | | | | | អាវុធកែច្នៃ 24ដើម |
| 4 | ខេត្ត កំពង់ឆ្នាំង | 19 | 22 | | | 08 | 10 | | | | | 07 | 08 | 03 | 03 | | | 01 | 01 | | | គ្រាប់បែក 3គ្រាប់ |
| 5 | ខេត្ត កំពង់ស្ពឺ | 25 | 29 | | | 03 | 07 | 02 | 02 | | | 08 | 08 | 11 | 11 | 01 | 01 | | | | | កាំបិត 213ដើម |
| 6 | ខេត្ត កំពង់ធំ | 44 | 68 | 02 | 02 | 10 | 16 | 01 | 04 | | | 25 | 40 | 06 | 06 | | | | | | | ម៉ូតូ 713គ្រឿង |
| 7 | ខេត្ត កំពត | 60 | 81 | | | 27 | 31 | | | 01 | 10 | 26 | 34 | 04 | 04 | 02 | 02 | | | | | រថយន្ត 80គ្រឿង |
| 8 | ខេត្ត កណ្តាល | 512 | 661 | 01 | 01 | 160 | 224 | 14 | 29 | 36 | 46 | 176 | 236 | 119 | 119 | 04 | 04 | 01 | 01 | 01 | 01 | និងឧបករណ៍ផ្សេងៗ ព្រមទាំងសម្ភារៈ |
| 9 | ខេត្ត កោះកុង | 45 | 68 | | | 21 | 43 | | | 03 | 03 | 17 | 18 | 04 | 04 | | | | | | | មាស ប្រាក់មួយចំនួន ។ |
| 10 | ខេត្ត ក្រចេះ | 23 | 28 | 01 | 01 | 08 | 12 | | | | | 07 | 08 | 05 | 05 | 02 | 02 | | | | | |
| 11 | ខេត្ត មណ្ឌលគិរី | 30 | 44 | | | 12 | 17 | | | | | 09 | 18 | 07 | 07 | 01 | 01 | 01 | 01 | | | |
| 12 | រាជធានីភ្នំពេញ | 489 | 702 | 07 | 07 | 224 | 314 | 167 | 265 | 22 | 26 | 50 | 67 | 07 | 07 | 05 | 05 | 07 | 11 | | | |
| 13 | ខេត្ត ព្រះវិហារ | 20 | 21 | | | 06 | 06 | | | | | 06 | 07 | 08 | 08 | | | | | | | |
| 14 | ខេត្ត ព្រៃវែង | 29 | 38 | 02 | 02 | 13 | 20 | | | | | 09 | 11 | 02 | 02 | 01 | 01 | 02 | 02 | | | |
| 15 | ខេត្ត ពោធិ៍សាត់ | 119 | 166 | 02 | 02 | 45 | 73 | 05 | 13 | 06 | 14 | 34 | 36 | 24 | 24 | 01 | 01 | 02 | 03 | | | |
| 16 | ខេត្ត រតនគិរី | 18 | 36 | | | 08 | 14 | | | | | 04 | 16 | 05 | 05 | | | 01 | 01 | | | |
| 17 | ខេត្ត សៀមរាប | 61 | 91 | 01 | 01 | 34 | 54 | 07 | 13 | 03 | 03 | 13 | 17 | 02 | 02 | 01 | 01 | | | | | |
| 18 | ខេត្ត ព្រះសីហនុ | 265 | 517 | 02 | 02 | 156 | 290 | 23 | 56 | 07 | 07 | 59 | 114 | | | | | 16 | 44 | 02 | 04 | |
